ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

វិស្វេទវកាសពិត



- ចងចាំថ្ងៃ១៧ មេសា
- ថ្ងៃ១៧ មេសា ខ្មែរក្រហមបានធ្វើអ្វី?

ចែកជូនដោយឥតគិតថ្លៃជូនមន្ទីរស្រុកនិងឃុំចាំឲ្យព្រះរាជាណាចក្រកម្ពុជា

លេខ១៤៨ ខែមេសា ឆ្នាំ២០១២

ស្វែងរកការពិត

លេខ១៤៨ ខែមេសា ឆ្នាំ២០១២

ឧស្សរនាទដ្ឋីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

មាតិកា

◆ បទចាំថ្ងៃ១៧ មេសា ១

ផ្នែកឯកសារ

◆ ឆ្នាំ១៩៦០ មហាសន្និបាតបក្សលើកទី កំណត់នូវមាគ៌ា ៨

◆ បម្រើយសារការពារយង់ ពៅ ប្រធានសន្តិសុខតំបន់១០៦ ..... ១៤

ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ

◆ សក្តីកម្ម ខុច ប្រឆាំងនឹងមេដឹកនាំខ្មែរក្រហម ១៦

◆ ថ្ងៃ១៧ មេសា ខ្មែរក្រហមបានធ្វើអ្វី? ២៤

◆ អតីតយុទ្ធនារីខ្មែរក្រហមនៅតែសម្រេចចិត្ត ២៦

◆ ហ្សុលី ខ : ស្ត្រីចាមដ៏រឹងមាំម្នាក់ ២៨

◆ ប្តីខ្ញុំស្លាប់ដោយសារតែមួកកន្តឹប ៣១

ផ្នែកច្បាប់

◆ សមភាពរវាងភាគី និងឯករាជ្យភាពរបស់តុលាការ ៣៤

វេទិកាពិភាក្សាសាធារណៈ

◆ ការពិនិត្យមើលសារឡើងវិញលើការចរចាឆ្ពោះទៅ ៣៨

◆ ប្រតិកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅលើសាលដីកា ៤៥

ឯកសារស្រាវជ្រាវរកត្រួសារ

◆ ដំណើរជីវិតត្រួសារខ្ញុំក្រោមរបប ប៉ុល ពត ៥៣

◆ រឿងបដិវត្តន៍ : ពលីកម្មរបស់យុទ្ធមិត្តយើង ៥៥

រូបថតគម្របមុខ : *យោធាខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងក្មេងៗជិះរថយន្តអបអរសាទរពិធីបុណ្យចូលឆ្នាំខ្មែរ ។ (រូបថត : រ៉ូឡង់ ឌើរើ)*



ស្ត្រីឱនក្បូនៗរបស់គាត់ចាកចេញពីទីក្រុងភ្នំពេញជាមួយនឹងទ្រព្យសម្បត្តិដាល់ខ្នងរបស់គាត់ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ (រូបថត : រ៉ូឡង់ ឌើរើ)

រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យចោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ០២៩១ពម.៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរខ្មែរក្រហមប្រល័យពូជសាសន៍ទួលស្លែង

ស្នេរលេខនេះ : *លី សុខឃាង, ចាន ច្រាថ្ម, ភីឡឺរី អ៊ី ស្រេឡើរី, ស៊ីវ ហេឌើ, លី មុនីសក្តិ* ***អ្នកនិពន្ធនិងស្រាវជ្រាវ :*** *ទាវ សារៈមុនិន្ទ, សោម ប៊ុនដន, ស៊ុន សុធីតា* ***អ្នកបកប្រែ :*** *ខែន សុខស្រីនិត* ***និពន្ធនាយកទទួល :*** *ឆាំង យុ* ***ជំនួយការនិពន្ធនាយក :*** *ញាណ សុជាតិ* ***ក្រាហ្វិកកុំព្យូទ័រ :*** *ស៊ឹម សុភ័ក្ត្រ* ***ត្រួតត្រាការចែកផ្សាយ :*** *ឆេង វ៉ែន*

Email: dccam@online.com.kh, Homepage: www.dccam.org

ចងចាំថ្ងៃ១៧ មេសា

ក្នុងការដោះស្រាយស្ថានភាពក្រោយជម្លោះនៅក្នុងប្រទេសកម្ពុជា បុគ្គលម្នាក់ៗ រដ្ឋ សង្គមស៊ីវិល និងអ្នករួមចំណែកផ្សេងទៀតបានគិតដល់វប្បធម៌ សាសនា នយោបាយ និងបុព្វហេតុផ្សេងទៀត។ កិច្ចខិតខំប្រឹងប្រែងទាំងឡាយ ដែលនឹងបកស្រាយខាងក្រោមនេះ បានបម្រើគោលបំណងនៃការថែរក្សាការចងចាំស្មៀងរកការពិត និងយុត្តិធម៌។ យ៉ាងណាមិញ មនុស្សម្នាទាំងឡាយមិនសូវដាយកចិត្តទុកដាក់នូវព្រឹត្តិការណ៍ «ថ្ងៃព្រហស្បតិ៍ ទី១៧ ខែមេសា ឆ្នាំ១៩៧៥» ដែលជារបត់ដ៏ខ្លោចផ្សានៅក្នុងប្រវត្តិសាស្ត្រកម្ពុជាទេ។ នៅថ្ងៃនោះ ក្រុមម៉ៅនិយមជ្រុលមួយក្រុមដែលស្គាល់ថាជាខ្មែរក្រហមបានទទួលជោគជ័យក្នុងការវាយប្រយុទ្ធចូលទីក្រុងភ្នំពេញ ហើយរបបសាធារណរដ្ឋខ្មែររបស់ លន់ នល់ បានចុះចាញ់។ ពេលនោះ ប្រទេសកម្ពុជាទាំងមូលបានធ្លាក់ក្រោមការគ្រប់គ្រងរបស់យោធាខ្មែរក្រហមដែលចូលកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

អ្នករស់នៅទីក្រុងជាច្រើនបានបង្ហាញនូវអារម្មណ៍រីករាយថា សង្គ្រាមបានបញ្ចប់ ហើយភាពសុខសាន្ត សន្តិភាព សន្តិសុខសង្គម និងការកសាងជាតិនឹងលេចជារូបរាងឡើង។ ភាពរីករាយទាំងអម្បាលម៉ានត្រូវបានជំនួសមកវិញភ្លាមនូវភាពភ័យខ្លាច ភាពច្របូកច្របល់ និងភាពតក់ស្លុតឥតឧបមា។ នៅថ្ងៃទី ១៧ មេសា ដដែលនោះដែរ យោធាខ្មែរក្រហមចាប់ផ្តើមជម្លៀសប្រជាជនចេញពីទីក្រុងនិងតាមទីប្រជុំជននានាដើម្បីទៅកាន់ទីជនបទ។ ការជម្លៀសនិងគោលនយោបាយខ្មែរក្រហមផ្សេងទៀតបានបង្កឲ្យមានការបាត់បង់ជីវិតប្រជាជនកម្ពុជាជិតពីរលាននាក់។

ប៉ុន្តែ ថ្មីៗនេះ អតីតមេដឹកនាំខ្មែរក្រហម នួន ជា បានផ្តល់សក្ខីកម្មនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហមថា គាត់មិនបានដឹងពីគម្រោងការនៃការជម្លៀសប្រជាជននៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥នោះទេ។ នួន ជា បានឲ្យការពារខ្លួនឯងនៅក្នុងសាលាក្តីនោះថា សេចក្តីសម្រេចក្នុងការជម្លៀសប្រជាជនត្រូវបានធ្វើឡើងដោយមូលដ្ឋានថ្នាក់ក្រោមដែលលេខាភូមិភាគនីមួយៗជាអ្នកចាត់ចែងរឿងនេះ។

ប៉ុន្តែ ទោះបីជាមេដឹកនាំទាំងនោះខិតខំព្យាយាមបញ្ជាក់នូវភាពបរិសុទ្ធរបស់ខ្លួនយ៉ាងណាក៏ដោយ យុត្តិធម៌តាមរយៈការកាត់ទោសមេដឹកនាំទាំងនោះនៅសាលាក្តីខ្មែរក្រហមនឹងលាតត្រដាងឡើង។ ស្របពេលជាមួយគ្នានេះដែរ ការប្តេលទោសខាងសង្គមកើតមាននៅគ្រប់ទីកន្លែង។

ការស្វែងរកការផ្សះផ្សាជាតិនៅក្នុងប្រទេសកម្ពុជានៅតែជាផលិបាកដ៏ចម្ងាន់មួយសម្រាប់រដ្ឋាភិបាលកម្ពុជា សង្គម

"All the News That's Fit to Print"

The New York Times

LATE CITY EDITION

VOL. CXXIV. No. 42,817 NEW YORK, THURSDAY, APRIL 17, 1975 20 CENTS

PHNOM PENH SURRENDERS TO REBEL FORCES AFTER OFFER OF A CEASE-FIRE IS REJECTED

Saigon Peril Grows as Troops Near Xuan Loc Fall Back

S.E.C. Says Northrop Kept $30-Million Secret Fund

BIEN HOA POUNDED

South Vietnam Force Abandons Port City of Phan Rang

REPORTS ON RADIO

Government Soldiers Are Directed to Cease Combat

EXTRA TAX SOUGHT TO AID DOWNTOWN

Business Leaders Assert Recession Nears a Low Point

FORD ASSERTS U.S. HAS FAILED SAIGON

Reporter's Notebook: Cambodia

U.S. Considers Corridor To Evacuate Vietnamese

VIETCONG DEMAND FULL U.S. PULLOUT

Radiohelsinhom Dies

Soviet Politburo Drops Shelepin, Formerly a Contender for Power

សារព័ត៌មានញូវយ៉កថែម លេខចុះផ្សាយថ្ងៃព្រហស្បតិ៍ ទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដែលត្រូចដណ្តប់រឿងរ៉ាវ ហេតុការណ៍នៃការដួលរលំទីក្រុងភ្នំពេញដោយយោធាខ្មែរក្រហម

ស៊ីវិល និងបុគ្គលម្នាក់ៗ ទោះបីជារបបខ្មែរក្រហមបានកន្ត្រងទៅជាចប់ទស វត្សរ៍ហើយក៏ដោយ ។ ប្រជាជនកម្ពុជាបានស្វែងរកកិច្ចខិតខំប្រឹងប្រែងជាច្រើនដើម្បីលើកកំពស់ការផ្សះផ្សាជាតិនៅក្នុងប្រទេសចាប់តាំងពីរបបខ្មែរក្រហមដួលរលំក្នុងឆ្នាំ១៩៧៩មក ។ ប៉ុន្តែ ជាការលំបាកណាស់ក្នុងការលាស់វែងពីភាពជោគជ័យដោយសារតែការផ្សះផ្សាជាតិគឺជារឿងដាល់ខ្លួនរបស់បុគ្គលម្នាក់ៗ ។

ការប្រារព្ធថ្ងៃជ័យជម្នះ ៧ មករា៖ ទិវាខួប «៧ មករា» ត្រូវបានអ្នករស់រានជីវិតពីរបបខ្មែរក្រហមក្នុងប្រទេសកម្ពុជាភាគច្រើនចាត់ទុកថាជាថ្ងៃដែលគាត់ត្រូវបានរំដោះចេញពីរបបខ្មែរក្រហម និងជាថ្ងៃដែលគាត់ទទួលបានសិទ្ធិនិងសេរីភាពជាមូលដ្ឋានឡើងវិញ ។ រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា សម័យរដ្ឋកម្ពុជានិងគណបក្សប្រជាជនកម្ពុជាបានប្រារព្ធទិវាជ័យជម្នះនេះជារៀងរាល់ឆ្នាំនៅថ្ងៃ៧ ខែមករា ចាប់តាំងពីទសវត្សរ៍៨០ រហូតដល់ពេលបច្ចុប្បន្ននេះ ។ ថ្នាក់ដឹកនាំជាន់ខ្ពស់និងថ្នាក់ដឹកនាំតាមមូលដ្ឋានបានរៀបចំប្រារព្ធពិធីនេះយ៉ាងសកម្មដើម្បីបង្កើតឲ្យមានការចងចាំពីអំពើឃោរឃៅនៃរបបខ្មែរក្រហម ។ ទោះជាយ៉ាងនេះក៏ដោយ អ្នកវិះគន់មួយចំនួនបានអះអាងថា ថ្ងៃ៧ មករា គឺជាថ្ងៃប្រកបដោយភាពអាម៉ាស់ព្រោះថ្ងៃនោះគឺជាថ្ងៃដែលវៀតណាមបានចូលឈ្លានពានប្រទេសកម្ពុជានិងបានត្រួតត្រងអស់រយៈពេលដប់ឆ្នាំពីឆ្នាំ១៩៧៩ ដល់ ១៩៨៩ ។

តុលាការប្រជាជនបដិវត្តន៍៖ នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ ១៩៧៩ ការដាក់ឲ្យមានការទទួលខុសត្រូវតាមផ្លូវច្បាប់លើកដំបូងប្រឆាំងទៅនឹងមេដឹកនាំខ្មែរក្រហមពីររូបបានកើតឡើង ។ ទោះបីជានៅមានការចោទសួរមួយចំនួនទាក់ទងទៅនឹងបទដ្ឋានយុត្តិធម៌ក៏ដោយ ក៏យ៉ាងហោចណាស់តុលាការនេះបានជួយពង្រឹងនូវស្មារតីរបស់ប្រជាជនកម្ពុជានៅពេលនោះដែរ ។ អ្នករស់រានជីវិតពីរបបខ្មែរក្រហមចង់ឃើញយុត្តិធម៌ចំពោះភាពខ្លោចផ្សាដែលគាត់ទទួលរង និងចំពោះសាច់ញាតិដែលបានបាត់បង់ ។ បើមិនដូច្នោះទេ អ្នករស់រានជីវិតទាំងនោះបារម្ភថាវប្បធម៌និទណ្ឌភាពអាចបង្កឲ្យមានវិបត្តិសង្គមកាន់តែជ្រៅឡើងៗក្នុងសង្គមកម្ពុជាទាំងមូល ដែលជាការបង្អាក់ដំណើរការវិវឌ្ឍន៍នៅមុខរបស់ប្រទេសនិងកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការនាំមកនូវសន្តិភាពសន្តិសុខ និងការអភិវឌ្ឍសង្គម ។

ញត្តិរណសិរ្ស៖ គុលាការប្រជាជនបដិវត្តន៍បានរួមចំណែកដ៏សំខាន់មួយចំពោះយុត្តិធម៌តាមផ្លូវច្បាប់តាមរយៈ «ញត្តិ» ចំនួនមួយលានជ្រាំមួយសែន ដែលប្រជាជនកម្ពុជាបានធ្វើក្នុងរវាងឆ្នាំ១៩៨៣ និង១៩៨៤ ។ ញត្តិទាំងនេះគឺជាការខំប្រឹងប្រែងដ៏ជាក់ច្បាស់របស់អ្នករួចរស់ជីវិតពីរបបខ្មែរក្រហមដើម្បីបង្ហាញនិងដោះស្រាយនូវភាពទុក្ខសោករបស់ខ្លួន ។ លើសពីនោះទៅទៀត ញត្តិទាំងអស់នោះបានបង្ហាញនូវរឿងរ៉ាវផ្សេងៗគ្នានូវសោកនាដកម្មដែលអ្នកទាំងនោះបានជួបប្រទះនិងអំពីរឿងរ៉ាវរបស់សាច់ញាតិដែលត្រូវបានសម្លាប់ដោយខ្មែរក្រហមតាមរយៈការបង្ហត់អាហារឬតាមរយៈការធ្វើការជាទម្ងន់ ។ ញត្តិទាំងអស់នោះពិតជាមានសារសំខាន់ក្នុងការស្តាបនាករណីច្បាប់ប្រឆាំងនឹង ប៉ុល ពត, អៀង សារី និងមេដឹកនាំខ្មែរក្រហមសំខាន់ៗជាច្រើនរូបទៀត ។ ញត្តិទាំងនោះគឺជាវេទិការសាធារណៈនិងមានប្រជាប្រិយភាពទាំងផ្នែកផ្លូវចិត្តនិងសង្គមមួយដែលតាមរយៈនោះអ្នករួចរស់ជីវិតបានភ្លោះទោសនូវការកាប់សម្លាប់ដ៏ធំធេងរបស់ខ្មែរក្រហម ។ ការស្វះស្វែងរកការផ្សះផ្សាដាល់ខ្លួននៅក្នុងសហគមន៍បានក្លាយជាដំណើរការដាក់ស្តែងមួយដែលអ្នករួចរស់ជីវិតពីរបបប្រល័យពូជសាសន៍បានអនុវត្ត ។

ការតួសដែនទីរណ្តៅសាកសព ៖ នៅចន្លោះឆ្នាំ១៩៨២ និង២០០៧ រដ្ឋាភិបាលនិងប្រជាជនកម្ពុជាបានគាស់កកាយនិងថែរក្សាអដ្ឋិធាតុនៃរណ្តៅសាកសពរួមចំនួន១៩៧៣ពកន្លែងដើម្បីបង្ហាញនូវការគោរពដល់អ្នកដែលបានស្លាប់ ។ តាមការស្រាវជ្រាវរបស់វីឌីយូហ្គីល បានឲ្យដឹងថា រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាបានខិតខំយ៉ាងខ្លាំងដើម្បីបង្ហាញនូវអដ្ឋិធាតុទាំងអស់ដោយហេតុផលពីរយ៉ាងគឺ ទីមួយរដ្ឋាភិបាលចង់បង្ហាញថាប្រទេសចិន ដែលជាសត្រូវនយោបាយនិងមនោគមន៍វិជ្ជារបស់កម្ពុជានៅពេលនោះគឺជាអ្នកនៅពីក្រោយខ្នងនៃអំពើកាប់សម្លាប់ដ៏មហិមានៅក្នុងប្រទេសកម្ពុជា ហើយទីពីរគឺរដ្ឋាភិបាលបង្ហាញនូវភ័ស្តុតាងយ៉ាងច្បាស់នៃអំពើប្រល័យពូជសាសន៍ក្នុងន័យធ្វើឲ្យរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាជារដ្ឋាភិបាលស្របច្បាប់ក្នុងសហគមន៍អន្តរជាតិ ។ ការពិភាក្សាគ្នាទាក់ទងទៅនឹងថាតើអដ្ឋិធាតុ

ទាំងនេះគួរតែយកទៅបូជាឬយ៉ាងណានោះនៅតែជាបញ្ហាចម្រូងចម្រាសនៅឡើយ ។ អតីតព្រះមហាក្សត្រនរោត្តម សីហនុ បានចេញព្រះរាជសំណេរមួយថា អដ្ឋិធាតុទាំងនោះគួរតែយកទៅបូជាតាមបែបពុទ្ធសាសនាដើម្បីឲ្យព្រលឹងរបស់អ្នកដែលបានស្លាប់ទៅកាន់សុគតិភព ។ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានជំទាស់ទៅនឹងព្រះរាជសំណេរនោះ ដោយសម្តេចបានលើកហេតុផលថា អដ្ឋិធាតុទាំងនោះអាចបម្រើជាភ័ស្តុតាង បូជនីយដ្ឋាននិងសម្រាប់ការអប់រំ ។ សម្តេចនាយករដ្ឋមន្ត្រីបានបញ្ជាក់ពីគោលបំណងក្នុងការធ្វើប្រជាមតិដើម្បីចង់ដឹងពីគំនិតយោបល់របស់ប្រជាជនទាក់ទងទៅនឹងគោលនយោបាយនៃការបូជាអដ្ឋិធាតុទាំងនោះ ។

ការស្តាបនាបូជនីយដ្ឋាន : បូជនីយដ្ឋានជាង៨០កន្លែងត្រូវបានសាងសង់ឡើងចាប់តាំងពីឆ្នាំ១៩៨៦មក ដើម្បីឲ្យសាធារណជនអាចប្រារព្ធពិធីតាមបែបសាសនាដើម្បីឲ្យព្រលឹង

បូជនីយដ្ឋានវត្តស្ងួនពេជ្រ

របស់អ្នកស្លាប់ធ្វើដំណើរទៅកាន់សុគតិភព ។ វាលពិឃាតដើងឯកគឺជាកន្លែងមួយដែលមនុស្សម្នាទាំងឡាយ ទាំងក្មេងចាស់ ប្រុសស្រីនាំគ្នាមកទស្សនានិងអុជធូបបែរបន់ដើម្បីរំពុកដល់សាច់ញាតិដែលបានស្លាប់ ។ បូជនីយដ្ឋានទាំងនេះគឺជាកេរដំណែលដ៏ឈឺចាប់ ។ តែភាពមិនងាយទ្រុឌទ្រោមរបស់ប្រជាជនកម្ពុជាបានជួយឲ្យអ្នកទាំងនោះអាចដោះស្រាយបាននូវព្រឹត្តិការណ៍ប៉ះទង្គិចផ្លូវចិត្តក្រោយពីហេតុការណ៍ព្រៃផ្សៃកើតឡើង ។ សាស្ត្រាចារ្យ រ៉ូបើតា ហ្គ្រីនីនៃសាកលវិទ្យាល័យតិចសាស់ នៅទីក្រុង អូស្ទីន រដ្ឋតិចសាស់ បានអះអាងថា ភាពមិនងាយទ្រុឌទ្រោមបានជួយអ្នកដែលធ្លាប់ឆ្លងកាត់របបយោរយៅឲ្យចេះដោះស្រាយនូវព្រឹត្តិការណ៍ប៉ះទង្គិចផ្លូវចិត្តនានា ហើយអនុញ្ញាតឲ្យអ្នកទាំងនោះអាចធ្វើដំណើរទៅមុខតែមិនបានបំភ្លេចចោលនូវអតីតកាលទេ ។ សាស្ត្រាចារ្យ រ៉ូបើតា ហ្គ្រីនី បានទទួលស្គាល់ថា ភាពមិនងាយទ្រុឌទ្រោមមិនអាចបែកឲ្យដាច់ពីការរស់នៅតាមបែបប្រពៃណីបុរាណនិងការអភិវឌ្ឍសេដ្ឋកិច្ចទេ ។ សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងត្រូវបានបង្កើតឡើងនាដើមទសវត្សរ៍ឆ្នាំ៨០ ហើយសារមន្ទីរនេះបានក្លាយជាផ្នែកមួយដ៏សំខាន់នៃកេរដំណែលរបបប្រល័យពូជសាសន៍ដែលជួយបង្កើតឲ្យមានការចងចាំសម្រាប់អ្នករួចរស់ជីវិត ដោយបង្ហាញនូវអ៊ីដែលរបបខ្មែរក្រហមបានធ្វើចំពោះប្រជាជនកម្ពុជា ។ ការទស្សនាសារមន្ទីរនេះគឺជាទម្រង់មួយនៃការទទួលស្គាល់ចំពោះអ្នករួចរស់ជីវិត ។

ទិវាចងកំហឹង : «ទិវាចងកំហឹង» ដែលបានប្រារព្ធរាល់ឆ្នាំនៅតាមបូជនីយដ្ឋាននានានៅថ្ងៃទី២០ ខែឧសភា តាំងពីឆ្នាំ១៩៨៤មក បង្កើតឲ្យមានភាពស៊ីសង្វាក់គ្នាជាមួយនឹងអតីតកាលរបស់អ្នករួចរស់ជីវិត ។ ទោះបីជានៅថ្ងៃនោះ អ្នកខ្លះបានស្រក់ទឹកភ្នែកក្នុងចិត្តពោរពេញដោយកំហឹងនិងការសងសឹកនៅពេលដែលមន្ត្រីរដ្ឋាភិបាលព្រមទាំងមនុស្សមួយចំនួនទៀតឡើងអានអំពីបទពិសោធន៍កាលពីអតីតកាលក៏ដោយ ក៏ពិធីនេះនៅតែជាដំណាក់កាលមួយដែលអ្នករួចរស់ជីវិតអាចឆ្លុះបញ្ចាំងថាបានឆ្ពោះទោសអំពីការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរបំផុតហើយទិវានោះបានជួយឲ្យអ្នករួចរស់ជីវិតស្វែងរកផ្លូវដួងដឹងបាន ។ ក្នុងឆ្នាំ២០០៩ «ទិវាចងកំហឹង» ត្រូវបានដូរទៅជា «ទិវានៃការចងចាំ» វិញ ។

កម្មវិធីអំពាវនាវ៖ ក្នុងរវាងឆ្នាំ១៩៧៩ រហូតដល់ចុងទសវត្សរ៍ឆ្នាំ៨០ ព្រមគ្នាជាមួយនឹងដំណើរការបង្រួបបង្រួមជាតិ រដ្ឋាភិបាលកម្ពុជាមានបំណងចង់បញ្ចប់សង្គ្រាមស៊ីវិលនិងនាំយកចលនាខ្មែរក្រហមជាមួយនឹងភាគីបដិបក្ខដែលប្រឆាំងនឹងរដ្ឋាភិបាលឲ្យត្រលប់មករួបរួមរស់ក្នុងសង្គមជាតិវិញ។ រដ្ឋាភិបាលបានប្រើកម្មវិធីវិទ្យុ «សម្ងេងអំពាវនាវ» ដើម្បីលើកទឹកចិត្តឲ្យភាគីប្រឆាំងវិលត្រលប់មកសង្គមជាតិវិញ។ ខណៈពេលដែលការប្រយុទ្ធគ្នារវាងកងកម្លាំងខ្មែរក្រហមនិងរដ្ឋាភិបាលកំពុងតែបន្ត ការចរចាផ្នែកនយោបាយគឺជាការចាំបាច់មួយដើម្បីបញ្ចប់ជម្លោះ។ សម្ងេងអំពាវនាវនេះបានត្រួសត្រាយផ្លូវឲ្យមានយន្តការប្រកបដោយផ្នែផ្កាមួយដើម្បីពង្រឹងកិច្ចប្រឹងប្រែងក្នុងការបង្កើតសន្តិភាព។

កិច្ចព្រមព្រៀងទីក្រុងប៉ារីស៖ កិច្ចព្រមព្រៀងទីក្រុងប៉ារីសដែលគ្រប់ភាគីទាំងអស់បានចុះកិច្ចព្រមព្រៀងសន្តិភាពក្នុងខែតុលាឆ្នាំ១៩៩១ គឺជាការអភិវឌ្ឍដ៏ត្រឹមត្រូវមួយដែលកម្ពុជាអាចមើលឃើញក្រោយពីការដកចេញរបស់កងទ័ពវៀតណាមពីប្រទេសកម្ពុជា។ ការប៉ះទង្គិចផ្នែកយោធាបានបញ្ចប់ ហើយជនស៊ីវិលលែងក្លាយជាជនរងគ្រោះនៃជម្លោះទៀតហើយ។ សំខាន់ជាងនេះទៅទៀតនោះគឺព្រះរាជមាតុភូមិនិវត្តន៍របស់ព្រះមហាក្សត្រ នរោត្តម សីហនុ គឺជាការចាប់ផ្តើមនៃដំណើរការសន្តិភាពដ៏ក្មេងខ្ចី។ ព្រះមហាក្សត្របានទទួលការគោរពយ៉ាងខ្លាំងនៅក្នុងសង្គមកម្ពុជា ហើយព្រះមហាក្សត្រគឺជានិមិត្តរូបសម្រាប់ការពង្រីកនិងបង្កើតឲ្យមានសន្តិភាព ការបង្រួបបង្រួមជាតិនៅក្នុងប្រទេសកម្ពុជា។ ប្រជាធិបតេយ្យចាប់ផ្តើមចាក់ឫសនៅក្នុងសង្គម ទោះបីជាការលោះដលវិបាកធំៗមួយចំនួនមិនទាន់បានដោះស្រាយក៏ដោយ ដូចជាការមិនបានរំសាយទ័ព ការមិនឲ្យមានកងទ័ព និងកម្មវិធីសមាហរណកម្ម ការធ្វើពហិការមិនទទួលស្គាល់របស់ខ្មែរក្រហមក្នុងការមិនទទួលស្គាល់កិច្ចព្រមព្រៀងនិងការសម្រុះសម្រួលអំណាចក្រោយលទ្ធផលនៃការបោះឆ្នោតឆ្នាំ១៩៩៣។ យ៉ាងហោចណាស់ប្រជាធិបតេយ្យក្នុងទម្រង់ជាការបោះឆ្នោតត្រូវបានអនុវត្តជាបន្តបន្ទាប់នៅក្នុងប្រទេសកម្ពុជាចាប់តាំងពីពេលនោះមក។

គោលនយោបាយផ្តាច់ខ្លួន៖ ក្នុងរវាងឆ្នាំ១៩៨៤ និង ១៩៩៨ រដ្ឋាភិបាលកម្ពុជាបានព្យាយាមរំលាយចោលរចនា

កងទ័ពរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាកំពុងកត់ឈ្មោះយោធាខ្មែរក្រហមដែលផ្តាច់ខ្លួនចូលមករស់នៅក្នុងសង្គមវិញ

សម្ព័ន្ធរបស់ខ្មែរក្រហមតាមរយៈការចរចាជាច្រើនលើកច្រើនសារ ។ ក្នុងឆ្នាំ១៩៩៦ អតីតរដ្ឋមន្ត្រីការបរទេសរបស់របបកម្ពុជាប្រជាធិបតេយ្យ អៀង សារី ដែលក្រោយមកត្រូវបានដល់ការលើកលែងទោសបានយល់ព្រមចុះចូលជាមួយរដ្ឋាភិបាល ។ មេដឹកនាំខ្មែរក្រហមផ្សេងទៀតដូចជា ប៉ុល ពត និង តាម៉ុក ដែលជាអតីតលេខាភូមិភាគនិរតីបានរឹងទទឹងនឹងមិនចូលរួមក្នុងគោលនយោបាយនេះ ។ ជាលទ្ធផលបង្ហាញថាការដាច់ខ្លួនរបស់មេដឹកនាំខ្មែរក្រហមបានធ្វើឲ្យចលនាខ្មែរក្រហមកាន់តែចុះខ្សោយជាលំដាប់ ។ ទីបញ្ចប់រចនាសម្ព័ន្ធដែលមានលក្ខណៈរៀបចំរបស់ខ្មែរក្រហមត្រូវបានរំលាយនិងបំផ្លាញក្រោយពី ប៉ុល ពត បានស្លាប់ក្នុងឆ្នាំ១៩៩៨ និង តាម៉ុក ត្រូវបានចាប់ខ្លួនក្នុងឆ្នាំ១៩៩៩ ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា : គោលនយោបាយដាច់ខ្លួនគឺជាវិធានការណ៍ដ៏មានប្រសិទ្ធភាពមួយក្នុងការបញ្ចប់សង្គ្រាមស៊ីវិល ។ ក្នុងឆ្នាំ១៩៩៧ រដ្ឋាភិបាលកម្ពុជាបានសរសេរលិខិតមួយច្បាប់ផ្ញើជូនទៅអង្គការសហប្រជាជាតិដើម្បីស្នើសុំជំនួយក្នុងការនាំយកទៅកាន់យុត្តិធម៌នូវជនទាំងឡាយណាដែលទទួលខុសត្រូវចំពោះការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរបំផុតក្នុងចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងថ្ងៃ៦ មករា ឆ្នាំ១៩៧៩ ។ ប្រាំមួយឆ្នាំក្រោយមក រដ្ឋាភិបាលនិងអង្គការសហប្រជាជាតិយល់ព្រមបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់ទោស «មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត» ចំពោះបទឧក្រិដ្ឋនៃរបបខ្មែរក្រហម ។ តុលាការចម្រុះនេះត្រូវបានមើលឃើញថាជាយន្តការប្រកប ដោយក្តីសង្ឃឹមមួយដើម្បីផ្តល់យុត្តិធម៌ចំពោះជនរងគ្រោះនិងដើម្បីឲ្យប្រជាជនកម្ពុជាវិវឌ្ឍន៍ទៅមុខទៅរកការផ្សះផ្សាជាតិ ។

ផលប៉ះពាល់នៃយន្តការសង្គម នយោបាយ ផ្លូវច្បាប់ និងប្រពៃណី ដែលចេះតែបន្តនេះបាននាំមកនូវកម្រិតជាក់លាក់មួយនៃការព្យាបាលរបួសផ្លូវចិត្តនិងការបង្រួបបង្រួមជាតិចំពោះប្រជាជនកម្ពុជា ។ រដ្ឋាភិបាលនិងបុគ្គលម្នាក់ៗបានខិតខំប្រឹងប្រែងដើម្បីបង្កើតឲ្យមានការព្យាបាលរបួសផ្លូវចិត្ត និងការបង្រួបបង្រួមជាតិនេះ ។ ស្របពេលជាមួយគ្នានេះដែរ មជ្ឈមណ្ឌលឯកសារកម្ពុជានិងស្ថាប័នផ្សេងទៀតក៏បានជួយក្នុងការរួមចំណែកជាមួយរដ្ឋាភិបាលនិងបុគ្គលក្នុងកិច្ចការនេះដែរ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាគឺជាស្ថាប័នក្រៅរដ្ឋាភិបាលមួយដែលបានរួមចំណែកក្នុងការបន្តែមឲ្យមានការផ្សះផ្សាជាតិនៅក្នុងសង្គមកម្ពុជា ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានគម្រោងចំនួនប្រាំដូចខាងក្រោមនេះដើម្បីលើកកម្ពស់ការផ្សះផ្សាជាតិដូចជា :

សៀវភៅរំឭកវិញ្ញាណកូន្ធអ្នកដែលបានស្លាប់ក្នុងរបបខ្មែរក្រហម : តាំងពីឆ្នាំ២០០៦មក មជ្ឈមណ្ឌលឯកសារកម្ពុជាចាប់ផ្តើមកត់ត្រាចងក្រងឈ្មោះអ្នកដែលបានស្លាប់ជាតិបងជីវិតនិងបាត់ខ្លួនក្នុងរបបខ្មែរក្រហមពីឆ្នាំ១៩៧៥ដល់១៩៧៩ ។ ឈ្មោះចំនួនជិតមួយលាននាក់មាននៅក្នុងប្រព័ន្ធទិន្នន័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជារួចហើយ ។ សៀវភៅនេះមានគោលបំណងជួយប្រជាជនកម្ពុជាក្នុងការស្រាវជ្រាវរកព័ត៌មានទាក់ទងទៅនឹងសមាជិកគ្រួសារដែលបានបាត់ខ្លួនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ សៀវភៅនេះនឹងចែកចាយដោយឥតគិតថ្លៃដល់សាលាឃុំទាំងអស់ទូទាំងប្រទេសកម្ពុជា ដូច្នេះអ្នកភូមិអាចឃើញឈ្មោះសាច់ញាតិរបស់គាត់ដែលបានបាត់ខ្លួននិងស្រាវជ្រាវរកឈ្មោះជនរងគ្រោះដែលមជ្ឈមណ្ឌលឯកសារកម្ពុជាមានព័ត៌មាន ។ មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងធ្វើការជាមួយនិងជនជាតិន័រវេម្នាក់ឈ្មោះ ស៊ីលវេលសិន អាគីវែត ដើម្បីបញ្ចូលឈ្មោះទាំងនោះចូលទៅក្នុងប្រព័ន្ធទិន្នន័យអេឡិចត្រូនិចដែលសាធារណជនអាចចូលមើលបានទូទាំងសាកលលោក ។

គម្រោងអប់រំពីអំពើប្រល័យពូជសាសន៍ : ក្នុងឆ្នាំ២០០៧ មជ្ឈមណ្ឌលឯកសារកម្ពុជាមានបំណងចែកចាយសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យទៅដល់សិស្ស-និស្សិតកម្ពុជាទាំងឡាយ ។ ដំណាក់កាលដំបូងគឺទាក់ទងទៅនឹងការសរសេរសៀវភៅសិក្សាលើកដំបូងមួយអំពីរបបខ្មែរក្រហមដែលមានចំណងដើងថា «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យឆ្នាំ១៩៧៥-១៩៧៩) » ។ ចាប់តាំងពីពេលនោះមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចែកចាយសៀវភៅនេះចំនួនប្រាំសែនក្បាលទូទាំងប្រទេស ហើយនិងបានបណ្តុះបណ្តាលគ្រូប្រវត្តិសាស្ត្រចំនួន៣០០នាក់ទូទាំងប្រទេសអំពីរបៀបក្នុងការបង្រៀនឲ្យមានប្រសិទ្ធភាពនិងចំគោលដៅ ។ ដោយធ្វើការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ក្រសួងអប់រំយុវជន និងកីឡា បានតម្រូវឲ្យមានការបង្រៀនអំពីការអប់រំអំពើ

ប្រល័យពូជសាសន៍ដល់សិស្សនិស្សិតកម្រិតវិទ្យាល័យនិងគ្រឹះស្ថានឧត្តមសិក្សាទាំងអស់នៅក្នុងកម្មវិធីសិក្សាដោយអនុវត្តត្រឹមឆ្នាំ ២០១១តទៅ ។ បទបញ្ជារបស់ក្រសួងបានបង្គាប់ថា គ្រូប្រវត្តិសាស្ត្រកម្រិតមធ្យមសិក្សាទាំងអស់ត្រូវតែចូលរួមក្នុងសិក្ខាសាលាបណ្តុះបណ្តាលអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងវិធីសាស្ត្របង្រៀនដើម្បីទទួលបាននូវវិញ្ញាបនបត្រមុននឹងទៅបង្រៀនសិស្សពីរបបកម្ពុជាប្រជាធិបតេយ្យ ។ វគ្គបណ្តុះបណ្តាលថ្នាក់ខេត្តនិងថ្នាក់ជាតិត្រូវបានរៀបចំឡើងក្នុងឆ្នាំ២០០៩ ហើយវគ្គបណ្តុះបណ្តាលថ្នាក់មូលដ្ឋានចាប់ផ្តើមឡើងក្នុងឆ្នាំ២០១០ ។ មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡាក៏បានរៀបចំវគ្គបណ្តុះបណ្តាលលើកទីមួយដល់គ្រូកម្រិតសកលវិទ្យាល័យ និងមន្ត្រីនគរបាលដែរ ។

ក្រុមការងារស្តីពីការចងក្រងឯកសារប្រវត្តិសាស្ត្រកម្ពុជា : ក្នុងឆ្នាំ២០០៨ ដោយសហការជាមួយក្រសួងអប់រំ យុវជន និង កីឡា មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំសិក្ខាសាលាគ្រូបង្រៀនប្រចាំឆ្នាំលើកទីបីក្នុងគោលបំណងបង្កើតក្រុមការងារមួយដើម្បីសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាតាមរយៈការស្វែងរកការពិតនិងការបង្រួបបង្រួមជាតិ ។

អ្នកចូលរួមនៅក្នុងសិក្ខាសាលានោះរួមមានគ្រូបណ្តុះបណ្តាលថ្នាក់ជាតិចំនួន២៤រូប និងគ្រូបណ្តុះ បណ្តាលថ្នាក់ខេត្តចំនួន ១៨០រូបដែលសុទ្ធតែបានទទួលការបណ្តុះបណ្តាលអំពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ គម្រោងនេះបង្កើតឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានជំនឿថាគម្រោងអប់រំអំពើប្រល័យពូជសាសន៍អាចប្រើជាមូលដ្ឋានមួយសម្រាប់ស្រាវជ្រាវអំពីការពិតឲ្យបានទូលំទូលាយនិងជួរការជាងមុន និងបេសកកម្មស្វែងរកការពិត ។ ក្រសួងអប់រំបានស្នើថាគ្រូបណ្តុះបណ្តាលថ្នាក់ជាតិ និងថ្នាក់ខេត្តអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រមូលនិងចែកចាយព័ត៌មានប្រវត្តិសាស្ត្ររបបខ្មែរក្រហម ។ ដំណើរការផ្សះផ្សានិងស្វែងរកការពិតរបស់កម្ពុជាអាចជាការអប់រំយ៉ាងសំខាន់ក្នុងការចែករំលែកព័ត៌មាន ដែលអាចទទួលយកបាន ហើយនិងកម្មវិធីនេះអាចលាតត្រដាងព័ត៌មានអំពីរបបខ្មែរក្រហមដែលលើសពីដែនកំណត់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

ការថែរក្សាប្រវត្តិសាស្ត្រអន្លង់វែង : នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០ រដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យមួយដើម្បីដាក់ឲ្យមានការថែរក្សានិងអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រអន្លង់វែង ។ ដោយទទួលស្គាល់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងនាមស្ថាប័នមួយដែលមានឯកទេសខាងការស្រាវជ្រាវនិងចងក្រងឯកសារពីរបបខ្មែរក្រហម រដ្ឋាភិបាលកម្ពុជាបានផ្តល់ការងារនេះដល់មជ្ឈមណ្ឌលឯកសារកម្ពុជាឲ្យធ្វើការសិក្សាឲ្យបានស៊ីជម្រៅនៅតំបន់អន្លង់វែង

សិស្សានុសិស្សទទួលសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ

នេះ ។ ការផ្តល់សិទ្ធិអំណាចនេះបានធ្វើឡើងក្រោយពីមានសារាចរចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០១ ពីសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលដាក់បទបញ្ជាឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើការជាមួយក្រសួងទេសចរណ៍និងស្ថាប័នពាក់ព័ន្ធដើម្បីកំណត់ការបង្កើតសារមន្ទីរ បូជនីយដ្ឋាន និងដំណើរការថែរក្សាប្រវត្តិសាស្ត្រសម្រាប់ស្រុកអន្លង់វែង ។ ដោយសារតែបទបញ្ជានេះ និងដោយមានការ

គាំទ្រពីក្រសួងទេសចរណ៍ មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងតែសិក្សាអំពីប្រវត្តិសាស្ត្រអន្ទង់វែងទាំងមូលជាពិសេសទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យនិងដើម្បីថែរក្សាតំបន់នេះជាភស្តុតាងនៃបទឧក្រិដ្ឋរបស់ខ្មែរក្រហម ។ ការសិក្សាតំបន់អន្ទង់វែងដែលធ្វើការរួមគ្នារវាងមជ្ឈមណ្ឌលឯកសារកម្ពុជានិងក្រសួងទេសចរណ៍គឺដើម្បីសម្រេចបានសៀវភៅណែនាំមួយនិងសម្ភារពាក់ព័ន្ធផ្សេងទៀតសម្រាប់អ្នកទស្សនានិងគ្រូបង្រៀននៅក្នុង

ប្ល និងផ្ទាំងរូបភាព

ស្រុកអន្ទង់វែងទាំងមូល ។ កិច្ចការនេះនឹងជួយបង្កើតឲ្យតំបន់នេះក្លាយជាធនធានដ៏សំខាន់មួយដើម្បីឲ្យមានការចងចាំពីអតីតកាលនិងដើម្បីទាញចំណាប់អារម្មណ៍ពីសាធារណជនអំពីទេសភាពដ៏ស្រស់ត្រកាលនៃតំបន់នេះ ។

វិទ្យាស្ថានស្ថិតិ : ចាប់តាំងពីឆ្នាំ២០១១មក មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងតែប្រែទៅជា «វិទ្យាស្ថានស្ថិតិ» ដែលនឹងក្លាយជាស្ថាប័នសម្រាប់ការសិក្សាពីអំពើប្រល័យពូជសាសន៍ដ៏ធំមួយនៅអាស៊ី ។ ក្នុងឆ្នាំ២០១០ ក្រសួងមហាផ្ទៃបានផ្តល់អាជ្ញាបត្រដល់មជ្ឈមណ្ឌលឯកសារកម្ពុជាឲ្យប្រើប្រាស់ឈ្មោះនេះនិងសាងសង់មជ្ឈមណ្ឌលអចិន្ត្រៃយ៍នៅលើទីតាំងមួយដែលផ្តល់ជូនដោយរដ្ឋាភិបាល« ដើម្បីបន្តដំណើរការស្រាវជ្រាវឯកសារនានាដែលពាក់ព័ន្ធទៅនឹងអំពើប្រល័យពូជសាសន៍នៅកម្ពុជានិងនៅក្នុងបណ្តាប្រទេសទាំងឡាយដែលពាក់ព័ន្ធដល់ឯកសាររបបប្រល័យពូជសាសន៍ដើម្បីបម្រើដល់ការចងចាំ យុត្តិធម៌ និងការផ្សះផ្សាជាតិនៅទូទាំងព្រះរាជាណាចក្រកម្ពុជា» ។ វិទ្យាស្ថានស្ថិតិនឹងមានសារមន្ទីរមួយដែលអ្នកទស្សនាអាចរៀនអំពីប្រវត្តិសាស្ត្រខ្មែរក្រហមនិងស្វែងរកការព្យាបាលនៅកន្លែងមួយដែលតាក់តែងឡើងសម្រាប់ស្នើងស្មាធិ៍និងការព្យាបាល ។ វិទ្យាស្ថានស្ថិតិនឹងមានបណ្ណាល័យ និងមជ្ឈមណ្ឌលស្រាវជ្រាវមួយដើម្បីបន្តអនុវត្តការចងក្រងឯកសារ ការវិភាគ និងការថែរក្សាព័ត៌មានអំពីរបបខ្មែរក្រហម និងដើម្បីឲ្យអ្នកស្រាវជ្រាវទូទាំងសកលលោកអាចសិក្សាអំពីការរំលោភសិទ្ធិមនុស្សទូទាំងតំបន់ ។ លើសពីនោះទៅទៀតវិទ្យាស្ថានស្ថិតិនេះនឹងមានអគារសិក្សាមួយដែលនិស្សិតកម្ពុជានិងបរទេសអាចមករៀនសូត្របន្ថែមដើម្បីយកពិន្ទុថ្នាក់ឧត្តមសិក្សាទាក់ទងទៅនឹងបញ្ហាសិទ្ធិមនុស្ស ។ សម្រាប់ព័ត៌មានបន្ថែមអំពីវិទ្យាស្ថាននេះ សូមមើលគេហទំព័រ www.cambodiasri.org ។

អ្វីដែលរៀបរាប់ខាងលើនេះគឺជាដំណើរការកម្រិតថ្នាក់ជាតិដែលអាចជួយប្រជាជនកម្ពុជាឲ្យជាសះស្បើយនិងផ្សះផ្សាតាំងពីរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។ បើគ្មានដំណាក់កាលទាំងអស់ខាងលើនេះនិងភាពមិនដាយទ្រុឌទ្រោមរបស់ប្រជាជនកម្ពុជាទេ ជំងឺសង្គមនឹងញាំញីប្រជាជនកម្ពុជារៀងរាល់ថ្ងៃ ។ ចំណុចនេះអាចធ្វើឲ្យយើងគិតពីចំណុចចាប់ផ្តើមនៃការបាត់បង់ និងភាពទុក្ខសោកដ៏ធំធេងនេះ ។ ថ្ងៃចាប់ផ្តើមនៃការបាត់បង់និងទុក្ខសោកដ៏ធំធែងនោះគឺ «ថ្ងៃ១៧ មេសា» ។ ថ្ងៃដ៏ជូរចត់នេះ ត្រូវបានចាំទុកយ៉ាងជាក់ច្បាស់ និងត្រូវបានមើលឃើញថាជាគ្រឿងរំឭកដ៏រស់រវើកនៃការទប់ស្កាត់ការកើតឡើងវិញនៅថ្ងៃអនាគតនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជានិងនៅសកលលោក ។ **ឈឹ សុខឃាង**

ឆ្នាំ១៩៦០ មហាសន្និបាតបក្សលើកទី១ កំណត់ទុកជាគោលយុទ្ធសាស្ត្រ នៃបដិវត្តន៍ប្រជាជាតិ-ប្រជាធិបតេយ្យ

ដកស្រង់ចេញពីទង់បដិវត្ត លេខពិសេស ធ្នូ-មករា ១៩៧៥-៧៦

ឆ្នាំ១៩៦០

មុនឆ្នាំ១៩៦០ បក្សយើងនៅមិនទាន់មានមាគ៌ាជាយុទ្ធសាស្ត្រជាយុទ្ធវិធីនៅឡើយ។ យើងមានតែការកិច្ចចំពោះមុខ គឺប្រឆាំងចក្រពត្តិ ពិសេសចក្រពត្តិអាមេរិក និងបរិវារវា។ គ្មានមាគ៌ាបដិវត្តន៍ជាយុទ្ធសាស្ត្រ និងយុទ្ធវិធី ប្រៀបដូចជាដើរក្នុងរូងភ្នំងងឹតឈឹង។

ឆ្នាំ១៩៦០ បក្សបើកមហាសន្និបាតបក្សលើកទី១

មហាសន្និបាតបក្សលើកទី១ បានសម្រេចជាឯកច្ឆន្ទកំណត់មាគ៌ាជាយុទ្ធសាស្ត្ររបស់បដិវត្តន៍កម្ពុជា ជាបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ គឺវាយចក្រពត្តិ ពិសេស ចក្រពត្តិអាមេរិកនិងបរិវារវា វាយសក្តិភូមិ និងនាយទុនប្រតិកិរិយា។ កម្លាំងបដិវត្តន៍គឺកម្លាំងប្រជាជាតិទាំងមូលដោយផ្អែកលើសម្ព័ន្ធភាពកម្មករ កសិករ។ រូបភាពស៊ូបដិវត្តន៍ គឺហិង្សាបដិវត្តន៍ខាងនយោបាយ និងហិង្សាបដិវត្តន៍ខាងអាវុធ។ បក្សកុម្មុនីស្តកម្ពុជាតែមួយគត់ជាបក្សដឹកនាំបដិវត្តន៍កម្ពុជា។ ទិសឈានទៅមុខរបស់បដិវត្តន៍ គឺសម្រេចបដិវត្តន៍ប្រជាជាតិ-ប្រជាធិបតេយ្យ ហើយឈានទៅធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយម និងកុម្មុយនីស្តនៅកម្ពុជា។

នេះជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយ ធំសំខាន់ណាស់ចំពោះបក្ស បដិវត្តន៍ ចំពោះប្រជាជន និងប្រជាជាតិកម្ពុជាយើង។ ជាពន្លឺយ៉ាងត្រចេះត្រចង់ នាំផ្លូវចូលចលនាបដិវត្តន៍កម្ពុជាដើម្បីឈានទៅ រំដោះជាតិ រំដោះប្រជាជន រំដោះវណ្ណៈ។ លើកមាគ៌ាបដិវត្តន៍ជាយុទ្ធសាស្ត្របានត្រឹមត្រូវ គឺបំផុសបានជំនឿបដិវត្តន៍យ៉ាងខ្លាំងក្លា ដឹងចង្អុល គឺជំនឿក្នុងជួរកម្លាភិបាលបក្ស។ មានជំនឿគឺខ្លាំង មានកម្លាំងប្រយុទ្ធយ៉ាងមុះមុត។

ឆ្នាំ១៩៦១

បក្សបើកវគ្គ ប្រយុទ្ធវាយសម្រុកអប់រំ ឲ្យកម្លាភិបាលបក្សទាំងនៅជនបទនិងទីក្រុង បានជ្រួតជ្រាប និងក្តាប់មាគ៌ាជាយុទ្ធសាស្ត្រ បដិវត្តន៍ប្រជាជាតិ-ប្រជាធិបតេយ្យបានមួយកម្រិតសំខាន់។ តាមពន្លឺនៃមាគ៌ាជាយុទ្ធសាស្ត្រនេះ សតិអារម្មណ៍កម្លាភិបាលបានវិវឌ្ឍន៍ឡើង។ គោលជំហរបដិវត្តន៍ រឹងជាងមុន។ ស្គាល់មិត្ត ស្គាល់សត្រូវ ច្បាស់ជាងមុន។ មានមាគ៌ាបដិវត្តន៍ត្រឹមត្រូវ សតិអារម្មណ៍បដិវត្តន៍ជ្រះស្រឡះ ការចាត់តាំងរបស់បក្ស ក៏មានរបៀបលាក់ការណ៍ចាត់តាំងរបស់បក្ស។ ចលនាតស៊ូរបស់មហាជននៅជនបទនិងទីក្រុង មានការដឹកនាំកាន់តែត្រឹមត្រូវតាមមាគ៌ារបស់បក្ស ហើយដុសដុលកាន់តែខ្លាំងជាងមុន ក្រោមពាក្យស្លោកប្រឆាំងចក្រពត្តិអាមេរិក និងទាមទារកែប្រែជីវភាពទាមទារសិទ្ធិសេរីភាពប្រជាធិបតេយ្យ។ បានទទួលពន្លឺនៃមាគ៌ាបដិវត្តន៍ជាយុទ្ធសាស្ត្រ គុណភាពកម្លាភិបាល ខាងគោលនយោបាយ សតិអារម្មណ៍ ចាត់តាំងចម្រើនឡើងមួយកម្រិត។ ចលនាតស៊ូរបស់មហាជននៅជនបទនិងទីក្រុងកាន់តែមានគុណភាពបដិវត្តន៍។

ឆ្នាំ១៩៦២

ចក្រពត្តិអាមេរិក បរិវារវា និងវណ្ណៈសក្តិភូមិ-នាយទុនប្រតិកិរិយាកាន់អំណាច បានបង្កើតសកម្មភាពវាយប្រហារបក្ស វាយប្រហារចលនាតស៊ូរបស់ប្រជាជន-មហាជននៅជនបទនិងទីក្រុងកាន់តែខ្លាំងក្លា យោរយៅជាងមុន។

ក្តាប់នូវមាគ៌ាជាយុទ្ធសាស្ត្ររបស់បក្ស កម្លាភិបាលនៅជនបទនិងទីក្រុង បានបំផុសបំផុលចលនាមហាជនតស៊ូថែមទៀត។ យើងការពារបានកម្លាំងបក្ស ការពារបានកម្លាំងមហាជនរក្សានិងបំផុសបានចលនាតស៊ូប្រជាជាតិ-ប្រជាធិបតេយ្យកាន់តែខ្លាំងធំទូលាយ និងជ្រៅជាងមុន។ ចលនាតស៊ូប្រជាជាតិ-ប្រជាធិបតេយ្យរបស់មហាជននៅជនបទនិងទីក្រុង ក្រោមការដឹកនាំរបស់បក្ស ឋិតក្នុងឋានៈវាយសម្រុកជាប់។ ទំនាស់រវាងចក្រពត្តិ

ពិសេសចក្រពត្តិអាមេរិក និងប្រជាជាតិ-ប្រជាជន កាន់តែឡើងស្រួច។ ទំនាស់រវាងសក្តិភូមិ-ម្ចាស់ដី និងកសិករ ចេះតែឡើង។ ភ្លើងបដិវត្តន៍កាន់តែឆេះខ្លាំងឡើង។ កម្លាំងបក្ស កម្លាំងបដិវត្តន៍កាន់តែបានពង្រឹង និងពង្រីកដាលំដាប់។

ឆ្នាំ១៩៦៣

គឺនៅក្នុងសភាពទំនាស់ដ៏តឹងតែង រវាងខ្លាំងនិងបដិវត្តន៍និងក្នុងសភាពដែលភ្លើងបដិវត្តន៍កាន់តែឆេះខ្លាំងនេះ បក្សបានបើកមហាសន្និបាតបក្សលើកទី២ នៅដើមឆ្នាំ១៩៦៣ ដើម្បីបញ្ជាក់ច្បាស់ថែមទៀត នូវមាគ៌ាជាយុទ្ធសាស្ត្រនៃបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ ហើយជំរុញអនុវត្តន៍មាគ៌ានេះឲ្យខ្លាំងក្លាថែមទៀត។ ខ្លឹមសារនៃមហាសន្និបាតបក្សលើកទី២ ចេញពីចលនាប្រយុទ្ធជាក់ស្តែងក្នុងរយៈជិត៨ឆ្នាំ។

ពិសោធន៍នៃការដឹកនាំចលនា ជិត៨ឆ្នាំមកនេះ បានពង្រឹងទស្សនៈ គោលជំហរ នយោបាយ សតិអារម្មណ៍ ចាត់តាំងក្នុងដៃក្នុងបក្ស បានមួយកម្រិតខ្ពស់ជាងមុន។ ជាពិសេស មហាសន្និបាតបក្សលើកទីII បានចង្កត្រងនូវសាមគ្គីភាព-ឯកភាពដៃក្នុងបក្សទាំងខាងទស្សនៈ គោលជំហរ សតិអារម្មណ៍ និងចាត់តាំងបានរឹងប៉ឹង កក់ក្តៅ ជំនឿទុកចិត្តលើអនាគតនៃបដិវត្តន៍ខ្លួន។ ពិសេសទៀត គោលជំហរឯករាជ្យ ម្ចាស់ការ ខ្លួនខបត្តមួយខ្លួន ខ្លួនកាន់កាប់វាសនាប្រទេសជាតិខ្លួនដោយខ្លួនឯង បានជ្រួតជ្រាបថែមទៀតជាសាច់ឈាម អាស្រ័យដោយចលនាបដិវត្តន៍ជាក់ស្តែង បញ្ជាក់ជារូបី។ តើចលនាជាក់ស្តែងបញ្ជាក់អ្វី? ចលនាជាក់ស្តែងបានបញ្ជាក់ច្បាស់ថា មាគ៌ាជាយុទ្ធសាស្ត្រនៃបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ ដែលកើតឡើងពីសម័ន្តភាពកម្មករ-កសិករ ក្រោមការដឹកនាំដ៏ចំមុខតែមួយគត់របស់បក្សកុម្មុយនីស្តកម្ពុជា គឺត្រឹមត្រូវជាទីបំផុត។

យុទ្ធនាការខ្មែរក្រហមច្រូតស្រូវ

ដើម្បីម្ចាស់ការ ដឹកនាំចលនាបដិវត្តន៍ប្រជាជាតិ-ប្រជាធិបតេយ្យ រំលាយសម្រុកទៅលើខ្លាំងកាន់តែខ្លាំងក្លា តាមសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតបក្សលើកទី២ ក្បាលម៉ាស៊ីនដឹកនាំបក្ស បានចុះរៀបចំចាត់តាំង និងពង្រឹងនៅមូលដ្ឋានបង្កែកជនបទ។

កម្មាភិបាលមួយចំនួនសំខាន់ត្រូវចុះជាប់នៅតាមជនបទ។ នេះជាជំហានមួយសំខាន់នៃការពង្រឹងការដឹកនាំរបស់បក្សទូទាំងប្រទេស។ ដោយហេតុនេះ ការដឹកនាំបក្ស កាន់តែមានលក្ខណៈរឹងប៉ឹង ឯកភាពគ្នាខាងទស្សនៈ គោលជំហរ សតិអារម្មណ៍ ហើយជិតស្និទ្ធនឹងចលនាកសិករ ដែលជាកម្លាំងធំសំខាន់របស់ចលនាបដិវត្តន៍ប្រជាជាតិ-ប្រជាធិបតេយ្យ។

ចក្រពត្តិអាមេរិកនិងបរិវារ ដែលមានអាក្បត់ លន់ នល់, សិរិ មតៈ, ស៊ឺន ង៉ុកថាញ់ ជាមេ មានផែនការធ្វើរដ្ឋប្រហារលំប្រទេសកម្ពុជា អព្យាក្រឹត្យ និងរាយកមេចកម្លាំងបក្ស កម្លាំងប្រជាជន-មហាជន។ ដោយមានស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់និងវៃឈ្លាស បក្សបានឆក់យកឱកាសនេះ បំផុសចលនាប្រជាជនមហាជនទាំងជនបទ ទីក្រុង ប្រឆាំងយ៉ាងខ្លាំងក្លា ផែនការធ្វើរដ្ឋប្រហាររបស់ចក្រពត្តិអាមេរិក និងពួកអាក្បត់បរិវារវា។ ដោយរួមផ្សំពាក្យស្លោក ប្រឆាំងរដ្ឋប្រហារ និងពួកអាក្បត់ ការពារប្រទេស ការពារសន្តិភាព អព្យាក្រឹត្យ ជាមួយនឹងពាក្យស្លោកតស៊ូតាមទាវដីធ្លីរបស់កសិករ តាមទាវដង្ហើងប្រាក់ខែរបស់កម្មករ តាមទាវសិទ្ធិសេរីភាពរបស់សិស្ស និស្សិត បញ្ញាជនទីក្រុង ចលនាជាតុកម្មមិទ្ធិង ចលនាតស៊ូចំហ ស្របច្បាប់ មិនស្របច្បាប់ តស៊ូសម្ងាត់ កម្ងាត់ពួកក្បត់នៅតាមជនបទ បានដុលដុសបន្តកន្ទុយគ្នាពីជនបទមួយទៅជនបទមួយ ពីទីក្រុងមួយទៅក្រុងមួយទៀត ធ្វើឲ្យពួកខ្វាំងវិលក្បាច តក់ស្លុតភិតភ័យ ជាត់ម្ងាស់ការ ធ្វើឲ្យផែនការរដ្ឋប្រហាររបស់ខ្មាំងត្រូវបរាជ័យ។

ដោយមានមាគ៌ាយុទ្ធសាស្ត្រនៃបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ ត្រឹមត្រូវ ច្បាស់លាស់ ហើយបានពង្រឹងក្នុងមហាសន្និបាតបក្សលើកទី២ថែមទៀត ហើយដោយមាគ៌ានេះបានចូលជ្រៅទៅក្នុងកម្មាភិបាល-បក្ខជន ប្រជាជន-មហាជន ដូច្នោះចលនាតស៊ូដោយហិង្សាបដិវត្តន៍ ដោយយក ហិង្សាបដិវត្តន៍ខាងនយោបាយជាសំខាន់ ហើយយកហិង្សាបដិវត្តន៍ខាងអាវុធរួមផ្សំជាបន្ទាប់ ចលនាតស៊ូរបស់ប្រជាជន-មហាជន នៅជនបទនិងទីក្រុង កាន់តែដុសដុលមានច្រើនខ្លឹមសារច្រើនរូបភាព។

ទន្ទឹមនឹងនេះ កងយោធាសម្ងាត់របស់បក្ស ដែលបានរៀបចំតាំងពីឆ្នាំ១៩៦០ ដោយជ្រើសរើសយកក្នុងយុវជនកសិករក្រនិងកសិករកណ្តាលថ្នាក់ក្រោម ដើម្បីធ្វើជាកងការពារសម្ងាត់បានចាប់ផ្តើមធ្វើសកម្មភាពដូចជាយាមល្បាតការពារកម្មាភិបាលជួនដំណើរកម្មាភិបាលកម្ទេចគិញចារបុរសយោរយៅ ដែលវាមកបំផ្លាញមូលដ្ឋាន រាតត្បាតប្រជាជន ចាប់ចងកម្មាភិបាល។ល។ ឯប្រជាជន-មហាជន ក៏កាន់តែឃើញថា បើតស៊ូនយោបាយទេមានតែខ្វាំងបង្ក្រាបទាល់តែបំពាក់អាវុធដែរ ទើបតស៊ូបាន។ ដូច្នោះ ប្រជាជន-មហាជន ដែលត្រូវដឹះជាន់សង្កត់សង្កិន មានទស្សនៈតស៊ូដោយហិង្សាអាវុធ ហើយត្រៀមអាវុធជាកាំបិតពូថៅ ដំបង ធ្នូ ស្នា ដើម្បីការពារភូមិ-ឃុំ ការពារប្រជាជន ការពារកម្មាភិបាលបក្ស។

ឆ្នាំ១៩៦៤-១៩៦៥-១៩៦៦

ក្នុងរយៈពេល១៣ឆ្នាំ ចលនាតស៊ូប្រឆាំងចក្រពត្តិអាមេរិកបរិវារ និងចលនាតស៊ូពីបញ្ហាដីធ្លីទៅជនបទ បញ្ហាតស៊ូកែប្រែជីវភាព ប្រជាជនប្រចាំថ្ងៃ តស៊ូតាមទាវសិទ្ធិសេរីប្រជាធិបតេយ្យ

ជានដុលដុសស្ទើរតែរាល់ខែ ។ ចលនាប្រជាជន មហាជន ប្រឆាំងចក្រពត្តិអាមេរិក ឡើងខ្ពស់ជាងពេលណាៗទាំងអស់ ។

ឆ្នាំ១៩៦៨ ប្រជាជន យុវជនសិស្សនៅទីក្រុងភ្នំពេញរាប់ម៉ឺននាក់ៗ ធ្វើបាតុកម្មវាយស្ពានទូតចក្រពត្តិអាមេរិក និងវាយមន្ទីរវប្បធម៌របស់ចក្រពត្តិអាមេរិក រហូតដល់ដេញទូតចក្រពត្តិអាមេរិកចេញពីប្រទេសកម្ពុជា ហើយបដិសេធជំនួយមានពិសពុលរបស់ចក្រពត្តិអាមេរិកទាំងអស់ ទាំងជំនួយយោធា សេដ្ឋកិច្ច

កងចល័តដឹកប្រជ្ញាយ

វប្បធម៌-សង្គមកិច្ច ។

ឯនៅជនបទវិញ ចលនាកសិករ តស៊ូប្រឆាំងសក្តិភូមិម្ចាស់ដី ប្រឆាំងរណ្តៅកាន់អំណាច ជាចៅហ្វាយខេត្ត ចៅហ្វាយស្រុក មេឃុំ ប៉ូលីស ទាហាន គិញ ទាមទារដីធ្លី ប្រឆាំងពន្ធដារនៃអង្គាសកំណែនកេណ្ឌកៀរក៏កាន់តែដុលដុស ។ល ។

កម្មាភិបាលដឹកនាំ កាន់តែចុះជនបទ ចុះជាប់ចលនា កសិករ ចុះជាប់ចលនាកម្មករ យុវជនសិស្ស ជំរុញចលនាជាប់ដុតភ្លើងបដិវត្តន៍ ភ្លើងកំហឹងប្រជាជាតិកំហឹងរណ្តៅនេះជាប់ជានិច្ច ។

ក្នុងចលនាក្តៅ ១៩៦៨-១៩៦៥-១៩៦៦នេះ បក្សបានកសាងជួរកម្មាភិបាលលេចធ្លាន់បានកាន់តែច្រើនកសាងអង្គការសម្ងាត់កាន់តែច្រើន ។ គោលជំហរនយោបាយ សតិអារម្មណ៍ចាត់តាំងរបស់បក្ស កាន់តែបានរឹងប៉ឹង ឯកភាពគ្នា ។ គោលជំហរឯករាជ្យ-ម្ចាស់ការ ខ្លួនខបត្តម្ភខ្លួន ខ្លួនកាន់កាប់វាសនាប្រទេសជាតិខ្លួនដោយខ្លួនឯង កាន់តែបានពង្រឹងជាក់ស្តែងក្នុងចលនាបដិវត្តន៍ ។

ឆ្នាំ១៩៦៧

សភាពការណ៍តស៊ូបដិវត្តន៍កាន់តែខ្លាំងក្លា ។ ការតស៊ូដោយហិង្សាអាវុធ បានផ្ទុះភ្លាមនៅជនបទ លេចធ្លោជាងគេគឺ «ព្រឹត្តការណ៍សំឡូត» ។ នៅទីក្រុង ចលនាបាតុកម្មមិទ្ទីង គាំទ្រចលនាតស៊ូរបស់ប្រជាជននៅជនបទ ប្រឆាំងពួកអាក្បត់ លន់ នល់ និងដៃដើងវា បានស៊ីសង្វាក់គ្នាជាធ្ងន់មួយ ឆ្ពោះឆ្ពើងពីទីក្រុងទៅជនបទ ពីជនបទទៅទីក្រុងទូទាំងប្រទេស ។ ប្រជាជន ជាពិសេសកសិករក្រ កសិករកណ្តាលថ្នាក់ក្រោម យល់ឃើញដោយខ្លួនគេច្បាស់លាស់ថា តស៊ូនយោបាយទេ មានតែខ្លាំងបង្ក្រាប ភាគត្បាត ចាប់ចង ដាក់គុកច្រវាក់ ទាល់តែបំពាក់អាវុធដែរ បានតស៊ូបានទាំងប្រជាជាតិទាំងប្រជាធិបតេយ្យ ។

ដូច្នោះ សភាពការណ៍ឆ្នាំ១៩៦៧ វាទុំខាងនយោបាយខាងចលនាតស៊ូបដិវត្តន៍របស់ប្រជាជន-មហាជន ខាងបំពាក់ហិង្សានយោបាយ និងអាវុធ ។

សរុបពិសោធន៍ មួយចំនួនសំខាន់នៃចលនាបដិវត្តន៍ប្រជាជាតិ-ប្រជាធិបតេយ្យពីឆ្នាំ១៩៦០-១៩៦៧ឃើញថា

១.មាគ៌ារបស់បក្ស

បក្សយើងកំណត់មាគ៌ាជាយុទ្ធសាស្ត្រនៃបដិវត្តន៍ប្រជាជាតិ-ប្រជាធិបតេយ្យ បានត្រឹមត្រូវ ហើយម្ចាស់ការក្នុងការដឹកនាំអនុវត្តន៍ ក្នុងរយៈកាលនីមួយៗបានជាក់ស្តែង ទៅតាមសភាពការណ៍ក្នុងហានៈវាយសម្រុកជាប់ជានិច្ច ។

យើងរួមជុំវិញការតស៊ូប្រជាជាតិ និងតស៊ូប្រជាធិបតេយ្យបានល្អ ទាំងខាងយុទ្ធសាស្ត្រ យុទ្ធវិធី ទាំងពាក្យស្លោកប្រចាំថ្ងៃ ។ ដូច្នោះប្រមូលកម្លាំងប្រជាជន-មហាជន បានបំផុសចលនាតស៊ូ

ជាន ទាំងប្រជាជាតិ-ប្រជាធិបតេយ្យ ហើយកម្ចាំងនេះធំទូលាយតែផ្លែកវែងបុំង លើកម្ចាំងសម្ព័ន្ធភាពកម្មករ-កសិករក្រោមការដឹកនាំរបស់បក្ស ។

២.សតិអារម្មណ៍របស់បក្ស

ចលនាខ្លាំងក្លា សតិអារម្មណ៍រីកចម្រើន ។ ស្មារតីស្នេហាជាតិបដិវត្តន៍ ដុលដុស ពុះកញ្ជ្រោលជាប់ជានិច្ច ។ សតិអារម្មណ៍វណ្ណៈ តស៊ូវណ្ណៈ ជាន់ពង្រឹងនិងពង្រីកថែម ។ ឃើញទំនាស់វណ្ណៈកាន់តែច្បាស់ រាល់ខែ រាល់ឆ្នាំ ។ ឃើញការប្រយុទ្ធវណ្ណៈកាន់តែច្បាស់ តឹងតែង ស្ងាប់ រស់ ទាំងក្នុងជួរបក្ស ទាំងក្នុងជួរប្រជាជន មហាជន ។ ដូច្នោះ គោលជំហរសតិអារម្មណ៍វណ្ណៈ និងតស៊ូវណ្ណៈ ជាន់ត្រូវសម្រួចឲ្យឡើងក្តៅគគុក ឆាបឆេះជានិច្ចទាំងក្នុងបក្ស ទាំងក្នុងប្រជាជន-មហាជន ដែលប្រយុទ្ធវាយសម្រុកជាប់ ហើយតាមការប្រយុទ្ធតទៅទៀតកាន់តែខ្លាំងក្លា ។

បក្សយើងជឿជាក់យ៉ាងច្បាស់លាស់ថា សតិអារម្មណ៍បដិវត្តន៍របស់កម្មាភិបាល-បក្ខជន ពុះពារយ៉ាងនេះ ធ្វើឲ្យយើងមានលក្ខណៈគ្រប់គ្រាន់ ដើម្បីប្រយុទ្ធនឹងខ្មាំងខ្លាំងក្លាក្តៅគគុកជាន ជាដាច់ខាត ។

៣.ចាត់តាំងរបស់បក្ស

មាគ៌ាច្បាស់លាស់ ជានសាកល្បងដកពិសោធន៍ខុសត្រូវក្នុងចលនា ។ សតិអារម្មណ៍ច្បាស់លាស់ ជានសាកល្បងដុតដំសាចុះសាឡើង ក្នុងចលនាក្តៅជាប់ជានិច្ច ។ ចាត់តាំងក៏ជានសាកល្បងពង្រឹងពង្រីកក្នុងចលនា ។ ការប្រយុទ្ធនាំឲ្យបក្ខជន-កម្មាភិបាលយល់ច្បាស់ជ្រួតជ្រាបនូវមាគ៌ា ក្តាប់មាគ៌ាជាប់ ឃើញខុស ឃើញត្រូវដោយច្បាស់លាស់ខ្លួនឯង ។ ដោយជានដុតដំសតិអារម្មណ៍ក្នុងចលនាតស៊ូក្តៅ ជាប់បក្សក៏សម្រិតសម្រាំងពួកស្មាក់ស្មើរពួកសារភាពខ្លាំងជានមួយចំនួន ។ ទន្ទឹមនឹងនេះជានពង្រឹង និងពង្រីកជួរកម្មាភិបាលចាស់-ថ្មីជានច្រើន ។ កម្មាភិបាលថ្មីនិងចាស់កសាងក្នុងចលនា មានទំនាស់ជាមួយខ្លាំងជាប់ជានិច្ច ។ សមមិត្តទាំងនេះត្រូវប្រយុទ្ធដោយហិង្សាជាមួយខ្លាំង ។ កម្មាភិបាលជាច្រើនចុះទៅជនបទ បំផុសបំផុលកសិករ រៀបចំចាត់តាំងកសិករឲ្យជានខ្លាំងក្លា គ្រប់ទីកន្លែង ពិសេសតាមជនបទចុងកាត់មាត់ញក ហើយក្នុងចលនានេះ ពង្រឹងពង្រីកជួរកម្មាភិបាល-បក្ខជនទៅជនបទថែមទៀត ។

កម្មាភិបាល-បក្ខជនល្អ ត្រង់ជាប់ចលនាប្រយុទ្ធក្នុងចលនាកសាងគោលជំហរ នយោបាយ សតិអារម្មណ៍ ចាត់តាំងក្នុងចលនាបន្ថែមសមត្ថភាពដឹកនាំក្នុងចលនាដោយដកពិសោធន៍ខុស-ត្រូវក្នុងចលនា ។

កម្មាភិបាល-បក្ខជនយើងទាំងអស់ឈរលើគោលជំហរនៃបដិវត្តន៍របស់បក្សខ្លួនច្បាស់លាស់ ឈរលើគោលជំហរឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន ជឿជាក់លើប្រជាជនខ្លួន លើចលនាខ្លួន លើការដឹកនាំរបស់បក្សខ្លួន ។ ឃើញចលនាតស៊ូត្រឹមត្រូវ ។ បើមិនប្រយុទ្ធ មិនតស៊ូនឹងចក្រពត្តិ សក្តិភូមិ និង នាយទុនប្រតិកិរិយាទេ គឺមុខជារាំរាយបដិវត្តន៍ឲ្យខ្ទេចខ្ទី ។ បើយើងមិនរាយរាំរាយយើងជាប់រាំមិនទុកឲ្យយើងនៅសុខទេ ។

ជាពិសេសទៀត ក្នុងចលនាតាំងពីឆ្នាំ១៩៦០ ដល់ឆ្នាំ១៩៦៧ អាស្រ័យតាមពន្លឺនៃមហាសន្និបាតបក្សទាំងពីរលើក និងអាស្រ័យតាមការពិសោធន៍នៃចលនាជាក់ស្តែង នៅក្នុងប្រទេសរបស់ខ្លួន បក្សយើងបានពង្រឹងគោលជំហរឯករាជ្យ-ម្ចាស់ការខ្លួនខបត្តមួយខ្លួន ខ្លួនកាន់កាប់វាសនាប្រទេសជាតិខ្លួនឯង បានថែមមួយកម្រិតទៀត លើសពេលមុនៗ ។ យើងមានជំនឿច្បាស់ណាស់ថា ប្រជាជនយើងខ្លាំងក្លា ។ បក្សយើង មានសមត្ថភាពដឹកនាំប្រជាជនទាំងជនបទ ទាំងទីក្រុង ។ យើងជឿជាក់ ហើយឃើញច្បាស់ថា ប្រជាជនយើងតស៊ូ ដោយហិង្សាជានយោបាយក៏បាន ដោយហិង្សាអាវុធក៏បាន ហើយជឿជាក់ថាវាយសម្រុកខ្លាំងតឿះ វាយសម្រុកជាបន្តបន្ទាប់បាន យកជ័យជម្នះជាបន្តបន្ទាប់បាន ។

ឆ្នាំ១៩៦៦-១៩៧០

១.ការបំផុសចលនាតស៊ូបដិវត្តន៍តាមមាគ៌ារបស់បក្ស

បក្សបានកំណត់ថា ត្រូវតស៊ូនយោបាយដង អាវុធដង ចាប់ពីឆ្នាំ១៩៦៨នេះទៅ ។ ដូច្នោះខែ១ ឆ្នាំ១៩៦៨ យើងផ្ទុះអាវុធនៅភូមិភាគពាយ័ព្យ (បាត់ដំបង) ។ ខែ២ ឆ្នាំ ១៩៦៨ នៅភូមិភាគនិរតី ។ ខែ៣ ឆ្នាំ១៩៦៨ នៅភូមិភាគបូព៌ ។ ចុងខែ៣ នៅភូមិភាគឥសាន ហើយក្នុងខែ៣ និងខែ៤ ឆ្នាំដដែលនៅភូមិភាគខុត្តរ ។

ហេតុនេះ នៅដើមឆ្នាំ១៩៦៨ មានការផ្ទុះអាវុធទូទៅ ។

គឺក្នុង១៩ខេត្ត យើងផ្ទុះអាវុធ១៧ខេត្ត ។

ក្នុងការតស៊ូនយោបាយដង អាវុធដងនេះ សភាពការណ៍សត្យានុម័តនៅលើពិភពលោកមិនអំណោយឲ្យយើងទេ ។ តែបក្សយើងជឿជាក់លើមាគ៌ារបស់ខ្លួន លើចលនារបស់ខ្លួន ហើយឃើញច្បាស់នូវលទ្ធភាពពង្រីកនិងពង្រីកចលនានេះបាន ។ ត្រង់នេះ នាំឲ្យផ្នែកក្នុងបក្សយើងពង្រឹងគោលជំហរ ជាមេរៀនជាបន្តបន្ទាប់ គឺថា កត្តាអត្តនោម័តិ ជាកត្តាសម្រេចជាមូលដ្ឋាន ត្រូវឈរលើគោលជំហរខ្លួនខបត្តម្ភខ្លួន ខ្លួនកាន់កាប់វាសនាខ្លួនដោយខ្លួនឯង ។ ន័យសំខាន់នៃខ្លួនខបត្តម្ភខ្លួន គឺផ្អែកលើកម្លាំងប្រជាជនឯងសំខាន់ដូច្នោះ យើងបំផុសបំផុលប្រជាជន នៅឆ្នាំ១៩៦៨ ធ្វើកុប្បកម្មដណ្តើមរដ្ឋអំណាចភូមិ-ឃុំពីខ្មាំង និងដណ្តើមអាវុធពីខ្មាំង ដើម្បីធ្វើសង្គ្រាមឈ្លបតទៅទៀត ។

ពេលនេះ កត្តាជាអត្តនោម័តិរបស់យើង គឺបក្សដឹកនាំប្រជាជនជាប់ស្មិត ។ មានមាគ៌ាត្រឹមត្រូវ សតិអារម្មណ៍ត្រឹមត្រូវ ការចាត់តាំងត្រឹមត្រូវ ។ កម្មាភិបាលមជ្ឈិមបក្ស ឯកភាពគ្នាជាធ្ងន់មួយគ្រប់ភូមិភាគ ។ ប្រជាជនដុសដុលខ្មាំងក្លាដោយហិង្សានយោបាយ និងហិង្សាអាវុធ ។ ដូច្នោះ ពិតមែនតែសភាពការណ៍សកលលោកមិនអនុគ្រោះឲ្យយើងក្តី យើងខ្វះខាតទាំងសព្វទាំងគ្រប់ក្តី ក៏យើងវាយខ្មាំងបានយ៉ាងខ្លាំងក្លា ធ្វើឲ្យពួកវាត្រូវរត់ខ្ចាត់ខ្ចាយ ។

២.សតិអារម្មណ៍របស់បក្ស

សតិអារម្មណ៍របស់បក្ស ផ្នែកក្នុងកងទ័ព ផ្នែកក្នុងប្រជាជនលះបង់ប្រយុទ្ធដាច់ខាត ហើយប្រយុទ្ធខ្មាំងក្លាណាស់ ។ គេកាន់តែឃើញច្បាស់ថា ខ្លួនត្រូវខបត្តម្ភខ្លួន ខ្លួនត្រូវកាន់កាប់វាសនាខ្លួនដោយខ្លួនឯង ។

យើងបន្តប្រយុទ្ធនយោបាយនៅភ្នំពេញ និងទីក្រុងផ្សេងៗ ។ ជនបទក៏បន្តតស៊ូនយោបាយនិងអាវុធ ។ យើងតស៊ូទាំងពីរបែបភាពដើម្បីរួមដៃវាយខ្មាំង ។ ទីក្រុងតស៊ូនយោបាយតទៅទៀត ហើយបំពាក់អាវុធសម្រាប់ការពារខ្លួន ។ ឯជនបទបំផុសបំផុលចលនាកសិករឲ្យតស៊ូនយោបាយដង និងតស៊ូអាវុធដង ។ ទន្ទឹមនឹងនេះ បក្សបំផុសធ្វើសង្គ្រាមឈ្លបពាសពេញដោយប្រើអាវុធបូរាណរួមដៃនឹងអាវុធសម័យ ។ ពេលនោះវណ្ណៈកាន់អំណាចវាប្រកាសថា វាយខ្មែរក្រហមឲ្យលៀនអណ្តែត ។ ពួកវាប្រមូលកម្លាំងទាំងអស់ទៅវាយយើង ។ មេទ័ពទាំងអស់របស់ខ្មាំងតាំងពី លន់ នល់ ជូឡុង និងពួកមេបញ្ជាការធំៗវាទាំងអស់ទៅវាយយើង ។ តែផ្ទុយទៅវិញ មិនគ្រាន់តែវាទប់ទល់យើងមិនបាន យើងថែមទាំងពង្រីកនិងពង្រីកតំបន់រំដោះពេលនោះ បានដាបណ្តើរៗទៀតដង ។ ការលំបាករបស់យើង ក៏មានច្រើនដែរ ។ ប៉ុន្តែមិនសារភាពខ្មាំងពីព្រោះការងារនយោបាយ ការងារ សតិអារម្មណ៍ បានត្រូវអប់រំជាប់ ។ បក្សយើងក្តាប់ជាប់ទាំងផ្នែកក្នុងបក្ស ទាំងផ្នែកក្នុងប្រជាជន ។ អញ្ចឹងហើយ បានជាសតិអារម្មណ៍រឹងប៉ឹង ប្រយុទ្ធដាច់ខាតទ្រាំទ្រលំបាកវេទនា ។ ការពិសោធន៍កន្លងមកឃើញថា បក្សបានលត់ដំក្នុងចលនា ក្នុងភ្លើងសង្គ្រាមបានឯកភាពគ្នាជាធ្ងន់មួយ ហើយប្រយុទ្ធសម្រុកជាធ្ងន់មួយ ។ ពិសោធន៍មួយទៀត គឺជាប្រជាជនមូលដ្ឋានទ្រាំទ្រលំបាកវេទនាមែនទែន ។ បើប្រជាជនស្រទាប់កណ្តាលនិងស្រទាប់លើមិនអាចទ្រាំទ្រដូច្នោះបានទេ ។ ការនេះនាំឲ្យយើងរឹតតែជឿជាក់លើមាគ៌ាចាត់តាំងរបស់បក្ស ដែលផ្អែកលើមាគ៌ាវណ្ណៈរបស់បក្ស និងលើចលនាបដិវត្តន៍ ។

៣.ចាត់តាំងរបស់បក្ស

បក្សយើងបានពង្រឹងនិងពង្រីកកម្លាំងគ្រប់ផ្នែកបានជាច្រើន ក្នុងរយៈកាលពីរឆ្នាំប៉ុណ្ណោះ ។ មូលដ្ឋាននយោបាយនៅក្នុងប្រជាជនទៅជនបទបានរីកធំធាត់ ព្រមទាំងមូលដ្ឋានបង្កែកនៅជនបទ ទូទាំងប្រទេសក៏បានពង្រឹង និងពង្រីកថែម ។ ឯកងទ័ពបដិវត្តន៍រីកធំធាត់ ។ កន្លែងខ្លះ ចាត់តាំងជាកងអនុសេនាធំហើយនៅដើមឆ្នាំ១៩៧០ ។ កងទ័ពនេះ មានសមត្ថភាពវាយ និងទប់ទល់ខ្មាំងបាន ។ ខ្មាំងវាទៅរកតស៊ាត ច្រើនកងវរសេនាតូច ក៏កងទ័ពបដិវត្តន៍យើងទប់ទល់បាន ថែមទាំងវាយខ្មាំងឲ្យបរាជ័យជាបន្តបន្ទាប់ទៀត ។

ដូច្នោះ រយៈកាលឆ្នាំ១៩៦៨ ដល់ដើមឆ្នាំ១៩៧០ បក្សបានរឹងនិងរីកថែម ប្រជាជន ក៏រឹងនិងរីកថែម កងទ័ព ក៏បានរឹងនិងរីកថែម មូលដ្ឋានបង្កែកក៏បានរឹងនិងរីកថែម ។

សភាពការណ៍បដិវត្តន៍យើងកំពុងរីកលូតលាស់យ៉ាងនេះស្រាប់តែមានផ្ទុះរដ្ឋប្រហារភ្លាមនៅថ្ងៃ១៨ ខែ៣ ឆ្នាំ១៩៧០ ។

(ឯកសារD២១៤១២)

ចម្លើយសារភាព យង់ ពៅ ប្រធានសន្តិសុខតំបន់១០៦

ដកស្រង់ចេញពីចម្លើយសារភាព

យង់ ពៅ ជាប្រធានសន្តិសុខ តំបន់១០៦ សៀមរាប។ យង់ ពៅ ត្រូវបានចាប់ខ្លួនដោយសារជាប់ទាក់ទងនឹងការកសាងកម្លាំងស្នូលដើម្បីទុកបម្រើសកម្មភាពក្បត់ និងផែនការ សេ.អ៊ី.អា និងរៀបចំអនុវត្តផែនការរដ្ឋប្រហារ។

នៅក្របមុខនៃចម្លើយសារភាព មានសរសេរថា ផែនការលាក់នាយទាហានរបស់ ស្រេង ភាគខ្តួរ និងមានចំណារថា ជូនអង្គការពីរច្បាប់ មិនទាន់អាន។ ជូនសមមិត្ត ពត ១ច្បាប់។

រូបថតអ្នកទោសនៅមន្ទីរ ស-២១

ចម្លើយសារភាព យង់ ពៅ មានចំនួនដប់ទំព័រ ដោយមានឈ្មោះ អឿន ឡោត ជាអ្នកសួរចម្លើយ។ នៅក្នុងចម្លើយសារភាពនេះបានសរសេររៀបរាប់អំពីទីមួយ) បញ្ជីរាយនាមបក្សពួកក្បត់ខាងភូមិភាគខ្តួរ ដែលរួមមាន ១) ស្រេង អនុលេខាភូមិភាគពាយ័ព្យ ២) ឈានគណៈស្រុកបាធាយ ៣) ស៊ុនគណៈស្រុកស្វាយ ៤) រុនគណៈស្រុកសន្ទុក និង ទីពី) បញ្ជីរាយនាមទាហានដែលលាក់ទុកនៅខាងភូមិភាគខ្តួរ។ យង់ ពៅ បានសរសេរពីសកម្មភាពដូចខាងក្រោម:

នៅក្រោយពេលរំដោះទូទាំងប្រទេស នៅខែឧសភា ឆ្នាំ ១៩៧៥ ខ្ញុំបានសរសេរសំបុត្រមួយច្បាប់ ជម្រាបសមមិត្ត ស្រេង អំពីបងថ្លៃរបស់ខ្ញុំឈ្មោះ អាន ហៅអ៊ុក សូដនទាហានសក្តិបី ដើម្បីឲ្យ ស្រេង ជួយស្រាវជ្រាវរកនៅក្នុងចំណោមប្រជាជនជម្លៀសទាំងអស់ ក្នុងគោលបំណងយកបងថ្លៃខ្ញុំមករស់នៅតំបន់ ១០៦ ខេត្តសៀមរាប រួចហើយប្រមូលកម្លាំងបក្សពួកក្បត់ ដើម្បីរៀបចំអនុវត្តផែនការរដ្ឋប្រហារ។

សមមិត្ត ស្រេង បានស្រាវជ្រាវរកឃើញបងថ្លៃខ្ញុំ ហើយបានផ្ញើទុកក្នុងមូលដ្ឋានភូមិព្រែកលើវ សង្កាត់កងតាណឹង ស្រុក

បម្រើសកម្មភាពក្បត់ និងដែនការ សេ.អ៊ី.អា នៅភូមិភាគខត្តរ ។

ក្រោយពី ស្រេង ទទួលសំបុត្ររួច គាត់ខ្នះខ្នែងតាមដានស្រាវជ្រាវរកឈ្មោះនាយទាហានទាំងនេះនៅគ្រប់ស្រុកទាំងអស់ រួចហើយបានសរសេរសំបុត្រមួយច្បាប់មកខ្ញុំវិញ ដោយបញ្ជាក់ថា សោម សារ៉ាន់ លាក់ទុកនៅភូមិដ្ឋារ សង្កាត់ដ្ឋារ ស្រុកបាធាយ តំបន់៨១ តាមរយៈសមមិត្ត ឈាន គណៈស្រុកបាធាយ ។ ស៊ឹម ញឹម លាក់ទុកនៅភូមិបន្ទាយជ័យ សង្កាត់បន្ទាយជ័យ ស្រុកស្នោង តំបន់៨៣ (កំពង់ធំ) តាមរយៈសមមិត្ត ស្រ៊ុន គណៈស្រុកស្នោង ។ ម៉ៅ ដល លាក់ទុកនៅភូមិគ្រាច សង្កាត់គ្រាច ស្រុកស្នោង តាមរយៈសមមិត្ត ស្រ៊ុន គណៈស្រុកស្នោង ។ នួ លឹម លាក់ទុកនៅភូមិតាំងក្រសៅ សង្កាត់តាំងក្រសៅ ស្រុកសន្ទុក តំបន់៨៣ តាមរយៈសមមិត្តរុន គណៈស្រុកសន្ទុក ។

បន្ទាប់ពីខ្ញុំក្លាប់បានកន្លែងរស់នៅរបស់នាយទាហានទាំងនោះហើយ ក្នុងខែមេសា ឆ្នាំ១៩៧៦ ខ្ញុំបានទៅជួបទាក់ទងសមមិត្ត ស្រ៊ុន ហើយបានជម្រាបគាត់ពីឈ្មោះ ស៊ឹម ញឹម និង ម៉ៅ ដល ដើម្បីឲ្យគាត់យកចិត្តទុកដាក់ណែនាំ និងអប់រំដែរ ។ ឆ្លងតាមការជួបពិភាក្សា ខ្ញុំនិងសមមិត្ត ស្រ៊ុន បានឯកភាពលើទស្សនៈក្បត់ហើយឆ្លៀតពេលនោះ ខ្ញុំបានស្នើសមមិត្ត ស្រ៊ុន សុំជួបឈ្មោះទាំងពីរនាក់នោះដើម្បីជំរុញឲ្យចូលរួមការងារក្បត់ និងវាយរំលំរដ្ឋអំណាចបដិវត្តន៍ ។ បន្ទាប់មក ខ្ញុំក៏លាសមមិត្ត ស្រ៊ុន ត្រឡប់មកខេត្តសៀមរាបវិញ ។

ក្នុងខែកក្កដា ឆ្នាំ១៩៧៦ ខ្ញុំមានភារកិច្ចទៅតាមដានប្រវត្តិរូបមិត្តយើងនៅក្នុងក្រសួងសន្តិសុខតំបន់១០៦ ។ ឆ្លៀតពេលនោះ ខ្ញុំបានទៅស្រុកបាធាយក្នុងគោលបំណងទាក់ទងសមមិត្ត ឈាន ជាគណៈស្រុក ដើម្បីពិភាក្សាពីបញ្ហាលាក់ទុកឈ្មោះ សោម សារ៉ាន់ ។ ខ្ញុំបានជម្រាបគាត់ឲ្យជួយកសាង សារ៉ាន់ ដើម្បីបង្កប់ស៊ីរូងនៅក្នុងសហករណ៍ និងបំដិចបំដាញសហករណ៍ ។ បន្ទាប់មក ខ្ញុំទៅជួប សារ៉ាន់ និងបានអប់រំគាត់ឲ្យចូលរួមសកម្មភាពក្បត់នៅក្នុងមូលដ្ឋាន ដើម្បីបម្រើដែនការ សេ.អ៊ី.អា ទៀត ។

ក្រោយពីអប់រំ សារ៉ាន់ រួចខ្ញុំក៏បន្តដំណើរទៅស្រុកកងមាសទៀត ដើម្បីជួបទាក់ទងជាមួយសមមិត្ត ស្រេង ដើម្បីពិភាក្សាពីការលាក់ទុកនាយទាហាន ។ សមមិត្ត ស្រេង បានបញ្ជាក់ថា ចំពោះនាយទាហានទាំងនោះ គាត់បានផ្ញើទុកនៅក្នុងមូលដ្ឋានស្រួលបួលហើយ ហើយកំពុងធ្វើសកម្មភាពបណ្តើរៗនៅក្នុងសហករណ៍ដោយលាក់ការណ៍សម្ងាត់ ។ ក្រៅពីនោះ សមមិត្ត ស្រេង បានជំរុញឲ្យខ្ញុំខិតខំយកចិត្តទុកដាក់ពង្រីកសកម្មភាពក្បត់ និងអនុវត្តដែនការក្បត់ថែមទៀត ។

បន្ទាប់ពីជួបសមមិត្ត ស្រេង រួច ខ្ញុំក៏ធ្វើដំណើរទៅបំពេញភារកិច្ចតាមដានប្រវត្តិរូប រួចហើយខ្ញុំក៏បានវិលត្រឡប់មកខេត្តសៀមរាបវិញ ។

នៅទំព័រចុងក្រោយនៃចម្លើយសារភាព យង់ ពៅ បានសរសេរថា :

ជុំវិញរឿងលាក់ទាហានទាំងនេះ ខ្ញុំបានចូលរួមសកម្មភាពយ៉ាងខ្លាំងក្លា និងយកចិត្តទុកដាក់ទាក់ទង តាមដានសភាពការណ៍បន្តបន្ទាប់ ដោយមានបំណងការពារកម្លាំងនេះទុកជាកម្លាំងស្នូល ដើម្បីបម្រើខុបាយកល និងដែនការក្បត់នៅពេលចំពោះមុខយួរអង្រែង និងបង្កប់ស៊ីរូងនៅក្នុងសហករណ៍ឲ្យវិនាសអន្តរាយ ។

គួរពុំគួរសូមអង្គការមេត្តាអធ្យាស្រ័យដល់យើងខ្ញុំ ។ ចម្លើយសារភាពនេះចុះកាលបរិច្ឆេទថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៧៧ ដោយមានហត្ថលេខា និងស្នាមដិតមេដៃរបស់អ្នកទោស យង់ ពៅ ។

សោម ប៊ុនថន

រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខ: (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខ: (៨៥៥) (១៦) ៨៧៦ ៦៩២

ទូរសារលេខ: (៨៥៥) (២៣) ២១០ ៣៥៨

Email: truthsocheat@dccam.org

Home page: www.dccam.org

សក្ខីកម្ម ឌុច ប្រឆាំងនឹងមេដឹកនាំខ្មែរក្រហម

សក្ខីកម្មថ្ងៃទីប្រាំ (ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២)

សវនាការពេលព្រឹក

នៅព្រឹកថ្ងៃអង្គារ ទី២៧ ខែមីនា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបន្តស្តាប់សក្ខីកម្ម ឌុច ដូចសព្វមួយដង។ លោក វីលៀម ស៊ឺត សហព្រះរាជអាជ្ញារង៍អន្តរជាតិបានជម្រាបអង្គជំនុំជម្រះថាលោកនឹងដាក់ឯកសារមួយចំនួនដើម្បីចោទសួរសាក្សី ឌុច។ ជាដំបូង វីលៀម ស៊ឺត បានដាក់ឯកសារប្រវត្តិរូបអ្នកទោសនៅមន្ទីរស-២១ ដែល ឌុច បានអះអាង និងបញ្ជាក់ដោយថ្លែកថាសម្រាប់អ្នកទោសពិសេស មិនមានការកត់ត្រាថ្ងៃចាប់ខ្លួន ឬរូបថតទេ ពីព្រោះវាគឺជាគោលការណ៍របស់ថ្នាក់លើក្នុងការរក្សាការសម្ងាត់ដើម្បីចៀសវាងភាពចលាចលក្នុងចំណោមឆ្មាំងដែលជាប់ពាក់ព័ន្ធនឹងអ្នកទោសពិសេសនោះ។ លោក វីលៀម ស៊ឺត បានឲ្យ ឌុច បកស្រាយខ្ទឹមសារពាក្យ «ចម្ងើយសារភាព»។ ឌុច បានឆ្លើយតបថា «ចម្ងើយសារភាពគឺជាចម្ងើយនៃសំណួរដែលសួរទៅកាន់អ្នកទោស»។ ភាគច្រើនចម្ងើយទាំងនោះទាញចេញដោយសារការធ្វើទារុណកម្ម។ ប៉ុន្តែ ឌុច បានបញ្ជាក់ថា ថ្នាក់លើបានចេញបញ្ជាយ៉ាងច្បាស់លាស់ថាអ្នកទោសទាំងអស់ត្រូវទទួលទារុណកម្ម លើកលែងតែ កុយ ធួន ម្នាក់ប៉ុណ្ណោះ។ ឌុច បានបន្តទៀតថាកាលពីមុនការសួរចម្ងើយត្រូវបានចាត់ជាសម្ងាត់ ប៉ុន្តែក្រោយមកត្រូវបានសរសេរលើក្រដាសដោយដៃ បន្ទាប់ពីមានការចេញបញ្ជាពី នួន ជា ពីព្រោះ នួន ជា ចូលចិត្តអានជាងស្តាប់។ ឌុច បានអះអាងចំពោះមុខអង្គជំនុំជម្រះថា គោលបំណងសំខាន់របស់មន្ទីរស-២១គឺទាញយកចម្ងើយសារភាពដើម្បីបញ្ជូនឲ្យថ្នាក់លើបក្សកុម្មុយនីស្តកម្ពុជា។ ឌុច បានបញ្ជាក់ថា រាល់ចម្ងើយសារភាពទាំងអស់ត្រូវឆ្លងកាត់ការអានរបស់ ឌុច ជាមុនសិន។ ជាពិសេស កាលណាចម្ងើយសារភាពណាមួយមានចំណាររបស់ សុន សេន នោះមានន័យថាចម្ងើយសារភាពនោះត្រូវបានចម្លងជូន «បង នួន» ឬ នួន ជា។ ជាទូទៅ ក្រោយពីផ្តល់ចម្ងើយសារភាពហើយ អ្នកទោសត្រូវបានសម្លាប់ចោល។ បន្ទាប់មកទៀត សហព្រះរាជអាជ្ញារង៍អន្តរជាតិក៏បានដាក់គម្របទស្សនាវដ្តីទង់បដិវត្តដើម្បីសួរសំណួរទៅ ឌុច។ ឌុច បានឆ្លើយតបថា ទស្សនាវដ្តីទង់បដិវត្តនេះត្រូវបានចាត់ទុកជា «ឯកសារផ្ទៃក្នុងរបស់បក្សកុម្មុយនីស្តកម្ពុជា» ដែលត្រូវបានបោះពុម្ព និងចែកជូនអង្គភាពនីមួយៗដើម្បីអប់រំអ្នកនៅក្រោមបង្គាប់។ ជាការឆ្លើយតបនឹងការដាក់ឯកសារថ្មីមួយទៀត ឌុច បានអះអាងថា ឯកសារនោះមិនមែនរៀបរៀងឡើងដោយបុគ្គលិកមន្ទីរស-២១ឡើយ ប៉ុន្តែបានបញ្ជាក់ថា ឌុច បានចារនៅលើចម្ងើយសារភាពនេះបង្គាប់ឲ្យលុបឈ្មោះអ្នកទោសមួយចំនួនចេញពីចម្ងើយសារភាពនេះ។ ខណៈពេលដែលសហព្រះរាជអាជ្ញារង៍អន្តរជាតិបានសួរ ឌុច ថាតើនរណាជាអ្នកបង្គាប់ ឌុច ឲ្យលុបឈ្មោះទាំងនេះ ឌុច បានបញ្ជាក់ថា នួន ជា គឺជាអ្នកចេញសេចក្តីបង្គាប់បែបនេះ ហេតុដូច្នេះហើយបានជាមានកំណត់ត្រាឈ្មោះ នួន ជា ក្នុងចម្ងើយសារភាពនោះ។

ក្រោយពីសម្រាកពេលព្រឹកមួយរយៈ លោក វីលៀម ស៊ឺត បានបន្ត សួរ ឌុច ថាហេតុអ្វីបានជាមានការលុបឈ្មោះចេញពីចម្ងើយសារភាព។ ឌុច បានបកស្រាយថា ការលុបឈ្មោះចេញនេះគឺដើម្បីរក្សាការសម្ងាត់ និងធានាថា អ្នកទោសនោះមិនដឹងថាបក្សកុម្មុយនីស្តកម្ពុជាកំពុងតែតាមដានទេ។ បន្ទាប់មកទៀត សហព្រះរាជអាជ្ញារង៍អន្តរជាតិបានសួរសំណួរ ឌុច មួយចំនួនទាក់ទងនឹងទំនាក់ទំនងរវាង ឌុច និង សុន សេន។ ឌុច បានរៀបរាប់ថា គាត់បានជួបពិភាក្សាជាមួយនឹង សុន សេន រៀងរាល់ចុងថ្ងៃម្តងរហូតដល់ពាក់កណ្តាលខែកក្កដា ឆ្នាំ១៩៧៧ ទើប ឌុច ចាប់ផ្តើមរាយការណ៍ជូន នួន ជា ផ្ទាល់ក្រោយពីបានជួបប្រជុំ និងទទួលបានសេចក្តីបង្គាប់ដូច្នេះពី នួន ជា។ ពេលដែលសួរពីរបៀបវារៈនៃអង្គប្រជុំនោះ ឌុច បានបកស្រាយថា ថ្នាក់លើ និង ឌុច បានពិភាក្សាពីបញ្ហាដំណើរការទូទៅរបស់មន្ទីរស-២១ និងបញ្ហាចោទសំខាន់ៗមួយចំនួន។ មុនពេល នួន ជា ទៅប្រទេសចិន ឌុច

តែងតែទៅជួប និងរាយការណ៍ជូន នួន ជា រៀងរាល់បីថ្ងៃម្តង។ ប៉ុន្តែក្រោយពេល នួន ជា ត្រឡប់ពីប្រទេសចិនវិញ ខុច បានជួបជាមួយនឹង នួន ជា រៀងរាល់ប្រាំថ្ងៃម្តងវិញ។ ខុច បាននិយាយបន្តមទៀតថា ថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា បានកំណត់ពីអត្តសញ្ញាណអ្នកទោសសំខាន់ៗឲ្យមន្ទីរស-២១ ដូច្នេះ ខុច ត្រូវតាញយកចម្លើយសារភាពពីអ្នកទោសនោះឲ្យទាល់តែបាន ហើយរាយការណ៍ជូនថ្នាក់លើដោយប្រុងប្រយ័ត្នបំផុត។ ខុច បានបញ្ជាក់ថា មានម្តងនោះក្នុងចម្លើយសារភាពរបស់អ្នកទោសសំខាន់ម្នាក់មានជាប់ពាក់ព័ន្ធនឹងសមាជិកគ្រួសាររបស់ អៀង សារី និង ខៀវ សំផន។ ប៉ុន្តែឈ្មោះរបស់បុគ្គលទាំងពីរនោះត្រូវបានលុបចេញ។ ខុច បានបន្តែមថា គោលបំណងសំខាន់នៃការជួបជាមួយនឹង នួន ជា គឺដើម្បីរាយការណ៍ជូនគាត់ពីស្ថានភាពទូទៅរបស់មន្ទីរស-២១ ដើម្បីទទួល «សេចក្តីបង្គាប់ផ្ទាល់ផ្សេងៗ» ពី នួន ជា។

សវនាការពេលរសៀល

បន្ទាប់មកទៀត លោក វីលៀម ស្មីត បានជម្រាបអង្គជំនុំជម្រះថា លោកនឹងផ្ញាស់ប្តូរប្រធានបទមកសួរសាកសួរពី

វីលៀម ស្មីត

ស្ថាប័នរដ្ឋាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យវិញ។ ឆ្លើយតបនឹងសំណួរថាតើមានបក្សនយោបាយប៉ុន្មានក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខុច បានអះអាងថាមានតែ «អង្គការ» មួយគត់ដែលគ្រប់គ្រងរាល់វិស័យទាំងអស់ក្នុងប្រទេសកម្ពុជា។ ខុច បានបន្តែមទៀតថា បក្សកុម្មុយនីស្តកម្ពុជាជាអ្នកចេញសេចក្តីសម្រេច ហើយមាគ៌ានយោបាយរបស់បក្សកុម្មុយនីស្តមិនទទួលឥទ្ធិពលពីមជ្ឈដ្ឋាន ឬស្ថាប័ណាមួយឡើយ។ បន្តែមលើនេះ គ្រប់ស្ថាប័ន ឯកជនដូចជាសាលារៀន មន្ទីរពេទ្យ និងមធ្យោបាយដឹកជញ្ជូនសុទ្ធតែឋិតនៅក្រោមការគ្រប់គ្រងដាច់រលាស់របស់ថ្នាក់ដឹកនាំនៃបក្សកុម្មុយនីស្តកម្ពុជាទាំងអស់។ ក្រោយពីទទួលបានជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ សមាជិកបក្សកុម្មុយនីស្តកម្ពុជាត្រូវបានកោះហៅមកចូលរួមប្រជុំ និងស្តាប់សេចក្តីប្រកាសរដ្ឋធម្មនុញ្ញនៃរបបកម្ពុជាប្រជាធិបតេយ្យ។ សេចក្តីប្រកាសរដ្ឋធម្មនុញ្ញនេះត្រូវបានផ្សព្វផ្សាយតាមវិទ្យុ។ បើទោះបីជាដឹងមិនសូវច្បាស់ ខុច បានសន្និដ្ឋានថា រដ្ឋធម្មនុញ្ញនេះត្រូវបានរៀបរៀងឡើងដោយ ប៉ុល ពត ឬ នួន ជា។ លើសពីនេះ លោក វីលៀម ស្មីត បានសួរ ខុច ថាតើ ខុច បានដឹងពីដំណើរការបោះឆ្នោតជ្រើសរើស «សមាជិករដ្ឋសភាជាតិ» ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ។ ខុច បានឆ្លើយតបវិញថា គាត់ស្គាល់តែស្ថានីយបោះឆ្នោតមួយដែលមានទីតាំងនៅទួលគោក ទីក្រុងភ្នំពេញតែប៉ុណ្ណោះ ហើយគាត់មិនបានដឹងថាតើមានស្ថានីយបោះឆ្នោតសរុបប៉ុន្មានទេ។ ខុច បានអះអាងថា នួន ជា គឺជាអ្នកទទួលបន្ទុកមើលការខុសត្រូវលើស្ថានីយបោះឆ្នោតនោះ។ ជាគោលការណ៍ សមាជិករដ្ឋសភាត្រូវបានបោះឆ្នោតជ្រើសតាំងជាសមាជិកពេញសិទ្ធិ ប៉ុន្តែដាក់ស្នើការបោះឆ្នោតនេះគឺគ្រាន់តែជាការបន្ទាំតែប៉ុណ្ណោះ ពីព្រោះមានតែថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាតែប៉ុណ្ណោះដែលមានអំណាចសម្រេចតែងតាំងសមាជិករដ្ឋសភា។ ខុច បានបន្តែមទៀតថាសមាជិករដ្ឋសភាជាច្រើននាក់ត្រូវបានចាប់ខ្លួនបញ្ជូនមកមន្ទីរស-២១។ ខុច បានគូសបញ្ជាក់ថា «ក្រុមប្រឹក្សារដ្ឋ» ក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺជា «ស្ថាប័ននិមិត្តរូប» តែប៉ុណ្ណោះដែលគ្មានអំណាច និងគ្មានសូម្បីតែការិយាល័យធ្វើការ។ ខុច បានអានផ្នែកមួយនៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យថា

ប្រជាជនប្រុសស្រីមានសិទ្ធិស្មើគ្នា និងទទួលបានសិទ្ធិនេះដូចៗគ្នា ។ ខុច បានរិះគន់ថា តាមពិតទៅគោលការណ៍នៃរដ្ឋធម្មនុញ្ញនេះមិនត្រូវបានអនុវត្តឲ្យត្រឹមត្រូវទេ ។ ជាឧទាហរណ៍ មានការបែងចែករវាង «ប្រជាជនថ្មី» និង «ប្រជាជនមូលដ្ឋាន» ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ទាក់ទងនឹងគណៈមជ្ឈិមបក្ស ខុច បានអះអាងថា ក្នុងជួរគណៈមជ្ឈិមមានសមាជិកចំនួនប្រាំពីរនាក់រួមមាន : ប៉ុល ពត, នួន ជា, សោ ភឹម, តា ម៉ុក, អៀង សារី, សុន សេន និង វ៉ន វ៉ែត ។ ខុច បានជម្រាបអង្គជំនុំជម្រះថា ខុច បានដឹងពីសមាសភាពសមាជិកគណៈមជ្ឈិមតាមរយៈ ប៉ង់ ជាសមាជិកបក្សកុម្មុយនីស្តម្នាក់ដែលចង់ក្លាយជាសមាជិកគណៈមជ្ឈិមដែរ ។ ក្រោយមកទៀត ខុច បានសួរ កុយ ធួន ពីសមាសភាពសមាជិកគណៈមជ្ឈិមដូចគ្នានឹងអ៊ីដែល ប៉ង់ បានប្រាប់ ខុច ដែរ ។ ដោយឡែក ខុច បាននិយាយបន្ថែមទៀតថា ក្នុងចំណោមអ្នកទោសទាំងអស់មានតែ កុយ ធួន ម្នាក់ប៉ុណ្ណោះដែលមិនត្រូវបានធ្វើទារុណកម្ម ។

ក្រោយពីសម្រាកពេលរសៀល លោក វីលៀម ស្មិត បានសួរ ខុច ពីអំណាចរបស់ថ្នាក់លើក្នុងគណៈមជ្ឈិមបក្ស ។ ខុច បានរៀបរាប់ថា ក្នុងជួរគណៈមជ្ឈិមមានការបែងចែកអំណាចជាបួនលំដាប់ : ជំនួយការសមាជិកគណៈមជ្ឈិម, បេក្ខជនគណៈមជ្ឈិម, សមាជិកគណៈមជ្ឈិមពេញសិទ្ធិ និងសមាជិកគណៈអចិន្ត្រៃយ៍ដែលជាអ្នកមានអំណាចខ្ពស់ជាងគេបំផុត ។ ទាក់ទងនឹងគណៈអចិន្ត្រៃយ៍ ខុច បានបញ្ជាក់ថា គ្រប់សមាជិកគណៈអចិន្ត្រៃយ៍ទាំងអស់សុទ្ធតែមានស្ថាប័នទទួលបន្ទុករៀងៗខ្លួន ។ ជាក់ស្តែង អៀង សារី បានទទួលការខុសត្រូវផ្នែកទំនាក់ទំនងរវាងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យជាមួយនឹងប្រទេសសង្គមនិយមផ្សេងទៀត ។ យ៉ាងណាមិញ ខុច នៅតែអះអាងថាអំណាចទាំងអស់គឺបិតក្នុងដៃរបស់ ប៉ុល ពត ប៉ុន្តែក្នុងករណីដែល ប៉ុល ពត មិនអាចចេញសេចក្តីសម្រេចណាមួយបាននោះ នួន ជា នឹងចេញបញ្ជាជំនួស ។ បន្ទាប់មកទៀត លោក វីលៀម ស្មិត បានចោទសួរ ខុច ទាក់ទងនឹងសេចក្តីសម្រេចរបស់គណៈមជ្ឈិម និងសិទ្ធិក្នុងការ «កម្ទេច» អ្នកទោស «ក្នុងនិងក្រៅ» បក្សកុម្មុយនីស្តកម្ពុជា និងសួរថាតើក្រោយថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ការកម្ទេចបានកើនឡើងដែរឬយ៉ាងណា ។ ខុច បានឆ្លើយថា មុនថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ បក្សកុម្មុយនីស្តកម្ពុជាមានគោលការណ៍កម្ទេចតែខ្លាំង «ក្រៅបក្ស» តែប៉ុណ្ណោះ ប៉ុន្តែក្រោយមកទៀតមានការចាប់ខ្លួន និងសួរចម្ងើយសមាជិកបក្សជាបន្តបន្ទាប់ ។

សកម្មថ្ងៃទីប្រាំមួយ (ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២)

សវនាការពេលព្រឹក

កុយ ធួន (រូបឈរកណ្តាល) និងកម្មាភិបាលខ្មែរក្រហម

នៅព្រឹកថ្ងៃពុធ ទី២៨ ខែមីនា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានដំណើរការនីតិវិធី ដោយការធ្វើសក្ខីកម្មរបស់ ខុច បន្តទៀត ។ លោក វីលៀម ស្មិត បានបន្តចោទសួរ ខុច ពីបញ្ហាដែលបានលើកឡើងក្នុងសវនាការកាលពីម្សិលមិញ ។ ខុច បានឆ្លើយតបថា មន្ទីរស-២១ បានចាប់ផ្តើមដំណើរការក្រោយថ្ងៃជ័យជម្នះ១៧ មេសា ឆ្នាំ១៩៧៥ ហើយត្រូវបានបញ្ជាឲ្យបិទដោយ នួន ជា នៅម៉ោងប្រាំបួនព្រឹកថ្ងៃទី៣ មករា ឆ្នាំ១៩៧៩ ។ ខុច បានបន្ថែមទៀតថា គណៈអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជាមានទីតាំងនៅទីក្រុងភ្នំពេញ ដូច្នេះអំណាចក្រោមរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានបែងចែកជាភូមិភាគ ។ ខុច បានពន្យល់ថា គោលការណ៍នេះគឺបង្កើតឡើងដើម្បីឲ្យគណៈអចិន្ត្រៃយ៍គ្រប់គ្រងសភាពការណ៍

តាមភូមិភាគដាល់ ។ ដោយឡែក តាមភូមិភាគនីមួយៗមានគណៈអចិន្ត្រៃយ៍ដែលមានលេខាភូមិភាគទទួលបន្ទុកគ្រប់គ្រងភូមិភាគដាល់ ។ ក្នុងភូមិភាគ មានបែងចែកជាតំបន់ ហើយតំបន់មានបែងចែកជាស្រុក និងឃុំ (ដែលហៅថាសហករណ៍) ។ ខុច បានបញ្ជាក់ថា សមាជិកគណៈមជ្ឈិមទាំងអស់ដែលទទួលបន្ទុកគ្រប់គ្រងតាមហានន្តរសក្តិ មានភាគពុកចុះរាយការណ៍ជូនថ្នាក់លើតាមលំដាប់រហូតដល់គណៈមជ្ឈិមអចិន្ត្រៃយ៍ ។ ទាក់ទងនឹងខ្សែសង្វាក់នៃបញ្ជា ខុច បានរៀបរាប់ពីអំណាចថ្នាក់ខាងបំផុតរហូតដល់ថ្នាក់កំពូល : គណៈកង, គណៈឃុំ ឬគណៈសហករណ៍, គណៈស្រុក, គណៈតំបន់, គណៈភូមិភាគ និងគណៈមជ្ឈិម ។ ខណៈពេលដែលសួរពីសិទ្ធិក្នុងការកម្ទេច ខុច បានអះអាងថា គណៈអចិន្ត្រៃយ៍តាមភូមិភាគនីមួយៗមានសិទ្ធិក្នុងការបញ្ជាឲ្យកម្ទេច ។ បន្ថែមលើនេះ តំបន់ឯករាជ្យ ឬតំបន់សុយ័តមិនចាំបាច់រាយការណ៍ជូនលេខាភូមិភាគទេ ។ មានន័យថា តំបន់សុយ័តនេះមានសិទ្ធិរាយការណ៍ជូនដល់លេខា និងអនុលេខាបក្សកុម្មុយនីស្តកម្ពុជាដាល់ ។ ខុច បានរៀបរាប់ពីដែ្នកយោធារបស់បក្សកុម្មុយនីស្តកម្ពុជាថាមុនថ្ងៃជ័យជម្នះ ១៧ មេសា ឆ្នាំ១៩៧៥ កងទ័ពបដិវត្តន៍កម្ពុជាគឺចិតនៅក្រោមការគ្រប់គ្រងដាល់តាមគណៈតំបន់នីមួយៗដែលចិតក្រោមការគ្រប់គ្រងទូទៅដាល់ពី ប៉ុល ពត និង នួន ជា ។ ប៉ុន្តែក្រោយខែកក្កដា ឆ្នាំ១៩៧៥ កងទ័ពបដិវត្តន៍កម្ពុជា ត្រូវបានតែងទម្រង់ឡើងវិញដោយចិតនៅក្រោមការគ្រប់គ្រងដាល់របស់អគ្គមេបញ្ជាការកងទ័ពបដិវត្តន៍កម្ពុជាប្រចាំនៅទីក្រុងភ្នំពេញ ។

ក្រោយពីសម្រាកពេលព្រឹក វីលៀម ស្មីត បានសួរសំណួរឲ្យ ខុច បកស្រាយពីការគ្រប់គ្រងអំណាចក្នុងជួរកងទ័ពបដិវត្តន៍កម្ពុជា ។ ខុច បានរៀបរាប់ពីឈ្មោះកងពលជាហូរហែ ហើយចុងក្រោយបានបញ្ជាក់ថាមុនឆ្នាំរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំ អគ្គមេបញ្ជាការកងពលទាំងអស់ត្រូវបានកម្ទេចចោល លើកលែងតែ សុន សេន និងមេបញ្ជាការកងទ័ពបដិវត្តន៍កម្ពុជា ។ ជាក់ស្តែងចំនួនសមាជិកកងទ័ពបដិវត្តន៍កម្ពុជាប្រមាណ៥,០០០នាក់ត្រូវបានកម្ទេចនៅមន្ទីរស-២១ ពីព្រោះថ្នាក់លើមានជំនឿថាក្នុងជួរកងទ័ពមានខ្មាំងបង្កប់ស៊ីរូងដែ្នក្នុងច្រើន ។ ខុច បានលើកឡើងបន្ថែមទៀតថា យោងតាមលក្ខន្តិកបក្សកុម្មុយនីស្តកម្ពុជាឆ្នាំ១៩៧១ កងទ័ពបដិវត្តន៍កម្ពុជាគឺជា «អង្គភាពបងប្អូនរបស់បក្ស» ដូច្នេះកងទ័ពបដិវត្តន៍កម្ពុជាគឺចិតនៅក្រោមការគ្រប់គ្រងដាល់ពីលេខាបក្ស ប៉ុល ពត និងអនុលេខាបក្ស នួន ជា ។ ជាមួយគ្នានេះ ខុច បានជម្រាបអង្គជំនុំជម្រះថាបានឮឈ្មោះ ខៀវ សំផន តាំងពីឆ្នាំ១៩៥៨ ។ ក្រោយថ្ងៃជ័យជម្នះ ប៉ុល ពត បានតែងតាំង ខៀវ សំផន ជាប្រធានការិយាល័យមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ប៉ុន្តែ ខុច បានអះអាងថា មុខតំណែងរបស់ ខៀវ សំផន ជាប្រធានប្រមុខរដ្ឋគឺមានតែ «ឈ្មោះ» តែប៉ុណ្ណោះ ។ ខៀវ សំផនគ្មានអំណាចអ្វីលើកងទ័ពបដិវត្តន៍កម្ពុជាឡើយ ។ ខុច បានឱយបន្ថែមថា គោលបំណងរបស់ ប៉ុល ពត ក្នុងការតែងតាំង ខៀវ សំផន ជាប្រធានប្រមុខរដ្ឋគឺដើម្បីផ្សព្វផ្សាយពីចលនាតស៊ូរបស់ខ្មែរក្រហមទៅសហគមន៍អន្តរជាតិ ពីព្រោះ ខៀវ សំផន ត្រូវបានចាត់ទុកជាបុគ្គល «ស្អាតស្អំ» ម្នាក់ទាំងក្នុងប្រទេស និងក្រៅប្រទេស ។ ដោយឡែក ខុច បានឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញាថា បានឮឈ្មោះ អៀង សារី ក្នុងឆ្នាំ១៩៦២ តាមរយៈគ្រូបង្រៀនរបស់ ខុច ហើយបានដឹងថា អៀង សារី គឺជា «អ្នកនយោបាយដ៏គួរឲ្យគោរពកោតសរសើរ» ម្នាក់ ។

សវនាការពេលរសៀល

ក្រោយពេលឈប់សម្រាកអាហារថ្ងៃត្រង់ អង្គជំនុំជម្រះសាលាដំបូងបានបន្តស្តាប់ការសាកសួរសាក្សី ខុច ពីសំណាក់សហព្រះរាជអាជ្ញារងអន្តរជាតិបន្ថែមទៀត ។ ខុច បានឱយថាក្នុងចន្លោះឆ្នាំ១៩៧២ និង១៩៧៣ ខុច បានស្តាប់ឮតាមវិទ្យុថា អៀង សារី ត្រូវបានតែងតាំងជា «អ្នកការទូតពិសេស» របស់ទីក្រុងប៉េកាំង ។ ដោយឡែក ខុច បានបន្ថែមថា នៅឆ្នាំ១៩៧១ គាត់បានទៅដល់តំបន់ពិសេស ហើយបានស្គាល់ នួន ជា និងសមាជិកគ្រួសាររបស់ នួន ជា មួយចំនួនដែរ ។ លោក វីលៀម ស្មីត បានងាកមកសួរ ខុច ទាក់ទងនឹងមន្ទីរស-៧១វិញម្តង ។ ខុច បានបញ្ជាក់ថា មន្ទីរស-៧១ នេះគឺចិតនៅក្រោមការគ្រប់គ្រងរបស់ ប៉ិង ហើយ ប៉ិង នេះក៏មានសិទ្ធិអំណាចលើមន្ទីរស-២១ដែរ ។ ខុច បានឱយថា ប៉ិង បានទទួលបញ្ជាដាល់ពី ប៉ុល ពត ។ បន្ទាប់មកទៀត លោក វីលៀម ស្មីត បានដាក់ឯកសារមួយដើម្បីសួរសំណួរមួយចំនួនទៅកាន់ ខុច ។ ខុច បានអះអាងថា ឯកសារនេះរៀបរាប់

ពីអង្គប្រជុំកាលពីខែកញ្ញា ឆ្នាំ១៩៧៦ ។ ខុច មិនបានចូលរួមក្នុងអង្គប្រជុំនេះទេ ប៉ុន្តែបាននិយាយថា គោលបំណងនៃអង្គប្រជុំនេះគឺបូកសរុបលទ្ធផលការងារបង្កបង្កើនផលស្រូវ និងបញ្ហាខ្វាំងដើម្បីទទួលសេចក្តីបង្គាប់ពីអង្គការ ។ ខុច បានបញ្ជាក់ត្រង់ចំណុចនេះថា ក្នុងបរិបទនេះ «អង្គការ» គឺសំដៅលើ ប៉ុល ពត ។ ទាក់ទងនឹង «មន្ទីរគណៈមជ្ឈិម» ខុច បានបញ្ជាក់ថា ខៀវ សំដន គឺជាប្រធានមន្ទីរនេះ ប៉ុន្តែ ខុច មិនសូវដឹងព័ត៌មានពី ខៀវ សំដន ច្រើនទេ ។ ឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញាពីសកម្មភាពរបស់ ខៀវ សំដន ខុច បានពន្យល់ថា គាត់បានឃើញឯកសារបក្សកុម្មុយនីស្តកម្ពុជាដែលស្នើសុំទិញទំនិញ និងលិខិតអនុញ្ញាតធ្វើដំណើរត្រូវបញ្ជូនទៅបង ហែម ឬ ខៀវ សំដន ។ ដូច្នេះ ខុច បានសន្និដ្ឋានថា ខៀវ សំដន ទទួលបន្ទុកផ្នែកពាណិជ្ជកម្ម និងទស្សនាហកម្ម អគ្គិសនី ។

ក្រោយពេលឈប់សម្រាកពេលរសៀល ខុច បានឆ្លើយតបនឹងសំណួររបស់លោក វីលៀម ស្មីត បន្តទៀតពាក់ព័ន្ធនឹងតួនាទីរបស់ ខៀវ សំដន ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ខុច បានបកស្រាយថា លិខិតអនុញ្ញាតឲ្យធ្វើដំណើរនេះគឺជាគោលការណ៍ដ៏សំខាន់របស់បក្សក្នុងការគាមដាន និងគ្រប់គ្រងការដើរហើររបស់សមាជិកបក្សនីមួយៗ ។ ឆ្លើយតបនឹងសំណួរស្តីពីឈ្មោះបដិវត្តន៍ ខុច បាននិយាយថា ខៀវ សំដន មានឈ្មោះបដិវត្តន៍ច្រើនដូចជា បងហែម និង បងខាង ។ បន្ទាប់មកទៀត ខុច បានរៀបរាប់ពីការប្រជុំនៅមន្ទីរ «ក-៧» ដែល ខុច បានចូលរួមថា រាល់សំបុត្រទាំងអស់ដែលខាងភូមិភាគទទួលបានត្រូវបានប្រមូលប្រគល់ឲ្យគណៈមជ្ឈិម ។ ដោយឡែក ខុច បាននិយាយពីមន្ទីរទស្សនាហកម្មអគ្គិសនី ។ បុគ្គលិកមន្ទីរទស្សនាហកម្មអគ្គិសនីម្នាក់ត្រូវបានចាប់ខ្លួនបញ្ជូនមកមន្ទីរស-២១ ហើយនៅក្នុងចម្លើយសារភាពរបស់បុគ្គលិករូបនេះបានចោទ ខៀវ សំដន ជាខ្វាំង ។ ដូច្នេះ ខុច បានសន្និដ្ឋានដូចខាងលើថា ខៀវ សំដន បានទទួលបន្ទុកគ្រប់គ្រងមន្ទីរទស្សនាហកម្មអគ្គិសនីដែរ ។ ខុចក៏បានរៀបរាប់ពីអង្គប្រជុំមួយធ្វើឡើងនៅសាលារៀននៅទីក្រុងភ្នំពេញ ដោយមាន ខៀវ សំដន ជាប្រធានអង្គប្រជុំដើម្បីពិភាក្សាពីឃ្វាំងសព្វាវុធរបស់បក្ស ។ ខុច បានបន្តថា ខៀវ សំដន បានលើកឡើងពីស្ថានភាពទូទៅនៃឃ្វាំងសព្វាវុធ ។ ដូច្នេះ ខុច បានសន្និដ្ឋានថា ខៀវ សំដន គឺជាប្រធានមន្ទីរទស្សនាហកម្មអគ្គិសនី ។ លោក វីលៀម ស្មីត ក៏បានចោទសួរ ខុច ពីតួនាទីរបស់ ខៀវ សំដន ជាប្រធានមន្ទីរគណៈមជ្ឈិមក្រោយពេលដែល ខៀង អតីតប្រធានមន្ទីរគណៈមជ្ឈិមត្រូវបានចាប់ខ្លួន ។ ខុច បានអះអាងថា ក្នុងអំឡុងពេលបម្រើការជាប្រធានមន្ទីរគណៈមជ្ឈិម ខៀង មានសិទ្ធិគ្រប់គ្រងតែឯកសារទេ ប៉ុន្តែក្រោយពេលដែល ខៀវ សំដន ឡើងជំនួសតំណែងនេះ ខៀវ សំដន មានតួនាទីលើសពីនេះជាច្រើនដូចជាសិទ្ធិអំណាចគ្រប់គ្រង ត្រួតពិនិត្យលើមន្ទីរទស្សនាហកម្មអគ្គិសនី ។ ខុច បានបញ្ជាក់បន្ថែមថា តួនាទីទាំងអស់របស់ ខៀវ សំដន មិនមានការផ្លាស់ប្តូរអ្វីឡើយ ។ លោក វីលៀម ស្មីត បានដាក់ឯកសារមានឈ្មោះថា «សេចក្តីបង្គាប់របស់គណៈមជ្ឈិម» លើ «កំហុសឆ្គង» របស់ជនក្បត់ ។ ខុច បានឆ្លើយតបថា ខុច បានទទួលឯកសារនេះ ហើយឯកសារនេះក៏ត្រូវបានចុះផ្សាយក្នុងទស្សនាវដ្តីទង់បដិវត្ត ។ ខុច ពេញចិត្តនឹងសេចក្តីបង្គាប់នេះពីព្រោះវាមានចែងជាគោលការណ៍អត់ឱនច្រើនដល់អ្នកដែលប្រព្រឹត្តខុស ហើយអនុញ្ញាតឲ្យអ្នកប្រព្រឹត្តខុសដែលបានឆ្លើយសារភាពកំហុសរបស់ខ្លួនមិនមានទោសពៃរ៍ ។ ទោះជាយ៉ាងណាក្តី លេខាបក្សកុម្មុយនីស្តកម្ពុជានៅតែបង្គាប់ឲ្យមានការចាប់ខ្វាំងស៊ីរូងផ្ទៃក្នុង ។ ខុច បានអះអាងថា សេចក្តីបង្គាប់នេះគឺគ្រាន់តែប្រើប្រាស់ដើម្បីធ្វើឲ្យសមាជិកបក្សផ្សេងៗមានអារម្មណ៍ពេញចិត្តនឹងគោលការណ៍របស់ថ្នាក់ដឹកនាំបក្សតែប៉ុណ្ណោះ ។ ជាចុងបញ្ចប់នៃការសួរដេញដោលក្នុងថ្ងៃនេះ លោក វីលៀម ស្មីត បានសួរ ខុច ពីសមាជប្រជុំរដ្ឋសភា ។ ខុច បាននិយាយថា ក្នុងអង្គសមាជប្រជុំលើកទីមួយ ខុច មិនបានឃើញ នួន ជា, សោ ភឹម និង តា ម៉ុក ទេ ប៉ុន្តែបានឃើញ រស់ ញឹម ដែលជាលេខាភូមិភាគពាយ័ព្យ ។ ខុច បានបញ្ជាក់ចំពោះមុខអង្គជំនុំជម្រះចុងក្រោយថា លេខាបក្សកុម្មុយនីស្តកម្ពុជាគឺ ប៉ុល ពត ហើយអនុលេខាបក្ស នួន ជា ។ សុន សេន, វន វ៉ែត និង អៀង សារី ទទួលបន្ទុកកិច្ចការរដ្ឋបាលទូទៅ ។

សកម្មថ្ងៃទីប្រាំពីរ (ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២)

សវនាការពេលព្រឹក

ថ្ងៃនេះ គឺជាថ្ងៃចុងក្រោយនៃការចោទសួរសាក្សី ខុច

ពីសំណាក់ភាគីព្រះរាជអាជ្ញាទាក់ទងនឹងប្រធានបទស្តីពីបញ្ហារចនាសម្ព័ន្ធរដ្ឋបាល គ្រប់គ្រង តួនាទី និងការទទួលខុសត្រូវរបស់លេខាបក្សកុម្មុយនីស្តកម្ពុជាក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ លោក វីលៀម ស្ទឺត បានសួរ ខុច ពីគោលការណ៍ប្រឆាំងជនក្បត់ក្នុងជួរបក្សកុម្មុយនីស្តកម្ពុជាសម្រាប់កំហុសអចេតនាដែលបានលើកឡើងកាលពីមុនិលមិញ។ ខុច បានបញ្ជាក់បន្ថែមថា គោលការណ៍នេះគឺខុសពីការអនុវត្តជាក់ស្តែង ពីព្រោះសមាជិកបក្សជាច្រើននាក់ត្រូវបានចាប់ខ្លួន និងកម្ទេចចោល។ លើសពីនេះ ខុច បានឱ្យដឹងថាខ្មែរក្រហមមានគោលការណ៍ជម្លៀសប្រជាជនក្រុងដើម្បីលត់ដំប្រជាជនទាំងអស់នេះឲ្យចូលរួមបង្កបង្កើនផលស្រូវ។ ខុច ក៏បានលើកឡើងថាក្នុងអង្គប្រជុំមួយ ប៉ុល ពត បានប្រកាសថាព្រះពុទ្ធសាសនាត្រូវតែរំលាយចោលដើម្បីឲ្យព្រះសង្ឃធ្វើពលកម្មលើកទំនប់ ដីកប្រឡាយជាមួយប្រជាជនសាមញ្ញ។ ជាថ្មីម្តងទៀត ខុច បានអះអាងថា ក្រោយពីបានសួរដេញដោលពីគោលការណ៍សម្រាលទោសដល់ជនក្បត់ស៊ីវិនដែលក្នុងរបស់គណៈមជ្ឈិមមក ខុច បានយោគយល់បុគ្គលិកមន្ទីរស-២១ច្រើន។ ប៉ុន្តែ នួន ជា បានតំរាម ខុច មិនឲ្យធ្វើដូច្នេះ។ ខុច បានបញ្ជាក់ថា មានម្តងនោះ នួន ជា បាននិយាយឡកឡឺយដាក់ ខុច ថា «ឥឡូវ ខុច ដូចជាដឹងពីមាគ៌ាបក្សច្រើនពេកហើយ»។ វីលៀម ស្ទឺត បានឲ្យ ខុច បកស្រាយពីខ្លឹមសារនៃពាក្យ «អង្គការ»។ ខុច បានពន្យល់ថាពាក្យ «អង្គការ» នេះគឺសំដៅលើ ប៉ុល ពត ប៉ុន្តែថាកម្មាភិបាលថ្នាក់ខាងបានប្រើប្រាស់ពាក្យនេះខុស ដោយបង្កាប់អ្នកនៅក្រោមបង្កាប់ឲ្យហៅខ្លួនឯងថា «អង្គការ»។ ទាក់ទងនឹងគោលការណ៍ប្រឆាំងខ្មាំង ខុច បានពន្យល់ថា គ្មានគោលការណ៍អ្វីពិសេសជាមួយខ្មាំងទេ ពីព្រោះឲ្យតែខ្មាំងគឺត្រូវតែកម្ទេច។ ឧទាហរណ៍ដូចជាពួកភ្នាក់ងារ សេ.អ៊ី.អា, កា.ហ្សេ.បេ, និងកងទ័ពវៀតណាម។ និយាយជារួមខ្មាំងគឺត្រូវតែកម្ទេច។ បន្ទាប់មកទៀត ខុច និយាយអំពីសមាសភាពមន្ត្រីរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដែលមានដូចតទៅ៖

- សមមិត្តលេខា៖ ប៉ុល ពត នាយករដ្ឋមន្ត្រី
- សមមិត្តអនុលេខា៖ នួន ជា ប្រធានសភា
- សមមិត្ត វ៉ាន់៖ អៀង សារី ក្រសួងការបរទេស
- សមមិត្ត ហែម៖ ខៀវ សំផន ប្រធានប្រមុខរដ្ឋ
- សមមិត្ត ធុច៖ កុយ ធួន ក្រសួងពាណិជ្ជកម្មរដ្ឋ
- សមមិត្ត ខៀវ៖ សុន សេន ក្រសួងការពារជាតិ

សុន សេន

- សមមិត្ត វ៉ន : វ៉ន វ៉ែត ក្រសួងសេដ្ឋកិច្ច
- សមមិត្ត ខៀន : សៀ អ៊ាសុី
- សមមិត្ត ភា : អៀង ធីរិទ្ធ ក្រសួងសុខាភិបាល
- សមមិត្ត អាត : យ៉ុន យ៉ាត (ប្រពន្ធ សុន សេន)
- សមមិត្ត ជ័យ : នង សួន
- សមមិត្ត យ៉ែម : ស៊ឹម សុន
- សមមិត្ត ប៉ង់ : ឈឹម សំអោក

បន្ទាប់មកទៀត ឌុច បានឆ្លើយតបនឹងសំណួររបស់ភាគីសហព្រះរាជអាជ្ញាថា មន្ទីរស-២១មិនចឹតនៅក្រោមការគ្រប់គ្រងពីមន្ទីរណាមួយឡើយ ប៉ុន្តែគឺចឹតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ សុន សេន ។

ក្រោយពេលសម្រាកពេលព្រឹក សហព្រះរាជអាជ្ញាបានដាក់បញ្ជីរាយឈ្មោះអ្នកទោសសួរ ឌុច បន្ថែមទៀតពាក់ព័ន្ធនឹងការសម្រេចកម្ទេចអ្នកទោស ។ ឌុច បានបកស្រាយថា មន្ទីរស-២១ មានតួនាទីទាញយកចម្លើយសារភាព ហើយបញ្ជូនឲ្យថ្នាក់លើ ។ ឌុច បានអះអាងពីចំណារនៅលើឯកសារដែល វីលៀម ស៊ឺត បង្ហាញ ថាជាចំណាររបស់ នួន ជា ដែលសរសេរថា «បញ្ហាបានដោះស្រាយ» ។ ឌុច បានបញ្ជាក់ថាក្នុងអំឡុងពេលនោះ នួន ជា ជាអ្នកចេញសេចក្តីសម្រេច ហើយចំណារលើឯកសារនោះបានគួសបញ្ជាក់ថា នួន ជា បានពិនិត្យ និងសម្រេចលើចម្លើយសារភាពរបស់អ្នកទោសម្នាក់នោះហើយ ។ ក្រោយពីលេខាបក្សកុម្មុយនីស្តកម្ពុជាបានចេញសេចក្តីសម្រេច ចម្លើយសារភាពនោះត្រូវបានបញ្ជូនទៅអង្គភាពដែលពាក់ព័ន្ធឲ្យអនុវត្តតាមសេចក្តីសម្រេចឲ្យចាប់ខ្លួនជនដែលមានឈ្មោះក្នុងចម្លើយសារភាពនោះ ។

សវនាការពេលរសៀល

ក្រោយពេលឈប់សម្រាកអាហារថ្ងៃត្រង់ លោក វីលៀម ស៊ឺត បានសួរ ឌុច ពីការប្រើប្រាស់ព័ត៌មានក្នុងចម្លើយសារភាព ។ ឌុច បានអះអាងថានេះគឺជាគោលការណ៍អនុវត្តទូទៅក្នុងការបញ្ជូនព័ត៌មានស្តីពីសមាសភាពដែលជាប់ពាក់ព័ន្ធក្នុងចម្លើយសារភាពពីមន្ទីរស-២១ ទៅកាន់អង្គភាពពាក់ព័ន្ធ ។ គោលការណ៍នេះត្រូវបានប្រកាន់ខ្ជាប់ចាប់តាំងពីឆ្នាំ១៩៧១មកម្ល៉េះ ។ ឌុច បានបន្ថែមទៀតថា ប្រធានកងត្រូវតែធានាថាបុគ្គលដែលជាប់ពាក់ព័ន្ធក្នុងចម្លើយសារភាពរបស់អ្នកទោសមន្ទីរស-២១ មិនដឹងពីការតាមដាន និងចាប់ខ្លួនទេ ។ ប៉ុន្តែមុននឹងចាប់ខ្លួនបុគ្គលណាម្នាក់ត្រូវតែមានការពិភាក្សា និងអនុញ្ញាតពីប្រធានកងដែរ បើយោងតាមលក្ខន្តិកបក្សកុម្មុយនីស្តកម្ពុជា ។ បន្ទាប់មកទៀត វីលៀម ស៊ឺត បានដាក់ឯកសារមួយទៀតឲ្យ ឌុច បកស្រាយ ។ ឌុច បានឱយយថា ឯកសារនេះគឺជាបញ្ជីឈ្មោះបុគ្គលជាប់ពាក់ព័ន្ធក្នុងចម្លើយសារភាពរបស់អ្នកទោសមុនដែលត្រូវចាប់ខ្លួន ។ បុគ្គលដែលមានឈ្មោះក្នុងបញ្ជីនេះមកពីក្រសួងការបរទេស ។ ខណៈពេលដែលសួរពីការសន្ទនារបស់ ឌុច ជាមួយនឹង នួន ជា ឌុច បានបញ្ជាក់ថា ណាត អតីតប្រធានរបស់ ឌុច ត្រូវបានបញ្ជូនទៅផ្នែកទូតមុនពេល ណាត ត្រូវបានចាប់ខ្លួន ។ ដូច្នេះ ឌុច បានយល់ថាការចាត់តាំងរបស់ នួន ជា ឲ្យទៅធ្វើទូតគឺសំដៅលើការចាប់ខ្លួន ។ ជាការសន្មត សមាជិកដែលលេខាបក្សកុម្មុយនីស្តកម្ពុជាមិនទុកចិត្តអាចត្រូវបានចាប់ខ្លួន ។ ឌុច បានគូសបញ្ជាក់ថាការចាត់តាំងឲ្យកម្មាភិបាលណាម្នាក់ទៅបម្រើការផ្នែកការទូតគឺដើម្បីបំបែកកម្លាំងគ្រប់គ្រងរបស់កម្មាភិបាលនោះមិនឲ្យមានអ្នកនៅក្រោមបង្គាប់ដោយសារអង្គការមិនទុកចិត្ត ។

ក្រោយឈប់សម្រាកពេលរសៀល លោក វីលៀម ស្ទឺត បានចោទសួរ ខុច បន្តែមទៀតពីក្រសួងការបរទេស។ ខុច បានឆ្លើយតបនឹងសំណួររបស់លោក វីលៀម ស្ទឺត ទាក់ទងនឹងសេចក្តីប្រកាសតាមវិទ្យុមួយកាលពីខែកុម្ភៈ ឆ្នាំ១៩៧៦ ខុច បានសង្កត់ធ្ងន់ថា កាលណោះវិទ្យុបានប្រកាសឈ្មោះមហាជនក្បត់ទាំងជ្រុំពីររូបរបស់បក្សកុម្មុយនីស្តកម្ពុជា។ ខុច បានអះអាងថា ខុច ពេញចិត្តនឹងសេចក្តីប្រកាសនេះពីព្រោះជនដែលមិនមែនជាមហាជនក្បត់ទាំងជ្រុំពីរនេះនឹងមិនមានទោសពៃរ៍អ្វីទេ។ ខុច យល់ថាសេចក្តីប្រកាសនេះ អាចត្រូវបានរៀបរៀងដោយ ប៉ុល ពត។ សេចក្តីប្រកាសនោះមិនបានបញ្ជាក់ថាមហាជនក្បត់ទាំងជ្រុំពីររូបនោះនឹងត្រូវសម្លាប់ទេ ហើយថានឹងនាំយកទៅកាត់ទោស។ ជាចុងក្រោយ លោក វីលៀម ស្ទឺត បានដាក់ឯកសារមួយចំពោះមុខ ខុច។ ខុច បានអះអាងថាឯកសារនោះ គឺជាចម្លើយសារភាពរបស់ ហ៊ូ នឹម។ នៅក្នុងចម្លើយសារភាពនោះ មានចំណារដោយដៃផ្ទាល់របស់ ហ៊ូ នឹមដែរ។ នៅលើចម្លើយសារភាពនេះមានចំណារមួយសរសេរថា «ផ្ញើជូនអង្គការបក្សកុម្មុយនីស្តកម្ពុជា» មានដូចជា : ប៉ុល ពត, នួន ជា, អៀង សារី, វន វែត, សុន សេន និង ខៀវ សំផន។ (សកម្មភាពរបស់ ខុច មានបន្តទៀតនៅថ្ងៃបន្ទាប់) ។ **ឯន សុខស្រីនិត**

ក្រុមបញ្ជាជននេះមិនត្រូវបានចាត់ទុកជាខ្លាំង ឬសត្រូវទេ ប៉ុន្តែដោយសារតែការមិនទុកចិត្តពីលេខាបក្សកុម្មុយនីស្ត ក្រុមបញ្ជាជននេះត្រូវបានបញ្ជូនមកសាលាចឹនត្របែកដើម្បីអប់រំមនោគមន៍វិជ្ជា និងតាមដាន។

ក្រោយឈប់សម្រាកពេលរសៀល លោក វីលៀម ស្ទឺត បានចោទសួរ ខុច បន្តែមទៀតពីក្រសួងការបរទេស។ ខុច បានពន្យល់ថា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ «ការទូត» មានន័យខុសពី «អគ្គរដ្ឋទូត» ដែលសំដៅលើជនដែលត្រូវបានបំបែកចេញពីអ្នកនៅក្រោមបង្គាប់។ ខុច បានរៀបរាប់ឈ្មោះកម្មាភិបាលមួយចំនួនដែលចាត់តាំងឲ្យទៅធ្វើទូត ប៉ុន្តែត្រូវបានចាប់ខ្លួនមកមន្ទីរស-២១ ដើម្បីសួរចម្លើយ និងកម្ទេច។ ខុច បានបញ្ជាក់បន្តែមថា អ្នកដែលបានចាប់ខ្លួនបញ្ជូនមកមន្ទីរស-២១ មានពីរប្រភេទគឺ អ្នកទោសដែលមន្ទីរស-២១ចាប់ខ្លួនដាល់ និងអ្នកទោសដែលប្រធានអង្គភាពចាប់ខ្លួនរួចបញ្ជូនមកមន្ទីរស-២១។ ជាក់ស្តែង ចំនួនអ្នកទោសដែលមន្ទីរស-២១ចាប់ខ្លួនដាល់មានគិចជាងចំនួនអ្នកទោសដែលអង្គភាពបានចាប់ខ្លួនរួចបញ្ជូនមកមន្ទីរស-២១។ ខុច បានអះអាងថា ប្រធានអង្គភាពនីមួយៗមានសមត្ថកិច្ចចាប់ខ្លួនអ្នកទោសរួចបញ្ជូនមកមន្ទីរស-២១។ បន្ទាប់មក លោក វីលៀម ស្ទឺត បានសួរ ខុច ពីសាលាចឹនត្របែក។ ខុច បានរៀបរាប់ថា សាលាចឹនត្របែកគឺជាមជ្ឈមណ្ឌលអប់រំ និងកែប្រែសម្រាប់ក្រុមបញ្ជាជន ដែលជាសមាជិករបស់រណសិរ្សរួបរួមជាតិកម្ពុជា។ ក្រុមបញ្ជាជននេះ



ខុច ក្នុងបន្ទប់សវនាការ

ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានធ្វើអ្វី?

ជារៀងរាល់ឆ្នាំ នៅថ្ងៃទី១៧ ខែមេសា ប្រជាជនកម្ពុជាតែងតែនឹកឃើញថ្ងៃនៃការចាប់ផ្តើមនូវរបបមួយដែលជាទូទៅយើងហៅថា «របបខ្មែរក្រហម» ។ លោកសហព្រះរាជអាជ្ញាអន្តរជាតិ អេនខ្មែ ខេលី ដែលមានបទពិសោធន៍ការងារជាច្រើនឆ្នាំក្នុងរឿងព្រហ្មទណ្ឌនៅតុលាការអន្តរជាតិមួយចំនួន បានហៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ថា គឺជាថ្ងៃដែល «អាយុជីវិតប្រជាជនរាប់លាននាក់ក្លាយជាកម្មសិទ្ធិរបស់បក្សកុម្មុយនីស្តកម្ពុជា» ។

យោធាខ្មែរក្រហមដែលទទួលជ័យជម្នះចូលមកកាន់ទីក្រុងភ្នំពេញគ្រប់ទិសទី (រូបថត : រ៉ូឡង់ នើរើ)

ទោះបីរបបនេះបានកន្ទុចហួសជាងសាមសិបឆ្នាំហើយក៏ដោយ ក៏ប្រជាជនកម្ពុជានៅតែមានការចងចាំមិនអាចបំភ្លេចបាននូវរឿងរ៉ាវដ៏សែនឈឺចាប់ និងទុក្ខសោកវេទនា ដោយសារការបែកបាក់គ្រួសារ ការតម្រូវឲ្យធ្វើការជាទម្ងន់ ភាពអត់ឃ្លាន ភាពភ័យខ្លាច ភាពអស់សង្ឃឹមក្នុងជីវិត ភាពគ្មានទីពឹង ការបាត់បង់ទ្រព្យសម្បត្តិដែលគាត់បានទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅពេលសួរនាំពីបទពិសោធន៍រស់នៅរបស់គាត់ក្នុងរបបខ្មែរក្រហម ជនរងគ្រោះបានឆ្លើយដោយលាយឡំនឹងទឹកភ្នែក ។ ប្រជាជនកម្ពុជារាប់លាននាក់បានជួបរឿងរ៉ាវនេះ លើកលែងតែមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាមួយចំនួនប៉ុណ្ណោះ ដែលនៅតែបន្តអះអាងថា ខ្លួនមិនបានដឹងអំពីបញ្ហានេះ ។

នៅថ្ងៃទី២១-២៣ ខែវិច្ឆិកា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបើកសវនាការលើសំណុំរឿង ០០២ ដែលមានជនជាប់ចោទបួនរូប គឺ នួន ជា, អៀង សារី, ខៀវ សំផន និង អៀង ធិរិទ្ធ (បច្ចុប្បន្នត្រូវបានបំបែកចេញពីសំណុំរឿង) ។ សវនាការនេះអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាថ្លែងបើកការចោទប្រកាន់ជនជាប់ចោទទាំងបួនរូបនេះចំពោះខ្លក្រិដ្ឋកម្មដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យដោយគិតចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ នៅក្នុងសេចក្តីថ្លែងរបស់ខ្លួន លោកជំទាវសហព្រះរាជអាជ្ញាជាតិ ជា លាង បានលើកឡើងថា «នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បន្ទាប់ពីកងទ័ពខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ ការជម្លៀសប្រជាជនដ៏គួរឲ្យរន្ធត់មួយបានកើតឡើង ។ ខ្មែរក្រហមបានប្រកាសឲ្យប្រជាជនចេញពីលំនៅដ្ឋាន ដោយហេតុបញ្ឆោតថា អាមេរិកកាំនឹងមកទម្លាក់គ្រាប់បែកមកលើទីក្រុងភ្នំពេញ ។ ប្រជាជនត្រូវបានបង្ខំឲ្យចេញពីផ្ទះសម្បែង ទ្រព្យសម្បត្តិ និងខ្លះបែកបាក់សមាជិកគ្រួសារ (ដោយសារមិននៅជុំគ្នាពេលខ្មែរក្រហមជម្លៀស) ហើយធ្វើដំណើរឆ្ពោះទៅកាន់ទីជនបទឆ្ងាយៗ ។ ក្នុងរយៈពេលតែប៉ុន្មានម៉ោងប៉ុណ្ណោះ នៅតាមដងវិថីនានានៃទីក្រុងភ្នំពេញ គឺពោរពេញទៅដោយហ្វូងមនុស្ស ដែលត្រូវគេបង្ខំឲ្យចាកចេញពីទីក្រុងដោយគ្មាននរណាដឹងថាខ្លួននឹងត្រូវទៅទីណាឡើយ ។ បុរស ស្ត្រី កុមារ មនុស្សចាស់ជរាជាងពីរលាននាក់ ត្រូវបានបង្ខំឲ្យចាកចេញដោយគ្មានការលើកលែង ។ អ្នកជំងឺត្រូវបានបង្ខំឲ្យចេញពីមន្ទីរពេទ្យ

ស្ត្រីមានផ្ទៃពោះអ្នកដែលទើបនឹងសម្រាលកូនត្រូវបានគេបង្ខំឲ្យចាកចេញពីឥណ្ដាលថ្ងៃត្រង់ជាមួយ និងកូនពេវក្នុងដៃ» ។

លោកជំទាវ ជា លាង បានដកស្រង់ខ្លឹមសារក្នុងសៀវភៅមួយដែលបានរៀបរាប់ថា «អ្នកជំងឺ និងអ្នករបួសរាប់ពាន់នាក់ត្រូវបានគេបោះបង់ចោលក្នុងទីក្រុង ។ អ្នកដែលនៅមានកម្លាំងគឺខំប្រឹងប្រែងទៅតាមគេ ខណៈដែលអ្នកខ្លះត្រូវបានមិត្តភក្តិជួយគ្រា និងអ្នកខ្លះទៀតត្រូវក្រុមគ្រួសារដាក់នៅលើក្រែរុញ ដោយមានសឺរ៉ឹមភ្ជាប់ជាមួយ ដែលមើលទៅគួរឲ្យអាណិតយ៉ាងក្រៃលែង ។ ហើយអ៊ីដែលមិនអាចបំភ្លេចបាននោះ គឺមានបុរសម្នាក់ពិការទាំងដៃ និងដើងខំរមៀលខ្លួននៅលើដីដូចដង្កូវដាច់ខ្លួន» ។ លោកជំទាវ ជា លាង បានបន្តថា «ប្រជាជនជាច្រើនបានស្លាប់ជាត់បង់ជីវិតនៅអំឡុងពេលនៃការជម្លៀសនេះដោយសារជំងឺ មិនមានអាហារបរិភោគ និងការរត់ជាន់គ្នាជាដើម ។ មានសាកសពមនុស្សនៅពាសពេញផ្លូវ ហើយកងទ័ពខ្មែរក្រហមបើកឡានកិនលើមនុស្ស និងសាកសពទាំងនោះដូចសត្វធាតុ» ។

សវនាការថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ ឌុច បានផ្តល់សក្ខីកម្មជូនអង្គជំនុំជម្រះសាលាដំបូងថា គាត់ធ្លាប់បានឮឈ្មោះ ស៊ឹម ម៉ែល ហៅ ម៉ាន ដែលជាអ្នកបានចូលរួមក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដោយដាល់ ហើយបាននិយាយប្រាប់គាត់ថា «ពេលជម្លៀសហ្នឹង គេថាចេញៗ អាមេរិកកាំងមកទម្លាក់គ្រាប់បែក បើមិនចេញខ្ញុំជាញ់» ។

លោកជំទាវ ជា លាង បន្ថែមថា «ស្របពេលនឹងការជម្លៀសនេះដែរ ការស្រាវជ្រាវរកខ្លាំងរបស់បក្សកុម្មុយនីស្តកម្ពុជាក៏ត្រូវបានធ្វើឡើងភ្លាមៗ ដោយខ្មែរក្រហមបានដាក់ប៉ុស្តិ៍ត្រួតពិនិត្យនៅពេលប្រជាជនចាកចេញពីទីក្រុងភ្នំពេញ ។ កងកម្លាំងរបស់បក្សកុម្មុយនីស្តកម្ពុជាបានតាមស្វែងរក និងសម្លាប់មន្ត្រី និងឆាហានដែលធ្វើការក្នុងរបប លន់ នល់ ។ សាក្សីម្នាក់ដែលត្រូវបានគេបង្ខំឲ្យចាកចេញពីទីក្រុងភ្នំពេញទាំងគ្រួសារនិយាយថា នៅពេលជម្លៀសនេះ ឪពុករបស់គាត់ត្រូវបានចាប់យកទៅជាត់រហូតបន្ទាប់ពីខ្មែរក្រហមរកឃើញថាគាត់ជាឆាហានរបស់ លន់ នល់ ។ ការស្រាវជ្រាវរុករក និងការសម្លាប់ឆាហាន និងមន្ត្រីក្នុងរបប លន់ នល់ ចេះតែបន្តរហូតជាច្រើនថ្ងៃ ច្រើនសប្តាហ៍មកទៀត ។ ក្នុងការស្វែងរកនេះ ខ្មែរក្រហមបានប្រើប្រាស់វិធីសាស្ត្របំភាន់ភ្នែក ដោយប្រកាសឲ្យសមាជិករបស់របបចាស់រាយការណ៍ពីការងារដែលខ្លួនធ្លាប់ធ្វើមកប្រាប់អាជ្ញាធរថ្មីរបស់ខ្លួន ដើម្បីទទួលបានការចាត់តាំងការងារនោះវិញនៅក្រោមរដ្ឋបាលថ្មី ។ ជាលទ្ធផលអ្នកទាំងអស់ដែលបានទៅរាយការណ៍នោះត្រូវបានសម្លាប់ចោល ។ ប្រជាជនដែលនៅសេសសល់ពីការជម្លៀសនេះត្រូវបានបក្សកុម្មុយនីស្តកម្ពុជាចាត់តាំងឲ្យនៅតាមសហករណ៍ និងការដ្ឋានផ្សេងៗជាមួយប្រជាជននៅតាមមូលដ្ឋាន ។ ប្រជាជនទាំងអស់ត្រូវបានបក្សតម្រូវឲ្យធ្វើការជាទម្ងន់ ដោយមិនបានទទួលតម្លៃតបស្នងអ្វីឡើយ ពោលគឺទទួលបានតែបាយ ឬបបរបន្តិចបន្តួចប៉ុណ្ណោះ» ។

លោក អេនជ្រូ ខេលី បានលើកឡើងថា «គោលបំណងនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងទីប្រជុំជនផ្សេងៗរបស់ខ្មែរក្រហម គឺកើតចេញពីយុទ្ធសាស្ត្ររបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដែលយល់ថា តំបន់ទីក្រុងគឺជាសរសៃឈាមរបស់វណ្ណៈក្បត់ វណ្ណៈខ្មាំង ដែលសម្រេចថាត្រូវតែដេញចេញនិងសម្លាប់ចោល» ។ ជនជាប់ចោទ នួន ជា ធ្លាប់និយាយថា មានខ្មាំងជាច្រើននៅក្នុងទីក្រុង ហើយថាប្រជាជនត្រូវតែចេញពីទីក្រុងដើម្បីឲ្យបក្សកុម្មុយនីស្តកម្ពុជាកម្ទេចបណ្តាញខ្មាំងទាំងអស់នោះ ។

សវនាការថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ ជនជាប់ចោទ នួន ជា បានបញ្ជាក់ជូនតុលាការថា ពាក់កណ្តាលឆ្នាំ១៩៧៨ គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាបានបើកកិច្ចប្រជុំមិនពេញអង្គមួយ ដោយលើកយកបញ្ហាសំខាន់ៗមួយចំនួនមកពិភាក្សាដើម្បីចាត់វិធានការទុកជាមុន មុនពេលរំដោះបានទីក្រុងភ្នំពេញ និងទូទាំងប្រទេស ។ ក្នុងកិច្ចប្រជុំនេះគណៈអចិន្ត្រៃយ៍បានសម្រេចជាឯកច្ឆន្ទលើបីចំណុចដែលក្នុងនោះមានមួយចំណុច គឺគណៈអចិន្ត្រៃយ៍សម្រេចថា «ក្នុងករណីដែលរំដោះបានទីក្រុងភ្នំពេញនោះ យើងត្រូវជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ និងទីរួមខេត្តជាបណ្តោះអាសន្នដើម្បីពិនិត្យតាមស្ថានការណ៍មួយរយៈសិន ជាពិសេសពិនិត្យអំពីសកម្មភាពរបស់វៀតណាម» ។ យោងតាមការលើកឡើងរបស់ នួន ជា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺមិនមែនជារឿងចៃដន្យនោះទេ គឺមានការគិតទុក និងសម្រេចតាំងពីកិច្ចប្រជុំគណៈអចិន្ត្រៃយ៍នៅពាក់កណ្តាលឆ្នាំ១៩៧៨មកម្ល៉េះ ។ **ចាន ជ្រាថ្លា**

អតីតយុទ្ធនារីខ្មែរក្រហមនៅតែសម្រេចចិត្តមិនត្រឡប់ទៅស្រុកកំណើត

រហូតមកដល់សព្វថ្ងៃ ទោះបីជាមានអតីតកម្មាភិបាលខ្មែរក្រហមជាច្រើនបានវិលត្រឡប់ទៅលេងស្រុកកំណើត និងជួបជុំគ្រួសាររហើយយ៉ាងណាក៏ដោយ ក៏នៅតែមានអតីតខ្មែរក្រហមខ្លះសម្រេចចិត្តមិនត្រឡប់ទៅស្រុកកំណើតដែរ ។

ពត វុន មានស្រុកកំណើតនៅភូមិអន្ទង់ឫស្សី ឃុំថ្នាលអន្សារ ស្រុកក្រគរ ខេត្តពោធិ៍សាត់ ។ វុន មានបងប្អូនជ្រាប់បីនាក់ (ស្រីបីនិងប្រុសជ្រាំនាក់) ។ វុន ជាកូនទីជ្រាំពីរ ។ កាលពីកុមារ វុន បានរៀនដល់ថ្នាក់ទី៣ ក្រោយមកគាត់ក៏ឈប់រៀន រួចហើយត្រឡប់មកធ្វើស្រែជាមួយឪពុកម្តាយវិញ ។

នៅឆ្នាំ១៩៧០ វុន បានចូលបដិវត្តន៍ខ្មែរក្រហម ហើយគាត់ត្រូវបានចាត់តាំងឲ្យធ្វើការងារផ្សេងៗនៅក្នុងកងចល័តនិងតម្រូវឲ្យរស់នៅបែកពីឪពុកម្តាយ ។

រហូតកងទ័ពខ្មែរក្រហមទទួលបានជ័យជម្នះឆ្នាំ១៩៧៥ ខ្មែរក្រហមបានចាត់តាំង វុន ឲ្យទៅធ្វើកងចល័តនៅស្រុកលាច (បច្ចុប្បន្ន ស្រុកភ្នំក្រវ៉ាញ) វិញ ដោយគាត់មានភារកិច្ចសូង និងជីកប្រឡាយ ។ ចំណែកឪពុកម្តាយគាត់ អង្គការចាត់តាំងឲ្យធ្វើការនៅក្នុងសហករណ៍ជាមួយប្រជាជនក្នុងភូមិដដែល ។ វុន ធ្វើការនៅកងចល័តបានមួយរយៈ អង្គការក៏ជ្រើសរើសគាត់ឲ្យទៅនៅជាមួយទ័ពនៅខេត្តកោះកុង ភូមិភាគបស្ចិម ដោយនៅទីនោះគាត់មានភារកិច្ចដាំបាយ ។

នៅឆ្នាំ១៩៧៧ វុន បានដាស់មកធ្វើចម្ការការហូរនៅប៉ៃលិន ដោយអង្គការបានកំណត់ដែនការឲ្យធ្វើ ។ វុន បានបន្តថា រដូវខ្លះការហូរបានផ្តល់ដលលើសដែនការកំណត់ រហូតក្រុមរបស់គាត់ប្រមូលដលមិនទាន់ ទើបស្នើយកកម្លាំងទ័ពមកជួយបេះដែ្លការហូរបន្តែមទៀត ។

វុន ធ្វើចម្ការរហូតកងទ័ពវៀតណាមវាយចូលប្រទេសកម្ពុជាឆ្នាំ១៩៧៩ ទើបគាត់ និងប្រជាជនក្នុងសហករណ៍ និងសហជីពទាំងអស់ភៀសខ្លួនទៅរស់នៅម៉ាឡែវិញ ។ ទៅដល់ដំបូង វុន ត្រូវបានអង្គការបែងចែកឲ្យរស់នៅជាក្រុម និងធ្វើខ្មមស្នាក់នៅដោយខ្លួនឯង ប៉ុន្តែរបបអាហារអង្គការផ្តល់ឲ្យហូបតាមក្រុមគ្រប់គ្រាន់ ។

នៅទីនោះ មេបញ្ជាការរបស់ វុន បានជ្រើសរើស វុន ឲ្យចូលកងជីកជញ្ជួន ដោយគាត់មានភារកិច្ចទូលអង្ករ មី ត្រីខកំប៉ុង គ្រាប់

យុទ្ធជន និងយុទ្ធនារីខ្មែរក្រហមជញ្ជួនគ្រាប់ទៅឲ្យកងទ័ពនៅសមរភូមិមុខ

និងការភ្ញើងទៅឲ្យយោធាខ្មែរក្រហមនៅសមរភូមិមុខ។ ប៉ុន្តែរាល់ពេល វុន ជញ្ជូនម្ហូបៗ តែងតែមានយោធាខ្មែរក្រហមនាំផ្លូវ និងយាមការពារ ព្រោះខ្លាចកងទ័ពវៀតណាម និងកងទ័ពរដ្ឋាភិបាលភ្នំពេញដាក់មីនស្អាត់ និងជាញ៉ាស្ងាត់។

ឆ្នាំ១៩៨៥ កងទ័ពវៀតណាម និងកងទ័ពរដ្ឋាភិបាលភ្នំពេញដែលមានមូលដ្ឋាននៅភ្នំយាយសំ (ស្រុកម៉ាំង្វៃ) បានវាយរុញច្រានទ័ពខ្មែរក្រហមរហូតដល់ព្រំប្រទល់ថៃជាប់នឹងស្រុកម៉ាំង្វៃ ទើប វុន ទទួលបញ្ជាពីមេបញ្ជាឲ្យប្រមូលរបស់របរ ចានឆ្នាំង ចាកចេញពីម៉ាំង្វៃទៅរស់នៅជុំ៨៥ នៅក្នុងទឹកដីថៃវិញ ដោយនៅទីនោះគាត់ទទួលជំនួយពីអង្គការកាកបាទក្រហមអន្តរជាតិ។

នៅឆ្នាំ១៩៩២ ទើប វុន បានត្រឡប់ចូលមករស់នៅម៉ាំង្វៃ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏តំបន់នោះនៅពុំទាន់មានស្ថេរភាពដែរ ព្រោះជាតំបន់ដែលសំបូរទៅដោយគ្រាប់មីន និងជាតំបន់ដែលនៅមានការវាយប្រយុទ្ធគ្នារវាងយោធាខ្មែរក្រហមនិងកងទ័ពរដ្ឋាភិបាលនៅឡើយ។

វុន រៀបរាប់ថា ការវាយប្រយុទ្ធគ្នានេះបានអូសបន្លាយរហូតមកដល់ឆ្នាំ១៩៩៦ទើបបញ្ចប់ នៅពេលកងទ័ពខ្មែរក្រហមតំបន់ម៉ាំង្វៃធ្វើសមាហរណកម្មជាមួយរដ្ឋាភិបាល។ ប៉ុន្តែក៏នៅមានអតីតកម្មាភិបាលខ្មែរក្រហម និងប្រជាជនមួយចំនួននៅតំបន់នោះរងគ្រោះដោយសារគ្រាប់មីនដែរ។

ក្រោយមក ដោយសាររដ្ឋាភិបាលមានគោលនយោបាយបែងចែកដីដល់អតីតកម្មាភិបាលខ្មែរក្រហមដែលផ្តាច់ខ្លួន ទើបនៅឆ្នាំ២០០១ វុន បានទៅចាប់ដីតាមបណ្តោយអូរព្រំដែនកម្ពុជាថៃ នៅឃុំម៉ាំង្វៃ ស្រុកម៉ាំង្វៃ ខេត្តបន្ទាយមានជ័យ និងបានសង់ផ្ទះតូចមួយស្នាក់នៅរហូតមកដល់បច្ចុប្បន្ននេះ។

សព្វថ្ងៃ វុន មានអាយុ៧៦ឆ្នាំហើយ តែគាត់អាចធ្វើការងារផ្ទះ និងធ្វើស្រែចម្ការបាន។ នៅទីនោះ វុន គ្មានបងប្អូនទេ គឺមានតែអតីតយុទ្ធនារីខ្មែរក្រហមដែលធ្លាប់ធ្វើការ និងធ្លាប់រស់នៅជាមួយបានរាប់អានគាត់ដូចជាបងប្អូនប៉ុណ្ណោះ។

វុន បញ្ជាក់ថា គាត់បែកពីបងប្អូន និងឪពុកម្តាយចាប់តាំងពីគាត់ចូលបដិវត្តន៍ជាមួយខ្មែរក្រហមឆ្នាំ១៩៧០ម៉្លេះ ហើយរហូតមកពេលនេះ ទោះបីជាមានបងប្អូនរស់នៅស្រុកម៉ាំង្វៃមួយចំនួនបានត្រឡប់ទៅរកបងប្អូននៅស្រុកកំណើតហើយក៏ដោយ ក៏គាត់មិនបានត្រឡប់ទៅស្រុកកំណើតដែរ ព្រោះគាត់គិតថា បងប្អូនស្លាប់អស់ហើយ ម្យ៉ាងទៀតដោយសារគាត់មានជីវភាពខ្វះខាត។

សោម ប៊ុនថន

ហ៊ុលី ខ : ស្ត្រីចាមដ៏រឹងមាំម្នាក់

ពាក្យស្លោកមួយនិយាយថា «ស្ត្រីគឺជាឫស្សីដ៏ខ្ជាប់ខ្ជួននៃសេដ្ឋកិច្ចគ្រួសារ» ។ ខ្សែជីវិតរបស់អ្នកមីង ហ៊ុលី ខ ពិតជាឆ្លុះបញ្ចាំងពីតថភាព និងខ្លឹមសារដ៏មានន័យរបស់ពាក្យស្លោកខាងលើនេះ ។ ទោះបីជាចិតក្នុងសម្លៀកបំពាក់ប្រឡាក់ប្រឡូកដោយធ្យូង ធូលីដី និងមេអ្បាធ្វើនំ ហើយរស់នៅក្នុងផ្ទះឈើដ៏ទ្រុឌទ្រោមដែលមនុស្សក្នុងសង្គមស៊ីវិល័យថ្មីយល់ថាជាមនុស្សខ្សត់ខ្សោយ និងទ្រុឌទ្រោមយ៉ាងណាក្តី អ្នកមីង ហ៊ុលី ជាមនុស្សរឹងប៉ឹងរាងសរវៃក្នុងមុខរបបរបស់គាត់ ។ អ្នកមីង ហ៊ុលី មានដំណើរហ័សរហួន សំដីម៉ាត់ៗ និងរួសរាយរាក់ទាក់ ។ ខណៈពេលដែលដៃកំពុងតែរវល់ចាក់នំអាកោ គាត់បានឆ្លៀតសួរនាំខ្ញុំ និងកញ្ញា សូ ហ្វារីណា ពីគោលបំណងនៃការរៀបចំវេទិកាពិភាក្សាពីដំណើរការបញ្ចាំងសក្តីកម្មខុចដល់បងប្អូនក្នុងសហគមន៍ឥស្លាមភូមិខ្ជួនរបស់គាត់ ។ បើទោះបីជាជាប់មមាញឹកនឹងរបរលក់ដូរចញ្ចឹមជីវិតរបស់គាត់យ៉ាងណាក្តី អ្នកមីង ហ៊ុលី បានចែករំលែកនូវបទពិសោធន៍ជីវិតដែលជាគំរូមួយដ៏ប្រសើរដល់ស្ត្រីកម្ពុជាដទៃទៀតដែលបានរងគ្រោះ និងរួចរស់រានមានជីវិតពីរបបខ្មែរក្រហម ។

ជាកូនច្បងក្នុងចំណោមបងប្អូនប្រាំបួននាក់ អ្នកមីង ហ៊ុលី បានរស់នៅក្នុងភូមិខ្ជួន ស្រុកពញាឮ ខេត្តកណ្តាលដោយជីវភាពធូរធារសប្បាយ និងភាពកក់ក្តៅដោយមានឪពុកធ្វើការសមរម្យ ។ នៅឆ្នាំ១៩៧៥ ដោយសារតែការជម្លៀសទ្រង់ទ្រាយធំ និងជំងឺសួត ម្តាយរបស់គាត់បានធ្លាក់ខ្លួនឈឺ ហើយស្លាប់នៅពេលទៅដល់ខេត្តកំពង់ស្ពឺ ។ ស្របពេលជាមួយគ្នានោះ បងប្អូនប្រុសពីរនាក់ទៀតក៏បានស្លាប់ដោយសារជំងឺ ខណៈពេលដែលបងប្អូនប្រុសគាត់ទីបីបានរត់ឆ្ងៃបាត់ខ្លួនគ្មានដំណឹងរហូតមកដល់សព្វថ្ងៃនេះ ។

ជម្លៀសមកដល់ខេត្តកំពង់ស្ពឺមិនបានប៉ុន្មានថ្ងៃផង ឪពុកគាត់ត្រូវបានខ្មែរក្រហមស៊ើបដឹងថាជាអ្នកធ្លាប់ធ្វើការឲ្យរបបលន់នល់ ។ នៅល្ងាចនោះ កងឈ្លបខ្មែរក្រហមមានគ្នាបីនាក់ឈ្មោះ លីម, ឡាត់ និង យួន បានមកហៅឪពុកគាត់ឲ្យទៅដេកពេទ្យ ។ បើទោះបីជាឪពុករបស់គាត់កើតជំងឺហើមក៏ដោយ ក៏អ្នកមីង ហ៊ុលី ដឿជាក់ថាឪពុក គាត់នឹងត្រូវខ្មែរក្រហមយកទៅសម្លាប់ជាមិនខាន ។ ខណៈពេលដែលកំពុងតែរៀបឥវ៉ាន់ដែលមានតែក្រមាមួយ ឪពុកគាត់បាននិយាយទៅកាន់អ្នកមីង ហ៊ុលី ថា «ប៉ាឃ្លានណាស់កូន ។ ឲ្យប៉ាសុំចិញ្ចៀនពេជ្ររបស់ប៉ាយកទៅដូរយកអង្ករហូបបានផង» ។ គាត់មានអារម្មណ៍រន្ធត់និងអាណិតស្រណោះឪពុកគាត់យ៉ាងខ្លាំង ប៉ុន្តែដោយសារតែចង់ទុកចិញ្ចៀននោះជាកេរ្តិ៍ គាត់បាននិយាយថា «ប៉ាយកនាឡិកាទៅដូរទៅ ពីព្រោះខ្ញុំចង់ទុកចិញ្ចៀននេះធ្វើជាកេរ្តិ៍» ។ ក្រោយមក ឪពុកគាត់បានដើរចេញទៅដោយបន្សល់ទុកតែចិញ្ចៀនមួយវង់នោះឲ្យគាត់ ។

ស្មែកឡើងដោយសារតែមិនអស់សង្ឃឹយ បួនប្រុសទីបួនរបស់គាត់បានសុំឈ្លបខ្មែរក្រហមទៅដេកពេទ្យដោយកុហកថាឈឺដើម្បីទៅស៊ើបដំណឹងឪពុកគាត់ ។ ក្រោយពីបានដឹងថាឪពុកគាត់ត្រូវបានខ្មែរក្រហមយកទៅសម្លាប់បួនប្រុសគាត់ក៏ត្រូវបានពេទ្យក្នុងតំបន់បង្ខំតអាហាររហូតដល់ស្លាប់ ។ អ្នកមីង ហ៊ុលី បានដឹងដំណឹងអកុសលទាំងពីរនេះតាមរយៈអ្នកនៅដេកពេទ្យនោះ ។ ការជាត់បង់ដ៏ធំធេងនេះមិនបានធ្វើឲ្យ ហ៊ុលី ទន់ខ្សោយ និងទ្រុឌទ្រោមទេ ។ ផ្ទុយទៅវិញ គាត់បានពង្រឹងស្មារតីឲ្យរឹងប៉ឹងពីព្រោះគាត់បានក្លាយជាមេគ្រួសារដែលត្រូវមើលខុសត្រូវបួនៗទាំងប្រាំនាក់ ។ នៅចុងឆ្នាំ១៩៧៥ ដោយសារតែជំងឺរាតត្បាត និងកង្វះអាហារ ប្រជាជនជារេ្ចើនបានស្លាប់ អាស្រ័យហេតុនេះខ្មែរក្រហមបានជម្លៀសប្រជាជនដែលនៅសេសសល់ទៅសាលាលេខ៥ ស្រុក១៨ ខេត្តកំពង់ឆ្នាំង ។

នៅពេលមកដល់ស្រុក១៨ ខេត្តកំពង់ឆ្នាំង បងប្អូនទាំងប្រាំនាក់របស់គាត់ត្រូវបានបំបែកឲ្យរស់នៅដាច់ដោយឡែកពីគ្នា ។ អ្នកមីង ហ៊ុលី បានចាត់តាំងឲ្យធ្វើការក្នុងកងនារី ចំណែកឯបួនៗរបស់គាត់ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យចូលកងកុមារ ។ គាត់បានរៀបរាប់ថា បើទោះបីជាមានជំងឺកាចសាហាវជារេ្ចើន

បានយារយីជីវិតរបស់ប្រជាជនកម្ពុជាក្នុងរបបខ្មែរក្រហមយ៉ាងណាក្តី ជំងឺ «សតិអារម្មណ៍» របស់ខ្មែរក្រហម ជាជំងឺដ៏យោរយៅបំផុតដែលអាចឆក់យកអាយុជីវិតប្រជាជនកម្ពុជាក្នុងមួយពព្រិចភ្នែក។ គាត់បានខិតខំ ប្រឹងប្រែងធ្វើការដកស្នង ច្រូតកាត់ដោយមិនខ្លាចហត់នឿយ។ បើទោះបីជាធ្លាក់ខ្លួនឈឺដោយសារជំងឺហើមក៏ដោយ ក៏គាត់បានទៅធ្វើការតាមធម្មតាពីព្រោះគាត់ខ្លាចខ្មែរក្រហមចោទប្រកាន់ថាគាត់មានជំងឺសតិអារម្មណ៍។

រស់នៅបែកពីគ្នាមិនបានប៉ុន្មានថ្ងៃផង គាត់បានទទួលដំណឹងថាប្អូនប្រុសគាត់ដែលមានអាយុទើបតែ១៩ឆ្នាំបានស្លាប់ដោយសារតែកងឈ្លបខ្មែរក្រហមវាយក្បាលនឹងកណ្តៀវបណ្តាលឲ្យកកឈាម ធ្លាក់ខ្លួនឈឺស្លាប់។ ដំណឹងមួយមិនទាន់ស្ងប់បានប៉ុន្មានផង ដំណឹងអាក្រក់មួយទៀតក៏បានមកដល់។ ប្អូនស្រីគាត់ដែលនៅក្នុងកងនារីដែរត្រូវបានខ្មែរក្រហមបង្ខំឲ្យឡើងដើមត្នោត។ ដោយសារតែមិនចេះឡើងត្នោត ប្អូនស្រីគាត់បានធ្លាក់ពីលើដើមត្នោត ត្រាំឈាមស្លាប់ទៀត។ ចំណែកប្អូនស្រីពៅរបស់គាត់វិញក៏ត្រូវបានកងឈ្លបខ្មែរក្រហមបង្ខំឲ្យស្នង។ ទើបតែមានអាយុ៦ឆ្នាំ និងមិនចេះស្នង កងឈ្លបនារីខ្មែរក្រហមបានធាក់ប្អូនគាត់ដួលជាក់ចង្កេះ។ មួយរយៈក្រោយមក ប្អូនស្រីគាត់បានស្លាប់ដោយសារមិនមានអាហារហូបនិងជំងឺផង។ ទីបំផុតបងប្អូនជ្រុំបួននាក់របស់អ្នកមីង ហ៊ុយ លី នៅសល់តែពីរនាក់គត់។

ការតស៊ូរស់នៅដោយគ្មានឪពុកម្តាយ បងប្អូនសាច់ញាតិជាទីពឹងបានធ្វើឲ្យអ្នកមីង ហ៊ុយ លី ក្លាយជាស្ត្រីម្នាក់ដ៏រឹងប៉ឹងទាំងផ្នែកកាយ និងសតិអារម្មណ៍។ គាត់មិនបានបណ្តោយឲ្យអតីតកាលដ៏ឈឺចាប់ពីរបបខ្មែរក្រហមមកយាយីជីវិតរបស់គាត់ឡើយ បើទោះបីជាភាពឈឺចាប់នេះបានលង់បន្ទាបគាត់ម្តងម្កាលក៏ដោយ។ ក្រោយពេលកងទ័ពវៀតណាមបានរំដោះប្រទេសកម្ពុជា អ្នកមីង ហ៊ុយ លី បានធ្វើដំណើរមករស់ នៅស្រុកកំណើតវិញ។ គាត់បានចំណាយរយៈពេលពីរឆ្នាំរស់នៅជាមួយនឹងអ្នកភូមិដូចគ្នា មុនពេលដែលគាត់អាចរកមុខរបបចិញ្ចឹមជីវិតខ្លួនឯងបាន។ គាត់បានបញ្ជាក់ថា «ខុនរកស៊ីរបស់ខ្ញុំគឺបានមកពីដើមចេកពីរដើមនៅក្រោយផ្ទះ»។ គាត់បានយកផ្លែចេកដែលទុំដើមយកទៅលក់ ហើយបានជ្រាក់ធ្វើជាខុនមកធ្វើនំអន្សមចេក និងនំអន្សមបិតលក់។ អ្នកមីង ហ៊ុយ លី បាននិយាយថា «ជីវិតជាមនុស្សស្រីរស់នៅតែឯង តែងតែទទួលរងនូវការម៉ាក់ងាយពីអ្នកជិតខាង»។ អាស្រ័យហេតុនេះ គាត់ក៏បានសម្រេចចិត្តរៀបការ។

ក្រោយពេលសម្រាលបានកូនប្រុសមួយ ប្តីរបស់អ្នកមីង ហ៊ុយ លី បានមានសម្ព័ន្ធមេត្រីភាពជាមួយនឹងស្ត្រីម្នាក់ផ្សេងទៀតដោយបោះបង់ចោលគាត់ និងកូនប្រុសតូចគាត់ដែលមានអាយុទើបតែពីរខួប។ អស់រយៈពេលមិនយូរប៉ុន្មាន គាត់បានទទួលដំណឹងតាមរយៈអ្នកជិតខាងថា ប្តីគាត់បានស្លាប់ ដោយសារតែធ្លាក់ពីលើឡាន។ ជាស្ត្រីមេម៉ាយកូនមួយគ្មានទីពឹង អ្នកមីង ហ៊ុយ លី នៅតែតស៊ូចិញ្ចឹមកូនប្រុសរបស់គាត់រហូតដល់ធំដឹងក្តី។ គាត់បានរៀបរាប់ថា «ខ្ញុំបានដាក់កូនខ្ញុំចោលក្នុងធុងអង្ករនៅពេលដែលខ្ញុំដើរលក់នំក្នុងភូមិ។ ពេលលក់នំអស់ ខ្ញុំប្រញាប់ប្រញាល់មកផ្ទះវិញភ្លាមដើម្បីបំបៅដោះកូន។ ពេលត្រូវការទៅដងទឹកពីទន្លេមកប្រើប្រាស់ម្តងៗ ខ្ញុំបានចងដើងកូនខ្ញុំជាប់នឹងដើងត្រែ ព្រោះខ្លាចវាមានគ្រោះថ្នាក់ពេលខ្ញុំមិននៅជាមួយ»។

ត្រប់ស្ត្រីកម្ពុជាដែលរួចរស់រានមានជីវិតពីរបបខ្មែរក្រហមទាំងអស់សុទ្ធតែទទួលរងទុក្ខលំបាកវេទនាខុសប្លែកៗពីគ្នា។ សម្រាប់អ្នកមីង ហ៊ុយ លី គាត់បានចាត់ទុកការលំបាកនេះជាមេរៀនជីវិតមួយដ៏ឈឺចាប់ ប៉ុន្តែគាត់មិនចុះញ៉ែមទន់ខ្សោយតាមភាពឈឺចាប់នេះទេ។ មកដល់សព្វថ្ងៃនេះ គាត់នៅតែដើរតួជាមេ គ្រួសារដ៏រឹងមាំម្នាក់រកស៊ីចិញ្ចឹមកូនប្រុសម្នាក់ កូនប្រសាស្រី និងចៅប្រុសបីនាក់។ អ្នកមីង ហ៊ុយ លី ប្រកបរបបជាអ្នកលក់នំអាកោ និងលក់ឥវ៉ាន់បន្តិចបន្តួចរួមមានថ្នាំសង្កូវ អង្ករ ធ្យូង ជាដើម។ សព្វថ្ងៃនេះគាត់មិនគិតអ៊ីក្រៅពីរបបរកស៊ីរបស់គាត់ដើម្បីលើកស្ទួយជីវភាពគ្រួសារ បើទោះបីជាគាត់មានជំងឺ និងចាស់ជរាក៏ដោយ។

ទោះបីជាមមាញឹកនឹងមុខរបបចិញ្ចឹមជីវិតយ៉ាងណាក្តី អ្នកមីង ហ៊ុយ លី បានតាមដានស្តាប់ដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមតាមវិទ្យុ។ គាត់បានដឹងថា ឌុច ដែលជាប្រធានគុកទួលស្លែងត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ចំណែកឯមេដឹកនាំខ្មែរក្រហមបួននាក់ទៀតកំពុងតែត្រូវបានតុលាការខ្មែរក្រហមកាត់ទោស។ ជួនកាល គាត់បានគិតថា គាត់ជាមនុស្សមានកម្មកាលពីជាតិមុន ដូច្នេះហើយបានជាជាតិនេះគាត់

ជានរណាម្នាក់ដែលបានរៀបរាប់ខាងលើ ឬពីដំណឹងនៃការស្វែងរកនេះ សូមទាក់ទងមកទូរស័ព្ទលេខ ០១២ ៣៨៦ ១៧២, ០១៧ ៧២២ ៨៨៧ ឬទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជា តាមរយៈអាសយដ្ឋានផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ក្រុងភ្នំពេញ ទូរស័ព្ទលេខ ០១៦ ៨៧៦ ៦៩២ ។

សូមអរគុណ ។

ជានរណាម្នាក់ដែលបានរៀបរាប់ខាងលើ ឬពីដំណឹងនៃការស្វែងរកនេះ សូមទាក់ទងមកទូរស័ព្ទលេខ ០១២ ៣៨៦ ១៧២, ០១៧ ៧២២ ៨៨៧ ឬទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជា តាមរយៈអាសយដ្ឋានផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ក្រុងភ្នំពេញ ទូរស័ព្ទលេខ ០១៦ ៨៧៦ ៦៩២ ។

សូមអរគុណ ។

«ប្តីខ្ញុំស្លាប់ដោយសារតែមួកកន្តឹប»

នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២ មជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំការផ្សាយបន្តដ្ឋាល់ពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាក់ទងទៅនឹងការផ្តល់សក្ខីកម្មរបស់សាក្សី ឌុច ប្រធានមន្ទីរស-២១ (គុកទួលស្លែង) ក្នុងការកាត់ទោសសំណុំរឿង០០២ ដែលមានជនជាប់ចោទ នួន ជា ប្រធានសភាជាតិក្នុងរបបកម្ពុជាប្រជាធិបតេយ្យ, ខៀវ សំផន គណៈប្រធានរដ្ឋ, អៀង សារី រដ្ឋមន្ត្រីក្រសួងការបរទេស នៅវិហារនន្ទុនណាអ៊ីម ស្ថិតនៅសង្កាត់ច្រាំងចំរេះ ខណ្ឌឫស្សីកែវ ភ្នំពេញ ។

នៅក្នុងចំណោមជនជាតិចាមដែលបានចូលរួមទស្សនាការផ្សាយបន្តដ្ឋាល់នេះ យ៉ែប រ៉ូគី អាយុ៥២ឆ្នាំ ដែលស្គាល់មេដឹកនាំខ្មែរក្រហមតិចតួចក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ និងក្នុងពេលផ្សាយបន្តដ្ឋាល់ បានរៀបរាប់ថា ការដាក់ទោស ឌុច និងការកាត់ទោសមេដឹកនាំខ្មែរក្រហមទាំងនេះ មិនស្មើនឹងការបាត់បង់ប្តីរបស់គាត់ និងក្រុមគ្រួសារគាត់ក្នុងរបបនោះទេ ។ រ៉ូគី បន្តថា ខ្មែរក្រហមបានយកប្តីគាត់ទៅសម្លាប់ដោយសារតែមួកកន្តិបមួយប៉ុណ្ណោះ ហើយគាត់ត្រូវទទួលបន្ទុកចិញ្ចឹមកូនបួននិងឪពុក ។

រ៉ូគី មានស្រុកកំណើតនៅភូមិពពាលខែ ឃុំដួង ស្រុកពញាឮ ខេត្តកណ្តាល ។ រ៉ូគី មានបងប្អូនបួននាក់ ហើយគាត់ជាកូនច្បង ។ រ៉ូគី មានឪពុកឈ្មោះ គិ យ៉ែប ប្រកបរបរនេសាទត្រី និងធ្វើចម្ការ ។ ចំណែកម្តាយឈ្មោះ អ៊ុត កាស់ មានមុខរបរលក់ត្រី ។ នៅពេលអាយុបាន៨ឆ្នាំ រ៉ូគី បានចូលរៀនភាសាចាមនៅសាលាមួយក្នុងភូមិពពាលខែ ហើយមួយរយៈក្រោយមក គាត់ក៏ឈប់រៀននៅពេលម្តាយរបស់គាត់ស្លាប់ ។ រ៉ូគី ត្រូវមកជួយការងារផ្ទះដាំបាយ និងមើលប្អូនតូចៗវិញ ។

ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ ឪពុករបស់ រ៉ូគី បានប្រមូលរបស់របរនាំកូនភៀសខ្លួនមករស់នៅសង្កាត់ច្រាំងចំរេះ ក្រុងភ្នំពេញវិញ ព្រោះមានកងទ័ពវៀតកុងបានលួចចូលមកដុតស្ថានីយប្រេង និងឃ្លាំងទំនិញនៅភូមិពពាលខែ ហើយនៅពេលនោះ កងទ័ព លន់ នល់ បានបាញ់សម្លាប់ទ័ពវៀតកុងម្នាក់នៅមុខផ្ទះយាយរបស់ រ៉ូគី ។

រ៉ូគី ជួយការងាររកស៊ីឪពុករបស់គាត់រហូតដល់ខ្មែរក្រហមរំដោះបានទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ រយៈពេលបីថ្ងៃក្រោយមក កងយោធាខ្មែរក្រហមបានបញ្ជូន រ៉ូគី និងក្រុមគ្រួសារចាកចេញពីផ្ទះរយៈពេលបីថ្ងៃដើម្បីរៀបចំទីក្រុងឡើងវិញ ។ នៅពេលនោះ ដោយសារមិនមានអ្នកជួយរៀបចំរបស់របរ ចំណែកប្អូនៅតូចទៀតនោះ ទើប រ៉ូគី ប្រមូលបានតែឆ្នាំងជាយពីរ ស្លាបព្រា ធុងដាក់ទឹក និងខោអាវពីរបីកំប្លេប៉ុណ្ណោះ ។

ឪពុក រ៉ូគី បាននាំកូនតូចៗធ្វើដំណើរទៅរស់នៅខេត្តក្នុងរយៈពេលបីថ្ងៃ ទើបកងយោធាខ្មែរក្រហមដែលយាមការពារនៅទីនោះ ដឹកក្រុមគ្រួសារគាត់តាមរថយន្តយោធាទៅដាក់នៅភូមិឃុំហង្សសំណំ ស្រុកឱរ៉ាល់ តំបន់២៧ ខេត្តកំពង់ស្ពឺ ក្រោមការគ្រប់គ្រងរបស់កម្មាភិបាលស្រុកឈ្មោះ ឆើម ដែលជាមនុស្សសូតបូត ។

ទៅដល់ភ្លាម កម្មាភិបាលស្រុកឈ្មោះ ឆើម បានបែងចែកក្រុមគ្រួសារ រ៉ូគី ឲ្យរស់នៅជាក្រុម ដោយក្នុងមួយក្រុមមានដប់គ្រួសារ បន្ទាប់មកបានចាត់តាំង រ៉ូគី ឲ្យចូលកងចល័តធ្វើការងារ

លើក ភ្លឺស្រែ ស្ងួតស្រួវ ។ រ៉ូគី បានរៀបរាប់ថា កម្មាភិបាលតំបន់នោះមិនបានដកទ្រព្យសម្បត្តិពីគ្រួសារគាត់ ឬបង្ខំឲ្យគាត់ធ្វើការងារធ្ងន់ ហួសម៉ោង ឬហាមប្រាមការគោរពប្រតិបត្តិសាសនាទេ ។ ប៉ុន្តែផ្ទុយទៅវិញ កម្មាភិបាលនោះបានផ្តល់អង្ករ នំចំណី និងសាច់ឲ្យគាត់ហូបឆ្អែតទៀតផង ។ មិនត្រឹមតែប៉ុណ្ណោះ រ៉ូគី តែងតែឃើញគណៈស្រុកឈ្មោះ ឆើម បានចុះទៅមើលប្រជាជនធ្វើការងារ និងហូបបាយជាមួយប្រជាជននៅក្នុងកងតែម្តង ។ ដោយសារអំពើល្អទាំងនេះ ទើបគ្រួសារ រ៉ូគី ព្រមទាំងប្រជាជនដែលជម្លៀសទៅដល់ថ្មីទាំងបានគោរពស្រលាញ់ និងរាប់អាន ឆើម ត្រប់ៗគ្នា ។

ក្រោយមក ដោយសារតែ ឆើម កាន់តែមានការគាំទ្រពីប្រជាជនច្រើន ទើបអង្គការដកគាត់ចេញរួចផ្ទាស់ សែម ឲ្យមកគ្រប់គ្រងជំនួសវិញ ។ បន្ទាប់ពីទទួលមុខតំណែងភ្លាម សែម ក៏ចាប់ផ្តើមរឹតបណ្តឹងប្រជាជន ដោយដកហូតរបរប្រើប្រាស់នៅតាមផ្ទះ ប្រមូលបងប្អូនជនជាតិចាមទាំងអស់ឲ្យមកហូបនៅក្នុងសហករណ៍ជាមួយខ្មែរ (ដែលមួយភាគច្រើនធ្វើអំពីសាច់ជ្រូក) និងហាមប្រាប់ការថ្វាយបង្គំដែលជាទំនៀមទម្លាប់ក្នុងសាសនាឥស្លាម ។ ឃើញដូច្នេះ ជនជាតិចាមនៅក្នុងភូមិនាំគ្នាតវ៉ាមិនព្រមមកហូបរួមចំណែកបងប្អូនមួយចំនួនបានលួចទៅថ្វាយបង្គំនៅក្នុងព្រៃវិញ ។ ប៉ុន្តែ អ្នកថ្វាយបង្គំទាំងនោះ ត្រូវបានកងឈ្លបខ្មែរក្រហមហៅមកព្រមាន ។

នៅពេលនោះ ឪពុករ៉ូគី ត្រូវសែមផ្ញាស់ពីឃុំហង្សសំណាំឲ្យទៅដាំអំពៅ លូង បន្ទែ និងទៅរកត្រីដើម្បីដុតដុំរោងជាយរួមនៅភូមិចំប៉ីដីមាសវិញ ចំណែក រ៉ូគី នៅឃុំហង្សសំណាំដដែល ។ រ៉ូគី ធ្វើការនៅកងចល័តភូមិជានមួយរយៈប្រធានសហករណ៍ បានជ្រើសរើសគាត់ឲ្យទៅធ្វើការនៅក្នុងកងចល័តតំបន់១៥ (ក្រោយមក អង្គការក៏កាត់បញ្ចូលតំបន់២៧ ទៅក្នុងតំបន់១៥នេះទៀត) រួចបញ្ជូនគាត់ឲ្យធ្វើការនៅដំណាក់ស្មាច់ ក្រោមការគ្រប់គ្រងរបស់យាយ មាស (ពិការភ្នែកម្ខាង និងជាអតីតយុទ្ធនារីខ្មែរក្រហម) ជាប្រធានកងចល័តតំបន់វិញ ។

រ៉ូគី ធ្វើការនៅសហករណ៍ស្មាច់ បានរយៈពេលប្រាំមួយខែ ស្រាប់តែមានយោធាម្នាក់បានមកប្រាប់គាត់ឲ្យទៅវត្តគ្រួស (ជាមន្ទីរតំបន់) ដោយមិនបានប្រាប់ពីមូលហេតុអ្វីទាំងអស់ ។ ប៉ុន្តែពេលនោះ ប្រធានកងរបស់គាត់នៅទីនោះ បានលួចប្រាប់គាត់ថា អង្គការមកស្នើគាត់ទៅរៀបការ ។ ពេលឮសម្តីនេះ រ៉ូគី មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ប៉ុន្តែគាត់មិនហ៊ានប្រកែកទេ ។

រ៉ូគី មិនបានដឹងឈ្មោះ និងតួនាទីប្តីគាត់ទេនៅពេលនោះ

អ្នកភូមិជនជាតិចាមអានឯកសារ មុននឹងទស្សនាការផ្សាយបន្តផ្ទាល់ការកាត់ទោសសំណុំរឿង ០ ០២

រហូតក្រោយមកទើប រ៉ូគី ដឹងថា ប្តីគាត់ឈ្មោះ ឡោះ ស៊ើ រស់នៅភូមិជ្រៃអណ្តែត ស្រុកពញាឮ និងត្រូវជាបងបួនដឺដួនមួយខាងឪពុក ដោយមានឪពុកម្តាយទាំងសងខាងដឹងឮ និងស្នើសុំឱយាយមាស ប្រធានកងចល័តតំបន់។ ប្តីរបស់ រ៉ូគី ជាអ្នកដែលរៀនសូត្រភាសាខ្មែរបានជ្រៅជ្រះ និងជានិស្សិតដែលត្រៀមទៅរៀននៅប្រទេសម៉ាឡេស៊ី សម័យ លន់ នល់។

រ៉ូគី បានរៀបការនៅវត្តគ្រួសជាមួយប្តី ដោយមានតែការសែនព្រេនបន្តិចបន្តួច និងការឡើងបេដ្ឋា ក្រោមការចូលរួមពីប្រធានកងចល័ត។ បន្ទាប់ពីរៀបការរួច រ៉ូគី បានយកក្រណាត់សារុំពណ៌ស្វាបកំភេមដែលគាត់លាក់ទុកតាំងពីពេលជម្លៀសចេញពីភ្នំពេញ មកកាត់ម្លូកកាតឹបឲ្យប្តីពាក់។ ក្រោយពីរៀបការរួច ប្រធានកងចល័តបានអនុញ្ញាតឲ្យរ៉ូគី និងប្តីឈប់សម្រាករយៈពេលបីថ្ងៃ បន្ទាប់មកទើបប្រធានកងផ្ញាស់គាត់ឲ្យទៅរស់នៅជាមួយឪពុកក្មេកនៅឃុំហង្ស ស្រុកឱរ៉ាល់វិញ។ នៅទីនោះ រ៉ូគី ជាមួយប្តីបានចូលធ្វើការនៅកងចល័ត ដោយធ្វើការងារដូចជា ដកសំណាបសូង លើកភ្ជួស្រែ និងប្រមូលដីដាក់ស្រែ។

រ៉ូគី នៅចងចាំថា រាល់ថ្ងៃប្តីរបស់គាត់បានពាក់ម្លូកដែលគាត់ដេរឲ្យទៅធ្វើការ ហើយកម្មាភិបាលដែលគ្រប់គ្រងនៅតាមកងនិងសហករណ៍តែងតែសុំម្លូកពីប្តីគាត់ ព្រោះម្លូកនោះមានពណ៌ស្រស់ស្អាត។ ប៉ុន្តែ រៀងរាល់ពេលសុំម្តងៗ ប្តីរបស់គាត់បានបដិសេធ ដោយប្រាប់ថា ជាម្លូកដែលគាត់ស្រឡាញ់ និងប្រពន្ធគាត់ដេរឲ្យដាល់ដៃ។ រ៉ូគី បញ្ជាក់ថា មានប្រធានកងខ្លះដែលសុំម្លូកពីប្តីគាត់មិនបានខឹងប្តីរបស់គាត់ ហើយបាននិយាយប្រាប់ប្រជាជននៅក្នុងភូមិថា បើមិត្តហន (សម័យនោះកម្មាភិបាល និងប្រជាជនក្នុងភូមិ មិនហៅឈ្មោះប្តី រ៉ូគី ថា ស៊ើ ទេ គឺ ហៅតែមិត្តហន។) មិនឲ្យម្លូកនោះទេ ថ្ងៃណាមួយ អង្គការយកទៅសម្លាប់ចោលមិនខាន។

ដោយដឹងរឿងនេះមុន ប្តី របស់ រ៉ូគី បានរៀបចំខោអាវដើម្បីរត់ចេញពីភូមិ ប៉ុន្តែឪពុកគាត់ឃាត់ ព្រោះខ្លាចឈ្លបចាប់ទាំងក្រុមគ្រួសារ។ រហូលដល់រដូវប្រមូលផល ប្រធានកងឈ្មោះ ហេង បានឲ្យឈ្លបម្នាក់មកហៅប្តីរបស់ រ៉ូគី ទៅដឹកសង្កុំសី និងថ្នាំពេទ្យយកមកភូមិវិញ។ ប្តីរបស់ រ៉ូគី មិនបានប្រកែកនឹងបញ្ជានេះទេ ហើយគាត់បានមកផ្តាំ រ៉ូគី ថាគាត់នឹងត្រឡប់មកផ្ទះពេលហូបបាយថ្ងៃត្រង់វិញ។

មួយថ្ងៃក្រោយមក ស្រាប់តែយាយជាប្រធានរោងបាយសហករណ៍ឃុំ ដែលបានរាប់អាន និងស្រឡាញ់ប្តី រ៉ូគី ដូចជាកូនចៅ បានមកប្រាប់ រ៉ូគី ថាប្តីឯង និងតាម្នាក់ទៀតដែលបរទេះទៅជាមួយគ្នា ត្រូវកងឈ្លបវាយសម្លាប់នៅក្រោយពេទ្យតាំងជិបងហើយ។ ក្រោយនិយាយចប់ យាយចុង ភៅ បានផ្តែផ្តាំ រ៉ូគី កុំឲ្យយំ និងត្រូវទៅធ្វើការងារ ព្រោះខ្លាចឈ្លបចោទប្រកាន់ទាំងគ្រួសារទៀត។ ទោះបីជាមានការផ្តែផ្តាំយ៉ាងនេះក៏ដោយ ក៏ រ៉ូ គី នៅតែលួចយំស្រណោះប្តីរបស់គាត់ដែរ ប៉ុន្តែគាត់ក៏មិនដែលហ៊ានទៅសុំបបួរដំណឹងពីប្តីគាត់ទេ។

ក្រោយពីសម្លាប់ប្តី រ៉ូគី រួច រ៉ូគី ឃើញយោធាខ្មែរក្រហមបានដឹកប្រជាជនថ្មីមកពីខេត្តស្វាយរៀង រាប់រយនាក់ រួចបញ្ជូនឲ្យប្រជាជនទាំងនោះសង់ខ្ទមរស់នៅរៀងខ្លួន។ ប៉ុន្តែមួយថ្ងៃ ក្រោយមក ស្រាប់តែ រ៉ូគី ឃើញយោធាខ្មែរក្រហមចាប់ចងស្ថាបសេកប្រជាជនទាំងនោះ រួចបណ្តើរយកទៅសម្លាប់ទាំងអស់។ បន្ទាប់ពីសម្លាប់ប្រជាជនថ្មីទាំងនោះរួច កម្មាភិបាលតំបន់ប្រកាសបញ្ចូលក្រុមគ្រួសារ រ៉ូគី និងគ្រួសារដែលជម្លៀសទៅតំបន់នោះតាំងពីឆ្នាំ១៩៧៥ ទៅជាប្រជាជនមូលដ្ឋានវិញ។ រ៉ូគី រៀបរាប់ថា នៅពេលនោះទោះបីគាត់ជាប្រជាជនមូលដ្ឋានក៏ដោយ ក៏គាត់ត្រូវធ្វើការធ្ងន់ធ្ងរដែរ ហើយពេលខ្លះគាត់ត្រូវធ្វើរហូតដល់យប់ជ្រៅទៀត។ រ៉ូគី បន្តថា ពេលខ្លះគាត់អត់អាហាររយៈពេលពីរថ្ងៃ។

រហូតដល់ចុងឆ្នាំ១៩៧៨ នៅក្នុងកងចល័តរបស់ រ៉ូគី ចាប់ផ្តើមច្របូកច្របល់ ព្រោះបានឮដំណឹងថាកងទ័ពវៀតណាមបានវាយចូលកំពង់ស្ពឺហើយ។ ពេលនោះ រ៉ូគី បានរត់ទៅជួបឪពុកនៅភូមិចំប៉ីដីមាស រួចហើយក៏នាំក្រុមគ្រួសារត្រឡប់មករស់នៅសង្កាត់ច្រាំងចំរេះ ខណ្ឌឫស្សីកែវ ភ្នំពេញ។

សព្វថ្ងៃ រ៉ូគី ជាស្ត្រីមេម៉ាយ និងមានកូនបួននាក់។ រ៉ូគី បានបញ្ជាក់ថា ពេលរំឭកឡើងវិញរបស់ប្តីគាត់ និងក្រុមគ្រួសារម្តងៗ គាត់តែងយំ និងធ្វើឲ្យអារម្មណ៍របស់គាត់គាន់តឹង។ ចុងក្រោយ រ៉ូគី បន្តែមថា ប្តីរបស់គាត់ស្លាប់ដោយសារតែមួកមួយប៉ុណ្ណោះ។

សោម ប៊ុនថន

សមភាពរវាងភាគី និងឯករាជ្យភាពរបស់តុលាការក្នុងការស៊ើបអង្កេតលើសំណុំរឿង០០២នៅអង្គចៅក្រមស៊ើបអង្កេតក្នុងតុលាការកម្ពុជា

សេចក្តីជំទាស់ដោយក្រុមមេធាវីការពារក្តីទាក់ទងនឹងតម្លាភាព និងឯករាជ្យភាពក្នុងការស៊ើបអង្កេតគឺធ្វើឡើងដោយផ្អែកទៅលើការទទួលខុសត្រូវរបស់សហចៅក្រមស៊ើបអង្កេតក្នុងការយកចិត្តទុកដាក់លើកិច្ចការរបស់ខ្លួនដើម្បីស្វែងរកការពិត។ ក្រុមមេធាវីការពារក្តីជនជាប់ចោទបានធ្វើការស្នើសុំ និងជំទាស់ជាច្រើនលើកច្រើនសារដោយចោទប្រកាន់ការិយាល័យសហចៅក្រមស៊ើបអង្កេតថាទទួលឥទ្ធិពល ជ្រៀតជ្រែកពីផ្នែកនយោបាយ និងអសមត្ថភាពក្នុងការបំពេញកិច្ចការរបស់ខ្លួន។ សេចក្តីជំទាស់របស់ក្រុមមេធាវីការពារក្តីជនជាប់ចោទពីការជ្រៀតជ្រែកផ្នែកនយោបាយ និងភាពលម្អៀងភាគច្រើនគឺធ្វើឡើងដោយមិនសមហេតុផល ហើយការស្នើសុំឲ្យមានការស៊ើបអង្កេតបន្ថែមទៀតក៏មិនសូវមានសារសំខាន់ដែរ។

ជាឧទាហរណ៍ ក្រុមមេធាវីការពារក្តីរបស់ អៀង សារី បានស្នើសុំឲ្យមានការស៊ើបអង្កេតលើអ្នក ស៊ើបអង្កេត ស៊ូ វ៉ា ហេឌើ ដើម្បីសម្រេចថាតើលោកគឺជាភ្នាក់ងារសម្ងាត់ដែលធ្វើការឲ្យភ្នាក់ងារ សេ.អ៊ី.អា របស់សហរដ្ឋអាមេរិកដែរឬទេ។ ចំណែកឯក្រុមមេធាវីការពារក្តីរបស់ នួន ជា វិញ បានស្នើសុំឲ្យសម្ភាសន៍បុគ្គលិករដ្ឋាភិបាលទាំងអស់ដែលជាអតីតកម្មាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យដើម្បីបញ្ជាក់ថាតើសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន កំពុងតែការាំងដំណើរការស៊ើបអង្កេតដើម្បីការពារមន្ត្រីនយោបាយណាម្នាក់មែនដែរឬទេ។ យ៉ាងណាមិញ មានបញ្ហាមួយចំនួនដែលក្លាយជាមូលហេតុធ្វើឲ្យមានការព្រួយបារម្ភលើគុណភាព និងជម្រៅនៃការស៊ើបអង្កេតលើសំណុំរឿង០០២។

តុលាការខ្មែរក្រហមត្រូវបានតាក់តែងឡើងដោយប្រព័ន្ធច្បាប់មួយដែលហៅថាប្រព័ន្ធច្បាប់ស៊ីវិល អ៊ិនហ្គីស៊ីតូរៀល (inquisitorial civil law system) ដែលមានលក្ខណៈដូចពីប្រព័ន្ធច្បាប់ខុសគ្នាឡើយ អេតវឺសារៀល (adversarial common law system) ដែលតុលាការអន្តរជាតិភាគច្រើនបានអនុវត្ត។ ភាពខុសគ្នាសំខាន់គឺថាប្រព័ន្ធ អ៊ិនហ្គីស៊ីតូរៀល ផ្តល់សិទ្ធិអំណាចពេញទីក្នុងការស៊ើបអង្កេតទៅឲ្យចៅក្រមស៊ើបអង្កេត។ ចៅក្រមនេះមានភារកិច្ចធ្វើការស្វែងរកការពិតទាក់ទងនឹងបទចោទប្រកាន់ ហើយក៏ត្រូវបានរំពឹងថានឹងបំពេញកិច្ចការរបស់ខ្លួនដើម្បីជាប្រយោជន៍ដល់ភាគីទាំងអស់ដោយមិនលម្អៀងទៅលើព្រះរាជអាជ្ញា ឬក៏មេធាវីការពារក្តីឡើយ។

នៅឯតុលាការខ្មែរក្រហម មេធាវីការពារក្តីជនជាប់ចោទមិនត្រូវបានអនុញ្ញាតឲ្យចូលរួមនៅក្នុងការសម្ភាសសាក្សីទេ ហើយក៏មិនត្រូវបានអនុញ្ញាតឲ្យចេញសេចក្តីណែនាំណាមួយដល់ដំណើរការស៊ើបអង្កេតរបស់តុលាការដែរ។ នៅក្នុងអំឡុងអង្គជំនុំជម្រះក្តី ចៅក្រមនឹងធ្វើការពិចារណាតែលើភ័ស្តុតាងដែលចៅក្រមស៊ើបអង្កេតបានរកឃើញតែប៉ុណ្ណោះ ហើយដាក់បញ្ចូលភ័ស្តុតាងទាំងនោះទៅក្នុងសំណុំរឿង។ ដោយសារតែចៅក្រមបានទទួលនូវឆន្ទានុសិទ្ធិយ៉ាងពេញលេញ នោះប្រព័ន្ធច្បាប់ អ៊ិនហ្គីស៊ីតូរៀលតម្រូវឲ្យចៅក្រមស៊ើបអង្កេតគឺជាបុគ្គលដែលមានសមត្ថភាពខ្ពស់ ហើយគ្មានភាពលម្អៀងដែលមិនទទួលរង្គការរិះគន់។

គោលការណ៍សំខាន់នៃសមភាពរវាងភាគីធានាថា ភាគីនីមួយៗទទួលបានឱកាសសមរម្យមួយក្នុងការលើកឡើងពីអំណះអំណាងផ្ទាល់របស់ខ្លួន ហើយមិនត្រូវបានកេងប្រយោជន៍ដោយភាគីតតាំងណាមួយឡើយ។ គោលការណ៍នេះដើរតួយ៉ាងសំខាន់នៅក្នុងបញ្ហាស្មុគស្មាញ និងក្នុងមជ្ឈដ្ឋានច្បាប់ដែលមានជាប់ពាក់ព័ន្ធនឹងបញ្ហានយោបាយ។ ចៅក្រមត្រូវតែបំពេញតួនាទីរបស់ខ្លួនដោយធានាថាមេធាវីការពារក្តីជនជាប់ចោទមិនត្រូវបានកេងប្រយោជន៍ ហើយធ្វើយ៉ាងណាធានាថាព្រះរាជអាជ្ញា និង មេធាវី

ការពារក្តីជនជាប់ចោទមានឱកាសស្មើគ្នាចំពោះអង្គជំនុំជម្រះសាលាដំបូង ។

ប៉ុន្តែ ក្រុមមេធាវីការពារក្តីរបស់ជនជាប់ចោទជំទាស់ថាការិយាល័យសហចៅក្រមស៊ើបអង្កេតមិនបានគោរពដល់ប្រយោជន៍របស់ជនជាប់ចោទទេ ។ មេធាវីសង្ឃឹមថាភ័ស្តុតាងដែលត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿងស៊ើរតែទាំងអស់គឺត្រូវបានរកឃើញនៅចំពោះចៅក្រមនោះត្រូវបានទទួលស្គាល់ជាផ្លូវការ ហើយតុលាការខ្មែរក្រហមត្រូវបានតាក់តែងឡើងក្នុងគោលបំណងចោទប្រកាន់ជនជាប់ចោទក្នុងសំណុំរឿង០០២ ដោយផ្អែកតែលើភ័ស្តុតាងតែមួយនោះ ។ ក្រុមមេធាវីការពារក្តីជនជាប់ចោទអះអាងថាការិយាល័យសហចៅក្រមស៊ើបអង្កេតបានអាក់ខានមិនបានពិនិត្យមើលលើប្រភពឯកសារបញ្ជាក់ពីភាពត្រឹមត្រូវរបស់ឯកសារនិងវត្ថុភស្តុតាងរបស់សាក្សី ហើយស្វែងរកភ័ស្តុតាងដែលហុចជាប្រយោជន៍ដល់ជនជាប់ចោទឡើយ ។ ជំនួសឲ្យការអនុញ្ញាតទទួលបានឱកាសក្នុងការបញ្ចេញមតិយោបល់ ឬដោះស្រាយភាពទន់ខ្សោយទាំងអស់នេះ មេធាវីការពារក្តីជនជាប់ចោទត្រូវបានហាមឃាត់មិនឲ្យធ្វើការស៊ើបអង្កេតណាមួយ ឬ ចូលរួមនៅក្នុងបទសម្ភាសជាមួយសាក្សីឡើយ ។ បន្ថែមលើនេះ ក្រុមមេធាវីការពារក្តីជនជាប់ចោទបានតវ៉ាថា រាល់ការស្នើសុំទាំងអស់របស់ក្រុមមេធាវីដែលឲ្យការិយាល័យស៊ើបអង្កេតធ្វើការស៊ើបអង្កេតបន្ថែមត្រូវបានច្រានចោល ។

ជាការឆ្លើយតបនឹងការតវ៉ាទាំងអស់របស់ក្រុមមេធាវីការពារក្តីជនជាប់ចោទរបស់តុលាការខ្មែរក្រហម ព្រះរាជអាជ្ញាជំទាស់ថាក្រុមមេធាវីការពារក្តីជនជាប់ចោទបានទទួលឱកាសគ្រប់គ្រាន់ក្នុងការកែប្រែភ័ស្តុតាងដែលបានដាក់បញ្ចូលទៅក្នុងសំណុំរឿងរួចរាល់ហើយដែលភាគីទាំងអស់អាចពិនិត្យមើលបានដោយស្មើភាព ។ សហព្រះរាជអាជ្ញាអះអាងថាភាគពូកិច្ចរបស់ក្រុមមេធាវីការពារក្តីជនជាប់ចោទគឺធ្វើការវាយតម្លៃថាតើព័ត៌មានណាដែលហុចជាប្រយោជន៍ដល់កូនក្តីរបស់ខ្លួន ។ អ្នកតាមដានអង្គជំនុំជម្រះរបស់តុលាការខ្មែរក្រហមមួយចំនួនបានណែនាំថាជាក់ស្តែងមានភ័ស្តុតាងមួយចំនួនដែលជួយគាំទ្រដល់រឿងក្តីរបស់ជនជាប់ចោទ ប៉ុន្តែមេធាវីជនជាប់ចោទមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការវាយតម្លៃលើព័ត៌មានដែលទទួលបានទាំងអស់នោះ ។ បន្ថែមលើនេះ សហព្រះរាជអាជ្ញាបានអះអាងថាការស៊ើបអង្កេតពិតជាធ្ងើឆ្ងើងដោយភាពល្អិតល្អន់ជាទីបំផុត ហើយថាវត្ថុតាងរបស់សាក្សីគួរតែត្រូវដាក់បញ្ចូលជាភ័ស្តុតាង តែម្តងដោយមិនចាំបាច់ផ្តល់សិទ្ធិដាច់ខាតមួយឲ្យជនជាប់ចោទពិនិត្យមើលលើវត្ថុតាងនោះឡើយនៅក្នុងពេលជំនុំជម្រះក្តី ។ តាមទស្សនៈរបស់សហព្រះរាជអាជ្ញា ជនជាប់ចោទត្រូវបានអនុញ្ញាតឲ្យចូលរួមដំណើរការស៊ើបអង្កេតដោយមានឱកាសស្នើសុំឲ្យមានការស៊ើបអង្កេត និងទទួលបានឱកាសក្នុងការសួរដេញដោលលើភ័ស្តុតាង និងវត្ថុតាងរបស់សាក្សីតាមរយៈសិទ្ធិរបស់ខ្លួនក្នុងការដាក់បណ្តឹងខ្ទរណ៍ដែលនឹងត្រូវសម្រេចដោយឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត ។

ក្នុងការពិចារណាសេចក្តីជំទាស់បែបនេះ វាគួរតែសង្កត់ធ្ងន់ថាសហចៅក្រមស៊ើបអង្កេតមានសិទ្ធិអំណាចពេញលេញក្នុងការស៊ើបអង្កេត ហើយថាគ្មានការរំលោភណាមួយបានកើតមានឡើងដោយសារតែគ្មានការចូលរួមពីក្រុមមេធាវីការពារក្តីជនជាប់ចោទនៅក្នុងដំណើរការស៊ើបអង្កេតទេ ។ យ៉ាងណាមិញ ប្រសិនបើការចោទប្រកាន់គឺជាការពិត នោះមានន័យថាក្រុមមេធាវីការពារក្តីជនជាប់ចោទបានចូលរួមនៅក្នុងអង្គជំនុំជម្រះក្តីដោយគ្មានសិទ្ធិការពារខ្លួន ។ ជាក់ស្តែង ក្រុមមេធាវីការពារក្តីជនជាប់ចោទមិនខាន់បានទទួលឱកាសដើម្បីសួរដេញដោលសាក្សី និងភ័ស្តុតាងដែលដាក់ប្រឆាំងមកលើកូនក្តីរបស់ខ្លួននៅឡើយទេ ហើយការស៊ើបអង្កេតវិញក៏មានតម្លាភាពពេញលេញដែរ ហើយក្រុមមេធាវីការពារក្តីក៏មិនខាន់ទទួលបានការពិចារណាដោយសមភាពក្នុងការបញ្ចេញមតិយោបល់លើការស៊ើបអង្កេតលើភ័ស្តុតាងដែលជាប្រយោជន៍ដល់ជនជាប់ចោទដែរ ។

បន្ថែមលើនេះ តុលាការ ខ្មែរក្រហមប្រហែលជាខ្វះខាតនូវធនធានគ្រប់គ្រាន់ដើម្បីដោះស្រាយបញ្ហានៅក្នុងការស៊ើបអង្កេត ។ ប៉ុន្តែ វាមិនអាចទៅរួចទេដែលថាបុគ្គលដែលនៅក្រៅអង្គជំនុំជម្រះរបស់តុលាការមកតួសបញ្ជាក់ថាតើការចោទប្រកាន់បែបនេះគឺជាការពិតដែរឬយ៉ាងណានោះ ពីព្រោះថាការស៊ើបអង្កេតត្រូវបានអនុវត្តដោយការិយាល័យសហចៅក្រមស៊ើប

អង្កេតដោយលាក់ការសម្ងាត់ជាទីបំផុត ។

នេះគឺជាប្រភេទនៃទ្រឹស្តីប្រឆាំងមួយដែលអំពាវនាវឲ្យមានការផ្តោតយកចិត្តទុកដាក់នៅពេលដែលមានការរិះគន់ពីប្រព័ន្ធច្បាប់យុត្តិធម៌ព្រហ្មទណ្ឌ អ៊ុនហ៊ីសុីតូរៀល ទាក់ទងនឹងភាពទន់ខ្សោយរបស់ប្រព័ន្ធច្បាប់ នេះស្តីពីបញ្ហាសមភាពរវាងភាគី ។ ដោយសារតែអង្គជំនុំជម្រះក្តីរបស់ជនជាប់ចោទនៅឯតុលាការខ្មែរក្រហមផ្នែកស៊ើរតែទាំងស្រុងទៅលើភ័ស្តុតាងដែលសហចៅក្រមស៊ើបអង្កេតបានរកឃើញដោយអនុវត្តសិទ្ធិអំណាចស៊ើបអង្កេតក្នុងការរក្សាការសម្ងាត់ ។ ដូច្នេះ សមត្ថភាពឯករាជ្យភាពនិងភាពមិនលម្អៀងរបស់តុលាការពិតជាមានសារសំខាន់ក្នុងការការពារសិទ្ធិទទួលបានអង្គជំនុំជម្រះក្តីដោយត្រឹមត្រូវ និងយុត្តិធម៌ ។ យ៉ាងណាមិញ មានការចោទប្រកាន់មិនដាច់ដែលថា សហចៅក្រមស៊ើបអង្កេតមិនបានពិចារណាពីប្រយោជន៍របស់ជនជាប់ចោទដោយត្រឹមត្រូវ និងមិនលម្អៀងនៅក្នុងដំណើរការស៊ើបអង្កេតរបស់ខ្លួន ។ អាស្រ័យហេតុនេះហើយទើបមានការសន្និដ្ឋានថា ការស៊ើបអង្កេតត្រូវបានអនុវត្តឡើងដោយអសមត្ថភាព លម្អៀង និងដោយមានការជ្រៀតជ្រែកពីផ្នែកនយោបាយ ។

នៅដើមឆ្នាំ ១៩៩៩ នៅក្នុងដំណាក់កាលចរចាដើម្បីបង្កើតតុលាការខ្មែរក្រហម មន្ត្រីរបស់អង្គការសហប្រជាជាតិបានបង្ហាញពីការព្រួយបារម្ភយ៉ាងខ្លាំងលើបញ្ហាអំពើពុករលួយ និងការជ្រៀតជ្រែកផ្នែកនយោបាយដែលបានកើតមានឡើងនៅក្នុងប្រព័ន្ធច្បាប់កម្ពុជាដូចជា : ចៅក្រមទទួលបានជ្រាក់បៀវត្សរ៍ទាបដែលបណ្តាលឲ្យមានការស៊ីសំណូក និងប្រកាន់បក្សពួក ។ មានការយល់ឃើញថា ចៅក្រមទាំងអស់ បើទោះបីជាចៅក្រមខ្លះមិនមានជាប់ពាក់ព័ន្ធនឹងគណបក្សប្រជាជនកម្ពុជាក៏ដោយ ក៏មានមុខតំណែងនៅក្នុងជួរនយោបាយ ។ ភាពអសមត្ថភាពបានរារាំងដល់វិស័យយុត្តិធម៌ ។ ការអនុវត្តច្បាប់បានធ្វើឡើងដោយគ្មានច្បាប់ទម្លាប់ ។ សូម្បីតែមកដល់សព្វថ្ងៃនេះ វាគឺជាការយល់ឃើញទូទៅមួយដែលថាការធ្វើជាសមាជិករបស់បក្សប្រជាជនកម្ពុជាគឺជាថ្នូរក្រៅផ្លូវការមួយសម្រាប់ក្លាយជាចៅក្រម ។ បើទោះបីជាគ្មានភ័ស្តុតាងផ្ទាល់រកឃើញជាសាធារណៈថាសហចៅក្រមជាតិយូ ប៊ុនឡេង មិនបានបំពេញកិច្ចការរបស់ខ្លួនឲ្យស៊ីសង្វាក់នឹងភាតព្រកិច្ចក៏ដោយ ក៏ភាពខ្វះខាតនូវឯករាជ្យភាពក្នុងប្រព័ន្ធច្បាប់កម្ពុជា ការចោទប្រកាន់លើចៅក្រមផ្សេងទៀតរបស់តុលាការខ្មែរក្រហម និងសេចក្តីសម្រេចរបស់លោកដែលសង្ស័យថាមានជាប់ពាក់ព័ន្ធនឹងបញ្ហានយោបាយ បានធ្វើឲ្យមានមន្ទិលសង្ស័យលើគោលការណ៍មិនលម្អៀងរបស់គាត់ ។

ឧទាហរណ៍នៃសកម្មភាពមិនត្រែងរអែងបំផុតមួយរបស់លោក យូ ប៊ុនឡេង ទាក់ទងនឹងការជ្រៀតជ្រែកផ្នែកនយោបាយគឺកាលដែលលោក យូ ប៊ុនឡេង បានបដិសេធមិនចុះហត្ថលេខាលើបទសម្ភាសរបស់ព្រះមហាវរក្សត្រ នរោត្តម សីហនុ និងមន្ត្រីរដ្ឋាភិបាលទាំងប្រាំមួយរូប ។ សកម្មភាព និងការមិនធ្វើសកម្មភាពរបស់លោកចៅក្រមនៅក្នុងហេតុការណ៍នេះបានបណ្តាលឲ្យមានការដាក់ទណ្ឌកម្មដោយចៅក្រមអង្គបុរេជំនុំជម្រះអន្តរជាតិដែលអះអាងថា បើទោះបីជាមានការខ្វះខាតនូវមូលហេតុតាមផ្លូវច្បាប់ក្នុងការពន្យល់បកស្រាយពីសេចក្តីសម្រេចចិត្តរបស់លោក យូ ប៊ុនឡេង ក៏ដោយ ក៏ចៅក្រមណាម្នាក់អាចនឹងពិចារណាថាចៅក្រម យូ ប៊ុនឡេង ទទួលរងឥទ្ធិពលពីការជ្រៀតជ្រែកផ្នែកនយោបាយដែរ ។

ចៅក្រម យូ ប៊ុនឡេង ក៏បានសម្រេចលុបចោលការចុះហត្ថលេខាលើលិខិតអនុញ្ញាតឲ្យធ្វើការស៊ើបអង្កេតបឋមលើសំណុំរឿង ០០៣ និង ០០៤ ក្រោយពេលដែលអ្នកនាំពាក្យរបស់រដ្ឋាភិបាលបានអះអាងថារដ្ឋាភិបាលកម្ពុជាមិនគាំទ្រចំពោះការកាត់ទោសជនសង្ស័យបន្តមទៀត ។ រហូតមកដល់សព្វថ្ងៃនេះគ្មានការបដិសេធច្រានចោលឬដីកាចោទប្រកាន់ណាមួយត្រូវបានធ្វើឡើងឡើយ ហើយសហចៅក្រមស៊ើបអង្កេតក៏បានបដិសេធច្រានចោលសំណើសហព្រះរាជអាជ្ញាអន្តរជាតិក្នុងការជំរុញឲ្យមានការស៊ើបអង្កេតបន្តមទៀត ។

ដោយសារតែមានចន្លោះខ្វះខាតនៅក្នុងដំណើរការស៊ើបអង្កេត ឧទាហរណ៍ទាំងអស់នេះមានជាប់ពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងសិទ្ធិរបស់ជនជាប់ចោទសំណុំរឿង ០០២ ក្នុងការទទួលបានការកាត់ទោសដែលត្រឹមត្រូវ និង យុត្តិធម៌ ។ ឧទាហរណ៍ទាំងនេះគួរបញ្ជាក់ថាចៅក្រមជាតិបានចេញសេចក្តីសម្រេចដោយឆ្លើយតបដាច់ទៅនឹងឆន្ទៈនយោបាយរបស់រដ្ឋាភិបាលកម្ពុជា ។ ចៅក្រម

អង្គបុរេជំនុំជម្រះបានសម្រេចជាច្រើនលើកច្រើនសាថាចៅក្រម យូ ប៊ុនឡេង មិនបានរំលោភលើវិធាន ឬច្បាប់ណាមួយទេ ហើយក៏គ្មានភស្តុតាងណាមួយដែលបញ្ជាក់ថាចៅក្រម យូ ប៊ុនឡេង បានដើរតាមសេចក្តីបង្គាប់របស់រដ្ឋាភិបាលដែរ ។ យ៉ាងណាមិញ នៅពេលដែលវិភាគសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់មន្ត្រីរដ្ឋាភិបាល លក្ខណៈនៃច្បាប់កម្ពុជា និងការចោទប្រកាន់ប្រឆាំងនឹងចៅក្រមជាតិមួយចំនួនផ្សេងទៀតបានឲ្យឃើញថា ឥរិយាបថរបស់ ចៅក្រម យូ ប៊ុនឡេង បានធ្វើឲ្យអ្នកសង្កេតជាច្រើនមានមន្ទិលសង្ស័យលើគុណភាព និងភាពមិនលម្អៀងនៃការស៊ើបអង្កេតលើសំណុំរឿង០០២ ។

ដោយសារតែមន្ទិលសង្ស័យលើចៅក្រមជាតិ និងមូលហេតុដែលថាតុលាការខ្មែរក្រហមត្រូវបានបង្កើតឡើងដើម្បីអនុញ្ញាតឲ្យមានការចូលរួមពីមជ្ឈដ្ឋានអន្តរជាតិ នោះវាពិតជាចាំបាច់ដែលថាចៅក្រម អន្តរជាតិត្រូវគេចចេញពីការរិះគន់ ។ ប៉ុន្តែ ទាក់ទងនឹងការចោទប្រកាន់ជាសាធារណៈមួយស្តីពីភាពលម្អៀងផ្លូវច្បាប់ ចៅក្រម ឡឺម៉ុង បានទទួលរងនូវការរិះគន់យ៉ាងខ្លាំងចំពោះសេចក្តីថ្លែងការណ៍ដែលលោកបាននិយាយនៅក្នុងអង្គប្រជុំក្រៅផ្លូវការមួយដែលថាលោកចង់ឲ្យការស៊ើបអង្កេតរកឃើញនូវភស្តុតាងដែលបម្រើជាប្រយោជន៍ដល់ព្រះរាជអាជ្ញាជាជាងមេធាវីការពារក្តីជនជាប់ចោទ ។

បើទោះបីជាមិនច្បាស់ថា តើចៅក្រម ឡឺម៉ុង បាននិយាយលេងសើច ឬជ្រាកដប្រជាក៏ដោយ ក៏ការនិយាយក្នុងឥរិយាបថបែបនេះមិនអាចទទួលយកបានទេ ហើយគួរតែត្រូវបានវិភាគឲ្យបានល្អិតល្អន់ ។ ចៅក្រមបន្ទាប់ ស៊ីតហ្វ្រីដ ប៊ីង ដែលជាអ្នកជំនួសតំណាងថ្មីឲ្យលោកចៅក្រម ឡឺម៉ុង បានទទួលរងការរិះគន់យ៉ាងខ្លាំងក្លាសម្រាប់កិច្ចការស៊ើបអង្កេតរបស់ខ្លួនលើកសំណុំរឿង០០៣ និង០០៤ ។ ចៅក្រម ប៊ីង បានធ្វើការស៊ើបអង្កេតលើសំណុំរឿង០០៣ តែគ្មានការស៊ើបអង្កេតណាមួយត្រូវបានធ្វើឡើងឡើយ ។ បញ្ហានេះធ្វើឲ្យមានការព្រួយបារម្ភថា ភាពត្រឹមត្រូវតាមផ្លូវច្បាប់របស់តុលាការខ្មែរក្រហមកំពុងតែទទួលរងផលប៉ះពាល់ដោយសារតែប្រព័ន្ធច្បាប់ដ៏មិនគួរឲ្យជឿជាក់មួយនេះ ។

វិធីសាស្ត្រ អ៊ិនហ៊ីស៊ីតូរៀល គឺជាប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌដែលប្រកបដោយភាពត្រឹមត្រូវ និងមានប្រសិទ្ធភាពច្រើនសម្រាប់តុលាការដែលមានភាពស្មុគស្មាញដូចជាតុលាការខ្មែរក្រហមដែលផ្តើការកាត់ទោសជនជាប់ចោទច្រើនក្នុងពេលតែមួយ ។ យ៉ាងណាមិញ ដើម្បីឲ្យប្រព័ន្ធច្បាប់នេះដំណើរការទៅបាន ចៅក្រមត្រូវតែមិនទទួលរងនូវការរិះគន់ ។ បើផ្តើការពិចារណាដាច់ដោយឡែកពីគ្នាការចោទប្រកាន់នីមួយៗស្តីពីអសមត្ថភាពក្នុងការស៊ើបអង្កេតលើសំណុំរឿង០០២មិនអះអាងឲ្យឃើញពីការរំលោភលើឯករាជ្យភាពរបស់តុលាការឡើយ ។ ប៉ុន្តែ បើវិភាគឲ្យបានល្អិតល្អន់ ការចោទប្រកាន់ទាំងនោះបណ្តាលឲ្យមានការព្រួយបារម្ភលើគុណភាពនៃការស៊ើបអង្កេត ការគោរពសមភាពរវាងភាគីនីមួយៗ និងឯករាជ្យភាពរបស់តុលាការ ។ បញ្ហានេះបណ្តាលឲ្យមានការសង្ស័យលើភាពត្រឹមត្រូវតាមផ្លូវច្បាប់របស់តុលាការ ហើយធ្វើជាគំរូអវិជ្ជមានមួយដល់ការអភិវឌ្ឍប្រព័ន្ធច្បាប់កម្ពុជា ។

ចៅក្រមរបស់អង្គជំនុំជម្រះសាលាដំបូងមានសមត្ថភាពក្នុងការកែតម្រូវលើភាពទន់ខ្សោយក្នុងការស៊ើបអង្កេតដោយធានាឲ្យបាននូវគុណភាពនៃការវិភាគលើភស្តុតាងរបស់អង្គជំនុំជម្រះក្តី ។ ជាពិសេស ជនជាប់ចោទត្រូវតែទទួលបានឱកាសសួរដេញដោលលើរបាយការណ៍របស់សាក្សី និងឯកសារដែលនុះបញ្ចាំង ណែនាំ ឬគាំទ្រជនជាប់ចោទ ។ លើសពីនេះ ចៅក្រមរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវតែបំពេញតួនាទីដោយតម្លាភាពដែលក្នុងនោះរួមមានការចេញសេចក្តីសម្រេចសមហេតុផលដើម្បីចៀសវាងភាពលម្អៀង ។

ដោយសារតែចៅក្រម ស៊ីលវៀ ភាតរ៉ាយម៉ ជាអ្នកបានព្រមានមុនថា រាល់សកម្មភាពរបស់អង្គជំនុំជម្រះសាលាដំបូងនឹងត្រូវបានសាធារណជនតាមដាន ដូច្នេះចៅក្រមត្រូវតែប្រកាន់ខ្ជាប់តាមតួនាទីរបស់ខ្លួនក្នុងការកសាងកេរដំណែលរបស់តុលាការខ្មែរក្រហមដូចជា : «ដើម្បីស្តារប្រព័ន្ធច្បាប់ដោយផ្តល់ការជឿទុកចិត្តដល់ប្រជាជនកម្ពុជាដែលថាប្រជាជនកម្ពុជានឹងទទួលបានយុត្តិធម៌ពីតុលាការ» និង «ដើម្បីបង្ហាញសហគមន៍អន្តរជាតិថាប្រទេសកម្ពុជាកំពុងតែប្រឹងប្រែងអនុវត្តប្រព័ន្ធច្បាប់មួយដែលដើរតាមបទដ្ឋានអន្តរជាតិ» ។

ខាឡឺរី អ៊ី ស្រែរឡឺរ

ការពិនិត្យមើលសារឡើងវិញលើការចរចាឆ្ពោះទៅរកការបង្កើតយុត្តាធិការបុគ្គលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

(តបថ)

ស្រដៀងគ្នានេះ នៅក្នុងសេចក្តីព្រាងចុងក្រោយរបស់អង្គការសហប្រជាជាតិស្តីពីមាត្រានៃកិច្ចសហប្រតិបត្តិការនិងអនុស្សារណៈយោគយល់រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ប្រយោគនៃយុត្តាធិការផ្នែកបុគ្គលនៅតែមានខ្វឹមសារថា មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ (ខ្វឹមសារបន្ថែមដែលដកស្រង់ចេញពីមាត្រា ១ នៃសេចក្តីព្រាងច្បាប់នីតិត្រូវដាក់បញ្ចូល) ដោយបញ្ជាក់ខ្វឹមសារបន្ថែមទៀតថា បញ្ហានេះមិនទាន់ត្រូវបានសម្រេចជាស្ថានពារនៅឡើយទេ ឬយ៉ាងហោចណាស់មិនទាន់ត្រូវបានបញ្ចប់រួចរាល់ដោយរដ្ឋាភិបាលកម្ពុជាទេ។

នៅពេលត្រឡប់មកបូរីញ៉ូវយ៉ែកវិញ លោក ហាន់ កូរ៉ែល បានឆ្លើយតបទៅកាន់លោកឧបនាយករដ្ឋមន្ត្រី សុខ អាន ដោយនិយាយថា លោកបានពិចារណាបន្ថែមទៅលើបញ្ហាយុត្តាធិការផ្នែកបុគ្គលនេះ។ លោក កូរ៉ែល បានសរសេរថា «ខ្ញុំគិតថាបញ្ហាយុត្តាធិការនេះគឺជាបញ្ហានយោបាយដ៏រសើបមួយ។ យើងត្រូវពិចារណាថា តើយើងត្រូវកម្រិតវិសាលភាពនៃយុត្តាធិការផ្នែកបុគ្គលបែបណាដើម្បីឲ្យអង្គជំនុំជម្រះវិសាមញ្ញអាចចាត់ចែងដំណើរការរឿងក្តីបាន។ យើងត្រូវកត់ចំណាំនៅក្នុងបរិបទនេះថា ជនសង្ស័យទាំងអស់របស់ខ្មែរក្រហមដែលអាចស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះមិនអាចគេចចេញពីការទទួលខុសត្រូវចំពោះការប្រព្រឹត្តខ្មែរក្រហមទាំងអស់នោះបានទេ។ រាជរដ្ឋាភិបាលកម្ពុជាត្រូវតែសម្រេចថា តើបញ្ហាដូចជាការកាត់ទោសចំពោះមុខតុលាការជាតិ ឬអន្តរជាតិ ឬក៏ការបង្កើតគណៈកម្មាធិការស្វែងរកការពិតនិងការផ្សះផ្សានឹងត្រូវដោះស្រាយដោយរបៀបណា។ នៅពេលដែលខ្ញុំត្រឡប់មកទីក្រុងញ៉ូវយ៉ែក ខ្ញុំនៅតែប្រកាន់ជំនឿថាពាក្យ «ឃោរឃៅ» អាចនឹងហុចជាភាពងាយស្រួលដល់ការកាត់ទោស។ យ៉ាងណាមិញ វាអាចចោទជាបញ្ហាក៏ថាបានពីព្រោះពាក្យនេះអាចចាត់ទុកថាបានរំលោភលើគោលការណ៍នៃការសន្មតថាគ្មានទោស»។ លោក កូរ៉ែល បានសន្យាថានឹងសរសេរឆ្លើយតបបន្ថែមទៀតទៅកាន់លោកឧបនាយករដ្ឋមន្ត្រី សុខ អាន ឆាប់ៗនេះនាពេលឆាប់ៗ។ ដោយសារតែមានភាពជាប់គាំងនីតិការប្រើប្រាស់ពាក្យ លោក កូរ៉ែល បានចេញលិខិតអញ្ជើញប្រទេសជាប់ពាក់ព័ន្ធមួយចំនួនឲ្យមកចូលរួមការប្រជុំមួយនៅថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២ ០ ០ ០ ដើម្បីពិភាក្សាអំពីការបង្កើតតុលាការជាតិនៅក្នុងប្រទេសកម្ពុជាដោយការផ្តល់ជំនួយពីអង្គការសហប្រជាជាតិ ដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែរ។ សារលិខិតដែលផ្ញើទៅកាន់ប្រទេសទាំងនោះបានប្រើប្រាស់ឃ្លាដូចគ្នាដដែល។ នៅពេលដែលត្រូវបានសួរឲ្យគូសបញ្ជាក់លើន័យនៃពាក្យផ្សេងៗ លោក កូរ៉ែល បានឆ្លើយតបថា នៅក្នុងបរិបទនេះ ពាក្យថា «ផ្សេងៗទៀត» គឺសំដៅទៅលើជនដែលមានការទទួលខុសត្រូវខ្ពស់។ លោក កូរ៉ែល នៅតែប្រើប្រាស់ឃ្លាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែរ។ នៅពេលដែលលោកបានសរសេរសារលិខិតឆ្លើយតបទៅកាន់លោកឧបនាយករដ្ឋមន្ត្រី សុខ អាន។ ខ្វឹមសារនៅក្នុងលិខិតនោះមានដូចខាងក្រោម:

«យើងបានពិចារណាបន្ថែមលើខ្វឹមសារនៃលក្ខន្តិកៈនៅក្នុងផ្នែករបស់បទបញ្ជតិ្តដែលអាចនឹងដាក់កម្រិតដ៏សមហេតុផលមួយលើវិសាលភាពនៃយុត្តាធិការផ្នែកបុគ្គល។ ក្រោយពីបានវិភាគបន្ថែមទៀត យើងបានសន្មតថា ពាក្យ «ឃោរឃៅ» អាចនឹងចោទជាបញ្ហាបាន។ ខ្ញុំបានបង្ហាញការព្រួយបារម្ភអំពីការរំលោភលើគោលការណ៍នៃការសន្មតថាគ្មានទោសពីព្រោះនៅក្នុងវចនានុក្រមយើងឃើញមានពាក្យដែលមានន័យដូចនឹងពាក្យឃោរឃៅនេះជាច្រើនដូចជាពាក្យ «មិនអាចប្រកែកបាន» និងពាក្យ «យ៉ាងពិតប្រាកដ»។ ដើម្បីជូនជាព័ត៌មានដល់លោក ខ្ញុំបានដកស្រង់ពាក្យន័យដូចមួយចំនួនពីវចនានុក្រម វែបស្ទឺ ដែលរួមទាំងពាក្យន័យផ្ទុយ និងន័យដូចដែលមានខ្វឹមសារដូចតទៅ : ជាក់ស្តែង ប្រត្យក្ស ស្គាល់ ពិតប្រាកដ បើកចំហរ

លាតត្រដាង យ៉ាងជាក់ស្តែង ធម្មតា មិនអាចប្រកែកបាន មិនអាចតវ៉ាបាន និងអាសោច។ បញ្ហាមួយទៀតគឺថា ជនដែលមានការទទួលខុសត្រូវខ្ពស់បំផុត អាចមិនមែនជាមនុស្ស «ឃោរឃៅ» ឬ «អាសោច»។ ដូច្នេះគុណាការមិនគួរកំណត់ការកាត់ទោសឲ្យនៅត្រឹមកម្រិតនេះទេ។ ដូច្នេះក្រោយពីការពិចារណាបន្ថែមទៀតមក យើងគិតថាដោយបន្ថែមពាក្យ «បំផុត» នៅក្នុងខ្លឹមសារដែលបានកំណត់នៅក្នុងសេចក្តីព្រាងចុះការពីថ្ងៃទី១៨ ខែមករា យើងអាចផ្តល់ជាការតម្រង់ទិសគ្រប់គ្រាន់ដល់សហចៅក្រមស៊ើបអង្កេតនិងសហព្រះរាជអាជ្ញាដើម្បីចាត់វិធីសាស្ត្រសម្រាប់ដំណើរការកាត់ទោសបាន។ ជាក់ស្តែង បញ្ហានេះនឹងត្រូវសម្រេចដោយអង្គនីតិបញ្ញត្តិដដែល»។

ដោយសារតែអង្គការសហប្រជាជាតិបានចាត់ទុកការកំណត់វិសាលភាពនៃយុត្តាធិការផ្នែកបុគ្គលនេះជាសេចក្តីសម្រេចផ្នែកនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជានោះនៅថ្ងៃទី១ ខែកញ្ញា រដ្ឋាភិបាលកម្ពុជាបានស្នើសុំឲ្យរដ្ឋសភាជាតិពិចារណាឡើងវិញលើសេចក្តីព្រាងច្បាប់ដែលខ្លួនបានស្នើឡើងក្នុងចន្លោះខែធ្នូ និងមករា កាលនោះ សេចក្តីព្រាងច្បាប់នោះត្រូវបានបង្ហាញជូនដល់គណៈកម្មាធិការនីតិបញ្ញត្តិដោយលោកឧបនាយករដ្ឋមន្ត្រី សុខ អាន។ ក្រោយមក គណៈកម្មាធិការនីតិបញ្ញត្តិបានកែសម្រួល និងបានធ្វើវិសោធនកម្មខ្លះលើសេចក្តីព្រាងច្បាប់នេះហើយបានយល់ស្របនឹងផ្នែកទាំងប្រាំបីនៃមាត្រាទាំងអស់ចំនួន៣៧របស់សេចក្តីព្រាងច្បាប់នេះ។ វិសោធនកម្មនេះរួមមាន ការកែប្រែលើខ្លឹមសារនៃយុត្តាធិការផ្នែកបុគ្គលនៃច្បាប់នេះដោយនិយាយថាយុត្តាធិការរបស់តុលាការរួមមានមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនដែលមានការទទួលខុសត្រូវខ្ពស់សម្រាប់ខ្ទក្រិដ្ឋកម្ម និងការរំលោភបំពានធ្ងន់ធ្ងរ។ វិសោធនកម្មនេះបានដាក់បញ្ចូលខ្លឹមសារធំៗពីរដែលត្រូវបានផ្តល់ឲ្យដោយអង្គការសហប្រជាជាតិដោយអនុម័តយកខ្លឹមសារនៃពាក្យដែលត្រូវបានដកស្រង់ចេញពីរបាយការណ៍របស់អ្នកស្រាវជ្រាវជំនាញនិងឃ្លាដែលគាំទ្រដោយគណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ និងសភាអង្គការសហប្រជាជាតិ។ ដោយបានដឹងពីលទ្ធផលនេះ នៅខែវិច្ឆិកា សហរដ្ឋអាមេរិកបានបង្ហាញការពេញចិត្តថាក្នុងចំណោមជនដែលត្រូវនាំមុខកាត់ទោសរួមមាន : មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម និងរួមទាំង ខុច ដង។ វិសោធនកម្មលើសេចក្តីព្រាងនេះចែងថា មេដឹកនាំ ជាន់ខ្ពស់ទាំងនោះរួមមាន នួន ជា, តាម៉ុក, អៀង សារី និងប្រពន្ធរបស់គាត់គឺ អៀង ធីរិទ្ធ, ខៀវ សំផន និង កែ ពក ដោយតួសបញ្ជាក់ម្តងទៀតលើការបកស្រាយដ៏វែងនៃឃ្លា: មេដឹកនាំជាន់ខ្ពស់ថា ជាជនដែលជាសមាជិករបស់គណៈអចិន្ត្រៃយ៍មជ្ឈិម ហើយការរាប់បញ្ចូលទាំង អៀង ធីរិទ្ធ ក៏បានធ្វើឲ្យចំនួនមេដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហមមានចំនួនដូចគ្នានឹងចំនួនដែលនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសកាលពីមុន។

នាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏បានបង្ហាញទស្សនៈជាសាធារណៈថា ក្រៅពី តាម៉ុក និង ខុច មេដឹកនាំខ្មែរក្រហមដូចជា នួន ជា, ខៀវ សំផន និង កែ ពក ក៏នឹងត្រូវកាត់ទោសដែរ។ នាយករដ្ឋមន្ត្រី ក៏បានរំឭកគ្រប់គ្នាថា វាពិតជាចាំបាច់ដែលភាគីទាំងអស់ត្រូវបែងចែកឲ្យច្បាស់រវាងសមាជិកខ្មែរក្រហមដែលបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ និងជនដែលជួយដួលរលំរបបប្រល័យពូជសាសន៍នេះដោយនិយាយថា: «ជនដែលបានប្រព្រឹត្តខ្ទក្រិដ្ឋកម្មអំពើប្រល័យពូជសាសន៍ ហើយបានសហការប្រព្រឹត្តខ្ទក្រិដ្ឋកម្ម និងអំពើប្រល័យពូជសាសន៍ត្រូវតែដុតខ្ទារទោសមិនមែនជនដែលផ្តួលរំលំរបបនេះទេ»។ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានតួសបញ្ជាក់ថា សម្តេចចង់មានន័យថាជនសង្ស័យបន្ថែមទៀតក្រៅពីមេដឹកនាំជាន់ខ្ពស់មិនត្រូវរាប់បញ្ចូលទេ រួមទាំងសម្តេច ហេង សំរិន, សម្តេច ជា ស៊ីម និងសម្តេច ហ៊ុន សែន ខ្លួនឯងផង ពីព្រោះជនសង្ស័យទាំងនោះ រួមទាំងសម្តេចផ្ទាល់បានចូលរួមផ្តួលរំលំរបបប្រល័យពូជសាសន៍របស់ខ្មែរក្រហម» ក្រោយពីការដកខ្លួនចេញពីបក្សកុម្មុយនីស្តកម្ពុជា។

នៅដើមខែធ្នូ ឆ្នាំ២០០០ គណៈកម្មាធិការនីតិបញ្ញត្តិរបស់រដ្ឋសភាជាតិបានបញ្ចប់ការត្រួតពិនិត្យរបស់ខ្លួនលើសេចក្តីព្រាងច្បាប់នេះដោយប្រគល់សេចក្តីព្រាងនេះទៅកាន់អង្គសភាទាំងមូលដែលខ្ទឹមសារនៃយុត្តាធិការផ្នែកបុគ្គលរួមមាន មេដឹកនាំជាន់ខ្ពស់ និងជនដែលទទួលខុសត្រូវខ្ពស់បំផុត។ ការពិភាក្សា និងការវិភាគវែកញែកបានចាប់ផ្តើមឡើងនៅថ្ងៃទី២៩ ខែធ្នូ។ សេចក្តីព្រាងនេះត្រូវបានចេញសម្រេចនៅថ្ងៃទី២ ខែមករា ឆ្នាំ២០០១ ដោយមានខ្ទឹមសារប្រហាក់ប្រហែលគ្នានឹងមាត្រា១ និងមាត្រា២ដែលចែងថាយោងតាមការបកប្រែរបស់រដ្ឋាភិបាលតុលាការអាចនាំយកមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនដែលមានការ

ទទួលខុសត្រូវខ្ពស់សម្រាប់ខក្រិដ្ឋកម្ម និងការរំលោភបំពានធ្ងន់ធ្ងរ លើច្បាប់កម្ពុជាដែលជាប់ពាក់ព័ន្ធនឹងខក្រិដ្ឋកម្ម ច្បាប់សិទ្ធិមនុស្ស និងទំនៀមទម្លាប់អន្តរជាតិ និងអនុសញ្ញាអន្តរជាតិដែលទទួលស្គាល់ដោយប្រទេសកម្ពុជាមកកាត់ទោសដែលខក្រិដ្ឋកម្មទាំងអស់នេះ ត្រូវបានប្រព្រឹត្តឡើងចាប់ពីថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ មករា ឆ្នាំ១៩៧៩ ។ ខ្ញុំមសារនេះត្រូវបានបញ្ជូនទៅឲ្យអង្គការសហប្រជាជាតិ ហើយអង្គការសហប្រជាជាតិបានសិក្សាយ៉ាងប្រុងប្រយ័ត្នលើខ្ញុំមសារនេះហើយបានបង្ហាញពីការព្រួយបារម្ភមួយចំនួន ។ យ៉ាងណាមិញ ការព្រួយបារម្ភទាំងនោះមិនមានជាប់ពាក់ព័ន្ធនឹងយុត្តាធិការផ្ទែកបុគ្គលរបស់តុលាការទេ ដូច្នេះវានឹងបញ្ជាក់ឲ្យឃើញថា អង្គការសហប្រជាជាតិពេញចិត្តនឹងខ្ញុំមសារនេះ ។ ខ្ញុំមសារនេះត្រូវបានរក្សាទុកនៅក្នុងច្បាប់ដែលត្រូវបានអនុម័តដោយព្រឹទ្ធសភា ហើយត្រូវបានព្រមព្រៀងដោយក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ ។ ជាពិសេសខ្ញុំមសារនេះក៏ត្រូវបានលើកឡើងម្តងទៀតនៅក្នុងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិនៅឆ្នាំ២ ០ ០ ៣ស្តីពីការបង្កើតតុលាការ ហើយក៏ត្រូវបានរក្សាទុកម្តងទៀតនៅក្នុងវិសោធនកម្មនៃច្បាប់តុលាការដែលត្រូវបានអនុម័តដូចគ្នានឹងដំណើរការនៃខ្ញុំមសារដើម ហើយត្រូវបានប្រកាសជាផ្លូវការនៅខែវិច្ឆិកា ឆ្នាំ២ ០ ០ ៤ ។ ខ្ញុំមសារនេះក៏ត្រូវបានដាក់បញ្ចូលទៅក្នុងអនុស្សារណៈរបស់អង្គការសហប្រជាជាតិរួមទាំងសភាអង្គការសហប្រជាជាតិនៅខែឧសភា ឆ្នាំ២ ០ ០ ៣ ។

ការបកស្រាយខ្ញុំមសារ

ដោយសារតែខ្ញុំមសារនេះត្រូវបានស្នើឡើងដោយអង្គការសហប្រជាជាតិ និងដកស្រង់ចេញពីរបាយការណ៍របស់អ្នកស្រាវជ្រាវជំនាញ ខ្ញុំមសារនេះអាចមានន័យដូចគ្នានឹងខ្ញុំមសាររបស់អ្នកស្រាវជ្រាវជំនាញ, អ្នកតំណាងពិសេស ហាំម៉ាបើក, គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ, រដ្ឋសភារបស់អង្គការសហប្រជាជាតិ, អគ្គលេខាធិការអង្គការសហប្រជាជាតិ, ការិយាល័យកិច្ចការច្បាប់របស់អង្គការសហប្រជាជាតិ និងសហរដ្ឋអាមេរិក ។ បើទោះបីជាអង្គការសហប្រជាជាតិបានលាក់ចាំងមិនបញ្ចេញឈ្មោះជនដែលត្រូវកាត់ទោសក៏ដោយ ក៏ខ្ញុំមសារនៃឃ្លាមេដឹកនាំជាន់ខ្ពស់បានសំដៅទៅលើសមាជិករបស់គណៈអចិន្ត្រៃយ៍ និងអ្នកនៅក្រោមបង្គាប់នៃគណៈមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា រួមទាំងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ខណៈពេលដែលជនមានការទទួលខុសត្រូវខ្ពស់នោះអាចសំដៅទៅលើមេដឹកនាំយោធានិងនយោបាយថ្នាក់កណ្តាលមន្ត្រីរដ្ឋាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ និងមេដឹកនាំថ្នាក់កណ្តាលដូចជា ខុច ដែលជនទាំងអស់នេះសុទ្ធតែមានភ័ស្តុតាងបញ្ជាក់ពីបទបញ្ញត្តិថាស្ថិតនៅក្រោមក្រុមជនជាប់ចោទប្រភេទទីពីរ ។ យ៉ាងណាមិញ ខ្ញុំមសារនៃឃ្លា : ជនដែលទទួលខុសត្រូវខ្ពស់បំផុតមិនសំដៅទៅលើខ្មែរក្រហមថ្នាក់ទាបទេ ។ មានន័យថា ខ្ញុំមសារនៃយុត្តាធិការនេះមិនសំដៅទៅលើជនដៃដល់ដាល់ ដែលមានហានៈខ្ពស់ បើទោះបីជាជនទាំងនោះជាកម្មាភិបាលខ្មែរក្រហមដែលមានអំណាចគ្រប់គ្រងលើកម្មាភិបាលនៃបក្សកុម្មុយនីស្តកម្ពុជាផ្សេងៗទៀតក៏ដោយ ។ បញ្ហាដែលរាជរដ្ឋាភិបាលកម្ពុជាបានបដិសេធខ្ញុំមសារដែលរឹតត្បិតបំផុតនោះត្រូវបានលោក ថូម៉ាស់ ហាំម៉ាបើក សហរដ្ឋអាមេរិក និងអង្គការសហប្រជាជាតិធ្វើការពិចារណាដែលភាគីទាំងអស់បានណែនាំថា ប្រសិនបើមិនត្រូវបានពន្យល់ បកស្រាយឲ្យបានច្បាស់ពីយុត្តាធិការរបស់មេដឹកនាំជាន់ខ្ពស់ដែលក្នុងនោះរួមមានទាំង ខុច នោះ តាមរយៈការទទួលស្គាល់របស់រាជរដ្ឋាភិបាលកម្ពុជាដោយយោងតាមគោលការណ៍យុត្តាធិការផ្ទែកបុគ្គលដែលមានវិសាលភាពធំជនដែលមានការទទួលខុសត្រូវខ្ពស់អាចនឹងសំដៅទៅលើមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ដោយរាប់បញ្ចូលទាំងមន្ត្រីថ្នាក់កណ្តាលរបស់បក្សកុម្មុយនីស្តកម្ពុជាថាជាជនដែលត្រូវកាត់ទោស ។

ស្របពេលជាមួយគ្នានេះ ច្បាប់ដើមត្រូវបានអនុម័តដោយយោងតាមមូលដ្ឋាននៃការបកស្រាយនិងយោបល់របស់រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋសភាជាតិដែលបានបកស្រាយថា គោលបំណងនិងការយល់ឃើញរបស់រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋសភាជាតិគឺដើម្បីបង្រួមខ្ញុំមសារយុត្តាធិការផ្ទែកបុគ្គលនេះ ។ នៅក្នុងអង្គសមាជរបស់សភាជាតិ លោកឧបនាយករដ្ឋមន្ត្រី សុខ អាន បានអះអាងថា មេដឹកនាំជាន់ខ្ពស់ និងជនដែលទទួលខុសត្រូវខ្ពស់បំផុត ដោយសង្កត់ធ្ងន់ថា ច្បាប់បានកំណត់កាត់ទោសតែជនមួយក្រុមតូចតែប៉ុណ្ណោះ ។ ក្រុមនោះគឺជាក្រុមដែលមិនសាយភាយមានលក្ខណៈជាក្រុមតូចបំផុតហើយមិនមែនជាកម្មាភិបាលថ្នាក់កណ្តាលនិងកម្មាភិ

ជាលក្ខាត់ខាបង្កើយ ។ សមាជិកសភាផ្សេងទៀតបានអះអាងថា លើកលែងតែមេដឹកនាំខ្មែរក្រហមជនឃាំងឃ្លាយណាដែលបានបម្រើឲ្យរបបកម្ពុជាប្រជាធិបតេយ្យដែលក្នុងនោះរួមមានកម្មាភិបាលយោធា កម្មាភិបាលនយោបាយ និងសេនាជនមិនចាំបាច់ព្រួយបារម្ភថា ខ្លួនត្រូវបានតុលាការកាត់ទោសទេ ។ យ៉ាងណាមិញ លោកឧបនាយករដ្ឋមន្ត្រី សុខ អាន បានបញ្ជាក្រមគិយោបល់ថា ប្រសិនបើយើងយកគំរូតាមតុលាការមុនៗដូចជាតុលាការនៅណូរឹមបើក, តូក្យូ និងរ៉ាន់ដា នោះការបកស្រាយលើយុត្តាធិការផ្ទែកបុគ្គលរបស់តុលាការខ្មែរក្រហមគឺមានវិសាលភាពធំទូលាយ ។ លោកឧបនាយករដ្ឋមន្ត្រីបាននិយាយពីចំណុចវិជ្ជមានរបស់តុលាការឆាំងបីនេះ ដោយលើកជាឧទាហរណ៍ថា តុលាការនៅណូរឹមបើក បានកាត់ទោសពួកណាហ្សីចំនួន២៤នាក់ តុលាការនៅតូក្យូបានកាត់ទោសមេដឹកនាំជប៉ុនចំនួន២៨នាក់ហើយចំណែកឯតុលាការសម្រាប់ប្រទេសរ៉ាន់ដាបានកាត់ទោសមេដឹកនាំជាន់ខ្ពស់ចំនួន ៤៥ករណី ។ រឿងក្តីរបស់តុលាការនៅណូរឹមបើក រួមមានមន្ត្រីរដ្ឋាភិបាល, ប្រធានខាងតំបន់នីមួយៗ, មេបញ្ជាការកងទ័ព, មេបញ្ជាការប៉ូលិស និងមេបញ្ជាការកងទ័ពជើងទឹក ។ ចំណែកឯរឿងក្តីរបស់តុលាការនៅតូក្យូរួមមានមន្ត្រីរដ្ឋាភិបាល, មេបញ្ជាការកងទ័ព, មេទ័ពជើងទឹក និងប្រធានគ្រប់គ្រងតំបន់ ។ សេចក្តីសង្ខេបស្តីពីរឿងក្តីរបស់តុលាការអន្តរជាតិរ៉ាន់ដា កាលពីឆ្នូ ឆ្នាំ២០០០ បានបង្ហាញថា រឿងក្តីទាំងអស់នេះគឺជារឿងក្តីរបស់មន្ត្រីរដ្ឋាភិបាលដោយចាប់ផ្តើមពីមេបញ្ជាការយោធារហូតដល់មេបញ្ជាការថ្នាក់កងវរសេនាតូច រួមទាំងប្រធានថៅហ្វាយខេត្តចំនួន១១នាក់និងមេឃុំចំនួន១៨៥នាក់ដែលមានចំនួនសរុបចាប់ពីរាប់រយពាន់នាក់ ។ ការលើកឡើងរបស់លោកឧបនាយករដ្ឋមន្ត្រីទំនងជាឆ្លុះបញ្ចាំងថា តុលាការខ្មែរក្រហមអាចនឹងធ្វើការកាត់ទោសជនប្រភេទនេះបានដែលក្នុងនោះរួមមានទាំងជនដៃដល់ក្នុងស្រុកនិងក្រៅស្រុក ។

ដោយឡែក សម្តេច ហេង សំរិន បានធ្វើការបកស្រាយផ្ទុយគ្នា ។ សម្តេចបាននិយាយកាលពីខែមករា ឆ្នាំ២០០១ បន្ទាប់ពីច្បាប់ត្រូវបានអនុម័តនោះដោយអះអាងថា «ជនដែលធ្លាប់ធ្វើជាខ្មែរក្រហមមិនជាប់ព្រួយបារម្ភទេពីព្រោះតុលាការនឹងធ្វើការកាត់ទោសតែមេដឹកនាំជាន់ខ្ពស់និងដែលមានការទទួលខុសត្រូវចំពោះរបបនេះតែប៉ុណ្ណោះ» ។ បើយោងតាមសារព័ត៌មានផ្សេងៗ សម្តេច ហេង សំរិន បាននិយាយទៅកាន់អតីតខ្មែរក្រហមថា «កុំព្រួយបារម្ភអី យើងនឹងកាត់ទោសតែមេដឹកនាំ និងជនដែលមានការទទួលខុសត្រូវចំពោះរបបខ្មែរក្រហមតែប៉ុណ្ណោះ» ។ យ៉ាងណាមិញ នាយករដ្ឋមន្ត្រី ហ៊ុន សែន បាននិយាយដោយរាប់បញ្ចូលទាំងមេដឹកនាំជាន់ខ្ពស់ និង ឌុច ជនដែលត្រូវនាំមកកាត់ទោសមានចំនួនខ្ពស់រហូតដល់ដប់នាក់ ។ នេះមានន័យថា មានជនបីនាក់បន្ថែមទៀតដែលត្រូវកាត់ទោស ។ នៅខែសីហា ឆ្នាំ២០០១ ក្នុងការជួបសម្ភាសន៍ជាមួយអ្នកសារព័ត៌មានពីមតិយោបល់របស់គាត់ទាក់ទងនឹងច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម នាយករដ្ឋមន្ត្រី ហ៊ុន សែន បានលើកឡើងពីលទ្ធភាពដែលតុលាការនឹងធ្វើការកាត់ទោសជនប្រើននាក់នោះក្រោយពីមានសំណួរចោទសួរថា តើតុលាការនឹងធ្វើការកាត់ទោសជនប៉ុន្មាននាក់? នាយករដ្ឋមន្ត្រីបានឆ្លើយថា នេះគឺអាស្រ័យទៅលើច្បាប់របស់តុលាការ ។ ប៉ុន្តែនាយករដ្ឋមន្ត្រី ហ៊ុន សែន បាននិយាយថា ក្នុងនាមជាជនជាតិខ្មែរ គាត់មិនយល់ស្របដែលថាតុលាការគួរតែកាត់ទោសជនសង្ស័យឲ្យលើសពីចំនួនដប់នាក់ទេ ។ នាយករដ្ឋមន្ត្រីបានបកស្រាយថា គាត់សូមប្រឆាំងនឹងការកាត់ទោសកម្មាភិបាលថ្នាក់ខាប ។ នេះអាចឆ្លុះបញ្ចាំងឲ្យឃើញថា ក្រៅពីនួន ជា, អៀង សារី, តាម៉ុក, ខៀវ សំផន, កែ ពក, អៀង ធីរិទ្ធ និង ឌុច ជនបីរូបទៀតដែលត្រូវកាត់ទោសជាសមាជិករបស់គណៈមជ្ឈិមនិងក្រុមកម្មាភិបាលថ្នាក់ផ្សេងក្រៅពីថ្នាក់ខាប ។ បើទោះបីជាអង្គការសហប្រជាជាតិនៅតែពេញចិត្តនឹងយុត្តាធិការផ្ទែកបុគ្គលរបស់តុលាការក៏ដោយ ក៏អង្គការសហប្រជាជាតិនៅតែមានការព្រួយបារម្ភដែលនឹងចោទជាបញ្ហាគឺមិនមែនខ្វីមសារនៃច្បាប់ទេ ប៉ុន្តែវាគឺជាការអនុវត្ត ។ វាគួរឲ្យសង្ស័យដែលថា នាយករដ្ឋមន្ត្រីហ៊ុន សែនមានបំណងនាំយកមេដឹកនាំខ្មែរក្រហម មកកាត់ទោសតាមផ្លូវច្បាប់ដោយជឿជាក់ថាសម្ពាធការទូតបរទេសមកលើមេដឹកនាំខ្មែរក្រហមដែលធ្វើឡើងតាមរយៈតុលាការអាចមានប្រយោជន៍ ។ ដោយសារមូលហេតុនេះ និងមូលហេតុផ្សេងៗទៀត អង្គការសហប្រជាជាតិបានបញ្ឈប់ការចរចារបស់ខ្លួនជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងជាមួយនឹងបញ្ហាតុលាការដោយដកស្រង់យកពាក្យសម្តីជាច្រើនរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន និងមន្ត្រី

រដ្ឋាភិបាលកម្ពុជាដោយចោទសួរពីឆន្ទៈរបស់មន្ត្រីរដ្ឋាភិបាលកម្ពុជា ក្នុងការនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោស ។ សំខាន់ជាងនេះ សារលិខិតរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានកត់ត្រាថា តាមរយៈបទពិសោធចរចារបស់យើងអស់រយៈពេលប្លន់ឆ្នាំកន្លងទៅនេះ សេចក្តីសម្រេចបញ្ចប់ការចរចានេះត្រូវបានធ្វើឡើងដោយផ្អែកលើការព្រួយបារម្ភធ្ងន់ធ្ងរមួយចំនួនថា នៅពេលដែលអង្គជំនុំជម្រះត្រូវបានបង្កើតឡើងហើយនោះ រដ្ឋាភិបាលកម្ពុជាអាចនឹងជ្រៀតជ្រែកដំណើរការអង្គនីតិវិធីរបស់តុលាការដែលអាចប៉ះពាល់ដល់ដំណើរការស្វែងរកយុត្តិធម៌ឲ្យប្រជាជនកម្ពុជា និងប៉ះពាល់កិត្តិយសរបស់អង្គការអន្តរជាតិ ដូចជាអង្គការសហប្រជាជាតិជាដើម ។ ក្នុងចំណោមបញ្ហាជាច្រើន អង្គការសហប្រជាជាតិភ័យខ្លាចថាដោយសារតែសម្ពាធចៅក្រម និងព្រះរាជអាជ្ញាកម្ពុជាអាចនឹងជ្រើសរើសជនជាប់ចោទដោយផ្អែកលើមូលហេតុនយោបាយហើយរាជរដ្ឋាភិបាលកម្ពុជាអាចមិនមានឆន្ទៈឬមធ្យោបាយក្នុងការចាប់ខ្លួនជនសង្ស័យ ។ នៅក្នុងកិច្ចសន្ទនាតាមខ្សែទូរស័ព្ទជាមួយនឹងលោក កូហ៊ី អាណាន់ កាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០១ និងក្នុងសារលិខិតឆ្លើយតបនឹងលោកអគ្គលេខាធិការអង្គការសហប្រជាជាតិចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០១ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រឆាំងនឹងគោលគំនិតរបស់អង្គការសហប្រជាជាតិដែលរិះគន់ការប្តេជ្ញាចិត្ត និងភាពស្មោះត្រង់របស់រាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងតុលាការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលមានការទទួលខុសត្រូវខ្ពស់បំពេញខ្លាំងក្នុងឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុត ។ បើទោះបីជាសម្តេចបាននិយាយពីខ្លាំងក្នុងឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តដោយមេដឹកនាំខ្មែរក្រហមនិងជនដៃដល់ក៏ដោយ ក៏ខ្លឹមសារដែលនាយករដ្ឋមន្ត្រីបានឲ្យទៅលើយុត្តាធិការផ្ទៃកបុគ្គល ទំនងជាឆ្លុះបញ្ចាំងពីគោលបំណងរបស់សម្តេចដើម្បីរារាំងលទ្ធភាពដែលតុលាការអាចកាត់ទោសជនទាំងឡាយណាដែលមិនមែនជាមេដឹកនាំជាន់ខ្ពស់នោះ ។ ស្របពេលជាមួយគ្នានោះ រដ្ឋមន្ត្រីក្រសួងការបរទេស ហោ ណាំហុង បានគូសបញ្ជាក់ថា នួន ជា, អៀង សារី និង ខៀវ សំផន គឺជាជនដែលរាជរដ្ឋាភិបាលកម្ពុជាមានបំណងកាត់ទោស ។

ប៉ុន្តែអង្គការសហប្រជាជាតិនៅតែជឿថា រាជរដ្ឋាភិបាលកម្ពុជានឹងត្រូវត្រៀមខ្លួនដើម្បីកាត់ទោសមេដឹកនាំថ្នាក់កណ្តាលដោយជឿជាក់ថារដ្ឋាភិបាលកម្ពុជាមិនមានបំណងដោះលែងមេដឹកនាំខ្មែរក្រហមដែលរស់នៅក្នុងទឹកដីកម្ពុជាឲ្យមានសេរីភាពនោះទេ ហើយសង្ឃឹមថា រដ្ឋាភិបាលកម្ពុជានឹងធ្វើការតាមដានដំណើរការកាត់ទោសនេះដោយប្រើប្រាស់គោលនយោបាយរបស់ខ្លួន ។ យ៉ាងណាមិញ ការចរចារវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមបន្តទៀតនៅដើមឆ្នាំ២០០៣ ដោយមានការស្នើសុំពីលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ កិច្ចចរចានេះបានគូសបញ្ជាក់ថាតុលាការមានយុត្តាធិការផ្ទៃកបុគ្គលក្នុងការកាត់ទោសមេដឹកនាំ និងជនដែលមានការទទួលខុសត្រូវខ្ពស់សម្រាប់ខ្លាំងក្នុងឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យចំនួន៨០នាក់ ។ ប៉ុន្តែរាជរដ្ឋាភិបាលកម្ពុជាបានខាមខារមិនឲ្យមានការកែប្រែលើខ្លឹមសារនៃយុត្តាធិការរបស់តុលាការឡើយ ។ ជាក់ស្តែង រាជរដ្ឋាភិបាលកម្ពុជាបានក្តោបយកឱកាសនេះដើម្បីគូសបញ្ជាក់ពីគោលនយោបាយរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា-វៀតណាមឆ្នាំ១៩៧៩ ក្នុងការនាំយកតែមេដឹកនាំមកកាត់ទោសដោយអនុវត្តគោលនយោបាយកម្រិតស្រាលចំពោះកម្មាភិបាលនយោបាយ និងយោធារួមទាំងសេនាជនធម្មតាដែលអ្នកទាំងអស់នេះសុទ្ធតែជាជនរងគ្រោះ ។ នៅក្នុងឱកាសថ្លែងសុន្ទរកថាជាសាធារណៈកាលពីខែមិថុនា ឆ្នាំ២០០៣ ក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាក្នុងការបង្កើតតុលាការខ្មែរក្រហម លោក ហាន់ ភូវ៉ែល បាននិយាយថា ថ្ងៃនេះគឺជាថ្ងៃចុងបញ្ចប់នៃកិច្ចខំប្រឹងប្រែងក្នុងការនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោសដោយបញ្ជាក់ថា លោកនិយាយបែបនេះគឺសំដៅទៅលើមេដឹកនាំខ្មែរក្រហម និងជនដែលមានការទទួលខុសត្រូវខ្ពស់បំផុតសម្រាប់អំពើសាហាវឃោរឃៅ ។ លោកបានសង្កត់ធ្ងន់ថា គោលបំណងនេះអាចសម្រេចបានលុះត្រាតែមានឆន្ទៈនយោបាយ ។ ក្នុងនាមជាប្រធានក្រុមការងារកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម លោកឧបនាយករដ្ឋមន្ត្រី សុខ អាន បាននិយាយពីការដើរឆ្ពោះទៅមុខក្នុងការនាំយកជនដៃដល់មកកាត់ទោស ដោយមិនបានបកស្រាយបន្ថែមអ្វីលើចំណុចនេះទេ ។

នៅចុងឆ្នាំ២០០៣ អង្គការសហប្រជាជាតិបានព្រមព្រៀង

ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជាថា ដោយសារតែទម្ងន់នៃបញ្ហារៀបចំគម្រោងនិងបញ្ហាធនធានដែលត្រូវការមានតែជនត្រូវចោទចាប់ពីជ្រុំទៅដប់នាក់ប៉ុណ្ណោះដែលត្រូវកាត់ទោស ។ ទាក់ទិននឹងបញ្ហានេះ លោក កូហ៊ី អាណាន់ បានសង្កត់ធ្ងន់ថា យោងតាមកិច្ចព្រមព្រៀងស្តីពីការបង្កើតតុលាការ សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតគឺជាអ្នកសម្រេចថាជនណាដែលត្រូវបានស៊ើបអង្កេត និងកាត់ទោស ។ ជាកិច្ចឆ្លើយតបដើម្បីកែសម្រួលទៅលើរបាយការណ៍សារព័ត៌មានដែលនិយាយថា អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាបានព្រមព្រៀងគ្នាកំណត់ជនត្រូវចោទអ្នកនាំពាក្យរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានបញ្ជាក់ថានេះគឺជាទង្វើមិនសមរម្យកាលដែលភាគីទាំងពីរនឹងធ្វើដូច្នេះ ។ លោកបានគូសបញ្ជាក់ម្តងទៀតថា ចំនួនជនដែលត្រូវចៅក្រមស៊ើបអង្កេត និងកាត់ទោសនោះនឹងត្រូវតែសម្រេច ។ ជាមួយគ្នានេះលោកក៏បាននិយាយថាមនុស្សចំនួនបួនទៅដប់នាក់គួរតែមិនយកជាការទេ ពីព្រោះថា ចំនួនជនដែលត្រូវតុលាការកាត់ទោសអាចនឹងត្រូវផ្អាស់ប្តូរអាស្រ័យលើវិធីសាស្ត្រស៊ើបអង្កេត និងកាត់ទោសដែលតុលាការអាចនឹងអនុវត្តនាពេលអនាគត ។ នៅពេលដែលរដ្ឋសភាជាតិកម្ពុជាបានជួបប្រជុំដើម្បីពិភាក្សាពីកិច្ចព្រមព្រៀងនិងការសម្រេចចុងក្រោយលើច្បាប់ក្នុងស្រុកក្នុងការផ្តល់ជាអាណត្តិដល់តុលាការដែលធ្វើឡើងនៅខែវិច្ឆិកា ឆ្នាំ២០០៤ សមាជិករដ្ឋសភាដែលមកពីគណៈបក្សប្រឆាំងនីងគណបក្សប្រជាជនកម្ពុជាបានចោទសួរពីយុត្តាធិការ ផ្នែកបុគ្គលរបស់តុលាការ ។ សមាជិករដ្ឋសភាទាំងនោះបានរិះគន់ថាយុត្តាធិការរបស់តុលាការអាចអនុញ្ញាតឲ្យមន្ត្រីរបស់បក្សកុម្មុយនីស្តកម្ពុជាចាប់ពីថ្នាក់ក្រោមដល់ថ្នាក់លើដែលជាជនមានការទទួលខុសត្រូវចំពោះខ្លាំងធ្ងន់ធ្ងរនោះរួចខ្លួន ។ លោកឧបនាយករដ្ឋមន្ត្រី សុខ អាន បានបដិសេធច្រានចោលការព្រួយបារម្ភរបស់សមាជិកសភាដោយសង្កត់ធ្ងន់ថាយុត្តាធិការផ្នែកបុគ្គលរបស់តុលាការត្រូវបានសម្រេចដោយមានការចូលរួមពីសហគមន៍អន្តរជាតិ ហើយថាការពិភាក្សាពីយុត្តាធិការរបស់តុលាការនាពេលនេះគឺជារឿងគ្មានប្រយោជន៍ ។ លោកឧបនាយករដ្ឋមន្ត្រីបានគូសបញ្ជាក់ថា មេដឹកនាំជាន់ខ្ពស់គឺជាជនសំខាន់ដែលនឹងត្រូវកាត់ទោសដោយធ្វើការកត់សម្គាល់ថា មេដឹកនាំខ្មែរក្រហមមិនលើសពីដប់នាក់ទេដែលនឹងត្រូវបានតុលាការកាត់ទោស ។ លោកក៏បាននិយាយបន្តទៀតថា អតីតកម្មាភិបាលថ្នាក់ក្រោមរបស់បក្សកុម្មុយនីស្តកម្ពុជាមួយចំនួនតូចដែលត្រូវបានសង្ស័យថាបានប្រព្រឹត្តខ្លាំងក្រៃដ្ឋកម្មធ្ងន់ធ្ងរជាងកម្មាភិបាលថ្នាក់លើរបស់ខ្លួននោះអាចនឹងត្រូវបានតុលាការកាត់ទោសដែរ ប្រសិនបើតុលាការមានភ័ស្តុតាងដើម្បីបញ្ជាក់ពីសកម្មភាពខ្លាំងក្រៃដ្ឋកម្មរបស់ជនទាំងនោះ ។ សេចក្តីសន្និដ្ឋានជាសង្ខេបមក លោក ហាន់ ជូរ៉ែល បានគូសបញ្ជាក់ថា ខ្លឹមសារនៃច្បាប់កម្ពុជា និងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាដែលជាលទ្ធផលសម្រេចបានពីដំណើរការនៃការចរចារបស់អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាដែលបានបកស្រាយខាងលើថា ខ្លឹមសារនៃច្បាប់ និងកិច្ចព្រមព្រៀងនេះបានបង្កើតប្រភេទជនសង្ស័យពីរគឺ : មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនដែលមានការទទួលខុសត្រូវខ្ពស់សម្រាប់ខ្លាំងក្រៃដ្ឋកម្ម ។ ប៉ុន្តែខ្លឹមសារដែលផ្តួយពីខ្លឹមសារខាងលើគឺស្ថិតក្នុងក្តីស្រមៃច្រើនជាង ពីព្រោះមិនមានភ័ស្តុតាងណាមួយឬក៏មូលហេតុណាមួយដែលយើងអាចជឿថាកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា បានកំណត់ថាតើជនណាដែលត្រូវនាំមុខកាត់ទោស ។ ជាក់ស្តែង អ្នកចរចាជំនាញរបស់ការិយាល័យកិច្ចការច្បាប់របស់អង្គការសហប្រជាជាតិមិនបានគូសសម្គាល់ឈ្មោះជនដែលត្រូវកាត់ទោសទេ ពីព្រោះគោលបំណងរបស់អ្នកចរចាទាំងអស់គឺចង់ឲ្យចៅក្រមស៊ើបអង្កេត និងព្រះរាជអាជ្ញារបស់តុលាការខ្មែរក្រហមយកភ័ស្តុតាងជាក់ស្តែងទៅធ្វើជាគោលដៅសម្រាប់វែកមុខជនសង្ស័យដែលជាមេដឹកនាំជាន់ខ្ពស់និងជនដែលមានការទទួលខុសត្រូវខ្ពស់ ដោយមិនចាំបាច់ធ្វើការពិភាក្សាជាមួយនឹងអង្គការសហប្រជាជាតិឬមន្ត្រីនយោបាយរបស់កម្ពុជាឡើយ ។

ការអត្ថាធិប្បាយខាងលើបានគូសបញ្ជាក់យ៉ាងច្បាស់ថា មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមរួមមានសមាជិកនៃគណៈអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជា និងអ្នកនៅក្រោមបង្គាប់របស់គណៈមជ្ឈិម ។ នៅឆ្នាំ២០០៤ ជនដែលត្រូវបានប្រកាសជាសាធារណៈថាជាប្រភេទខាងលើដែលមាននៅក្នុងបញ្ជីឈ្មោះរបស់នាយករដ្ឋមន្ត្រីហ៊ុន សែនរួមមានដូចជា នួន ជា, តា ម៉ុក, អៀង សារី, និង ខៀវ សំផន

(តែ ពក ស្លាប់នៅឆ្នាំ២០០២) ។ អៀង ធីរិទ្ធ ជាជនប្រភេទខាងលើដែលនៅរស់ហើយដែលមានចុះក្នុងបញ្ជីឈ្មោះរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ត្រូវបានប្រកាសជាសាធារណៈថាជាជនដែលអាចចាត់ទុកជាមេដឹកនាំជាន់ខ្ពស់ ដោយសារតែគាត់ធ្លាប់ធ្វើជារដ្ឋមន្ត្រីរដ្ឋាភិបាលរបស់កម្ពុជាប្រជាធិបតេយ្យ និងជាជនដែលទទួលខុសត្រូវខ្ពស់បំផុត ។ ដូច្នេះជនសង្ស័យទាំងអស់មានចំនួនប្រាំមួយរូប ។ ប្រសិនបើមានជនសង្ស័យចំនួនបួននាក់ ឬ ច្រើននាក់បន្ថែមទៀតត្រូវបានដាក់ឲ្យកាត់ទោសនោះមានន័យថាជននោះគឺជាសមាជិករបស់គណៈមជ្ឈិមនៃរបបកម្ពុជាប្រជាធិបតេយ្យ និងជាកម្មាភិបាលយោធានិងនយោបាយថ្នាក់កណ្តាលរបស់បក្សកុម្មុយនីស្តកម្ពុជា ។

ប្រាកដណាស់ បើទោះបីជាមិនយល់ស្របគ្នាក៏ដោយក៏ទាំងនាយករដ្ឋមន្ត្រី ហ៊ុន សែន និងរាជរដ្ឋាភិបាលកម្ពុជាបានសម្រេចយ៉ាងច្បាស់ថាកម្មាភិបាលថ្នាក់កណ្តាលរបស់បក្សកុម្មុយនីស្តកម្ពុជាអាចនឹងត្រូវបានតុលាការកាត់ទោស ចំណែកឯនាយករដ្ឋមន្ត្រី ហ៊ុន សែន, សម្តេច ហេង សំរិន និង សម្តេច ជា ស៊ីម មិនត្រូវបានរាប់បញ្ចូលថាជាជនប្រភេទខាងលើ ។ លទ្ធភាពនេះគឺជាការពិត បើទោះបីជាជនដែលអាចនឹងត្រូវបានកាត់ទោស គួរឲ្យសង្ស័យថាតើរាជរដ្ឋាភិបាលកម្ពុជាពិតជាបានត្រៀមខ្លួនដើម្បីទទួលយកខ្វីមសារបកស្រាយរបស់យុត្តាធិការផ្នែកបុគ្គល ដែលក្នុងនោះរួមបញ្ចូលទាំងមេដឹកនាំថ្នាក់កណ្តាលរបស់បក្សកុម្មុយនីស្តកម្ពុជា ។ យោងតាមប្រវត្តិនៃកិច្ចចរចា វាគឺច្បាស់ណាស់ថា ខ្វីមសារនៃយុត្តាធិការផ្នែកបុគ្គលនេះ គឺជាខ្វីមសារដែលអង្គការសហប្រជាជាតិចង់បាន ហើយវាក៏ជាខ្វីមសារដែលសមហេតុផលបំផុត បើនិយាយតាមផ្លូវច្បាប់ ហើយកាលដែលមេដឹកនាំថ្នាក់កណ្តាលអាចនឹងត្រូវបានកាត់ទោសនោះមិនអាចមានន័យថា មេដឹកនាំទាំងនេះអាចត្រូវបានចោទប្រកាន់ដោយតុលាការ ឬក៏ថា មានពិរុទ្ធភាពស្រាលនោះទេ ។ បញ្ហាធ្ងន់ធ្ងរបែបនេះត្រូវតែសម្រេចដោយផ្អែកលើភ័ស្តុតាងជាក់ស្តែងតាមរយៈការស៊ើបអង្កេតដ៏មានប្រសិទ្ធភាព និងមិនលម្អៀងដើម្បីបញ្ជាក់ពីការពិតនៃពិរុទ្ធភាពរបស់មេដឹកនាំថ្នាក់កណ្តាលទាំងនោះ សម្រាប់ខក្រិដ្ឋកម្មដែលពិតនៅក្រោមយុត្តាធិការតាមសាច់រឿងរបស់តុលាការខ្មែរក្រហម ។ **ស្ទឹង ហោះឌី**

ប្រកាសរកឪពុកមា និងក្រុមគ្រួសាររបស់គាត់

ខ្ញុំបាទឈ្មោះ ចូណាតាន់ តាំ សព្វថ្ងៃរស់នៅទីក្រុងតូរ៉ុនតូ ប្រទេសកាណាដា ។ ខ្ញុំបាទសូមប្រកាសស្វែងរកឪពុកមារបស់ខ្ញុំនិងគ្រួសាររបស់គាត់ដែលបានបែកគ្នានៅពេលដែលយោធាខ្មែរក្រហមវាយចូលទីក្រុងភ្នំពេញក្នុងខែមេសា ឆ្នាំ១៩៧៥ ។ ឪពុកមារបស់ខ្ញុំឈ្មោះ តាំ ណាំស៊ែ ហើយភរិយារបស់គាត់ឈ្មោះ ជុយ ណៃ ។ គាត់ទាំងពីរមានកូនប្រាំពីរនាក់ ប្រុសប្រាំនាក់ និងស្រីពីរនាក់ គឺ ១) តាំង គីមតួង, ២) តាំង សុរយទី, ៣) តាំង គីមហៃ, ៤) តាំង គីមស៊ុង, ៥) តាំង ឥសរ៊ី, ៦) តាំង អាមួយ និង ៧) តាំង មេង់ហេក ។

គ្រួសារនេះធ្លាប់រស់នៅផ្សារកាប់គោមុនរបបខ្មែរក្រហម ។ នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៩ គ្រួសារនេះត្រូវបានជម្លៀសទៅនៅស្រែក្រោម ឬស្រែស្ពាង ក្នុងស្រុកស្ពាង ខេត្តកណ្តាល ហើយតាំងពីពេលនោះមក ខ្ញុំមិនដែលទទួលដំណឹងអ្វីសោះពីគ្រួសាររបស់គាត់ ។ ប្រសិនបើមា ឬបង ឬប្អូនបានឮពីដំណឹងនេះ សូមទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈអាសយដ្ឋានផ្ទះលេខ ៦៦ ផ្លូវព្រះសីហនុ រាជធានីភ្នំពេញ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬ ០ ១៦ ៨៧៦ ៦៩២ ឬទាក់ទងមកខ្ញុំបាទផ្ទាល់តាមរយៈអ៊ីម៉ែល jon7888@gmail.com ។ ***សូមអរគុណ***

ប្រតិកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅលើសាលដីកាស្តាពររបស់ ឪុច

◆ ហេង ឆុិចហុង ភេទស្រី មកពីខេត្តកណ្តាល

ហេង ឆុិចហុង

ឪពុករបស់ខ្ញុំបានជាប់ចង់ជីវិតនៅគុកទួលស្លែង ។ មូលហេតុដែលខ្ញុំដាក់ពាក្យបណ្តឹងគឺដោយសារតែខ្ញុំចង់បានយុត្តិធម៌ ។ ខ្ញុំមានការពេញចិត្តយ៉ាងខ្លាំងចំពោះការចូលរួមរបស់ខ្ញុំកន្លងមកនៅក្នុងដំណើរការនេះ ជាពិសេស នៅពេលដែលខ្ញុំបានមើលឃើញ ឪុច ត្រូវបានតុលាការកាត់ទោសឲ្យជាប់គុកមួយជីវិត ។ ខ្ញុំគិតថាខ្ញុំទទួលបានយុត្តិធម៌ហើយ ។ សេចក្តីសម្រេចចុងក្រោយលើករណីរបស់ ឪុច នេះគឺពិតជាមានអត្ថន័យធំធេងណាស់សម្រាប់ខ្ញុំដោយសារតែនេះគឺជាយុត្តិធម៌មួយដែលធ្វើឲ្យខ្ញុំមានអារម្មណ៍អស់ចិត្ត ។ ការកាត់ទោស ឪុច គឺពិតជាមានសារសំខាន់ណាស់ ។ ឥឡូវនេះខ្ញុំមានអារម្មណ៍ធូរស្បើយ និងទទួលបានយុត្តិធម៌ហើយ ប៉ុន្តែបើចង់លើកលែងទោសឲ្យ ឪុច នោះខ្ញុំមិនអាចធ្វើបានទេ ។

◆ ង៉ែត សុខ ភេទស្រី មកពីតាកែវ

ខ្ញុំសប្បាយចិត្តណាស់ដែលខ្ញុំមានឱកាសចូលរួមក្នុងដំណើរការនេះ ។ ខ្ញុំពេញចិត្តចំពោះសេចក្តីសម្រេចចុងក្រោយនេះ ។ ខ្ញុំមានអាយុ៦៥ឆ្នាំហើយ តែខ្ញុំមិនដែលបានឆ្លងកាត់នូវព្រឹត្តិការណ៍ដែលគួរឲ្យរំភើបបែបនេះទេ ។ ឪុច ត្រូវបានកាត់ទោសដូចអ្វីដែលខ្ញុំរំពឹងទុកអីចឹង ។ នៅតាមផ្លូវពេលដែលខ្ញុំធ្វើដំណើរមកសាលាក្តីខ្មែរក្រហម ខ្ញុំមានអារម្មណ៍អន្ទះសារ និងញាប់ញ័រយ៉ាងខ្លាំងដោយសារតែនេះគឺជាថ្ងៃចុងក្រោយ ។ ទោះបីជាសំណុំរឿងករណី០០១ ត្រូវបានបញ្ចប់ក៏ដោយ ខ្ញុំនៅតែបន្តទៅករណី០០២ទៀត ក្នុងគោលបំណងតែមួយគត់គឺដើម្បីស្វែងរកយុត្តិធម៌ ។ ចំពោះខ្ញុំ ការកាត់ទោសនិងសំណងមានសារសំខាន់ដូចគ្នា ។ ខ្ញុំខិតខំស៊ូតាំងពីឆ្នាំ ២០០៦មក ឥឡូវនេះឆ្នាំ ២០១២ ហើយ ទើប ឪុច

ង៉ែត សុខ

ត្រូវបានកាត់ទោសឲ្យជាប់គុកអស់មួយជីវិត ។ ខ្ញុំមានអារម្មណ៍ធូរស្បើយបន្តិច ។ ខ្ញុំអាចត្រឡប់ទៅផ្ទះវិញ ជ្រាបក្តួនចៅរបស់ខ្ញុំនិងអ្នកជិតខាងខ្ញុំអំពីដំណឹងនេះ ។ ចំពោះសំណងវិញ ខ្ញុំគិតថាខ្ញុំអាចទទួលយកបាន ។ ការចូលរួមរបស់ខ្ញុំនៅក្នុងដំណើរការនេះគឺដើម្បីស្វែងរកការពិតនិងយុត្តិធម៌ចំពោះបងប្អូនដែលបានស្លាប់បាត់បង់ជីវិតទៅ ។

◆ អែល លីម៉ះ ភេទស្រី មកពីខេត្តកំពង់ចាម

ខ្ញុំសប្បាយចិត្តណាស់នៅពេលដែលដឹងថា ឪុច ត្រូវបានកាត់ទោសឲ្យជាប់គុកអស់មួយជីវិត ។ នេះពិតជាដំណឹងដ៏ល្អណាស់មួយសម្រាប់ខ្ញុំ ។ សាលក្រមមុនដំបូងរបស់ ឪុច ធ្វើឲ្យខ្ញុំមានការព្រួយបារម្ភយ៉ាងខ្លាំង មិនដឹងថា ឪុច អាចដើរហើរមានសេរីភាពដូចគេឯងនៅថ្ងៃណាមួយ ប្រសិនបើគាត់ពិតជាត្រូវបានកាត់ទោស

អែល លីម៉ះ

ឲ្យជាប់គុកត្រឹមតែ៣៥ឆ្នាំមែននោះ ។ ខ្ញុំសូមអរគុណយ៉ាងជ្រាលជ្រៅចំពោះតុលាការដែលបានរកយុត្តិធម៌ឲ្យបងប្រុសខ្ញុំដែលជានិស្សិតមកពីប្រទេសអេហ្ស៊ីប ប៉ុន្តែត្រូវបានយកមកសម្លាប់នៅគុកទួលស្វែងដោយមិនមានហេតុដលអ្វីទាំងអស់ ។ ចាប់តាំងពីការបាត់ខ្លួនរបស់បងប្រុស សុខភាពរបស់ឪពុកម្តាយខ្ញុំកាន់តែដុនដាបទៅៗដោយសារតែគាត់ទន្ទឹងរង់ចាំមើលផ្លូវកូនត្រឡប់មកវិញដោយអស់សង្ឃឹម ។ ប៉ុន្តែ ការទន្ទឹងរង់ចាំនោះបានប្រែក្លាយទៅជាអាសាបង់ ហើយឪពុកម្តាយខ្ញុំបានស្លាប់បន្តបន្ទាប់គ្នា ។ លោកទាំងពីរបានបន្សល់ទុកនូវបងប្អូនស្រីយើងទាំងបួននាក់ដើម្បីបន្តរង់ចាំដំណឹងពីបងប្រុសរបស់ខ្ញុំ ។

រហូតដល់ថ្ងៃមួយ មជ្ឈមណ្ឌលឯកសារកម្ពុជាបានមកជម្រាបខ្ញុំពីដំណឹងនៃការបាត់បង់ជីវិតរបស់បងប្រុសខ្ញុំនៅក្នុងគុកទួលស្វែង ។ ខ្ញុំចំណាយពេលយ៉ាងយូរមុននឹងខ្ញុំហ៊ានសម្រេចចិត្តដាក់ពាក្យបណ្តឹងទៅតុលាការខ្មែរក្រហម ដោយសារតែខ្ញុំនៅមានអារម្មណ៍កិតភ័យព្រោះខ្លាចមានការសងសឹកទៅថ្ងៃក្រោយ ។ គោលបំណងតែមួយគត់ដែលជំរុញឲ្យខ្ញុំដាក់ពាក្យបណ្តឹងទៅតុលាការនេះ គឺដើម្បីស្វែងរកយុត្តិធម៌ដល់បងប្រុសខ្ញុំដែលត្រូវបានយកទៅសម្លាប់នៅគុកទួលស្វែង ។ ប៉ុន្មានឆ្នាំកន្លងទៅនេះ ខ្ញុំពិតជាមានការពេញចិត្តយ៉ាងខ្លាំងចំពោះការចូលរួមរបស់ខ្ញុំនៅក្នុងដំណើរការតុលាការខ្មែរក្រហមនេះ ហើយតុលាការនេះកាន់តែមានអត្ថន័យថែមទៀតនៅពេលដែលខ្លួនបានធ្វើការកាត់ទោសឲ្យ ឌុច ជាប់គុកអស់មួយជីវិត ដែលនេះគឺជាយុត្តិធម៌សម្រាប់យើងទាំងអស់គ្នា ។ សាលដីកានេះមានអត្ថន័យយ៉ាងខ្លាំងចំពោះរូបខ្ញុំក៏ដូចជាប្រជាជនកម្ពុជាទូទៅ ។

ទោះជាយ៉ាងណាក៏ដោយ ខ្ញុំមិនអាចទុកនូវកន្លែងទំនេរមួយសម្រាប់លើកលែងទោសចំពោះអ៊ូដែល ឌុច បានប្រព្រឹត្តមកលើបងប្រុសរបស់ខ្ញុំក៏ដូចជាប្រជាជនស្លូតត្រង់ដែលត្រូវបានសម្លាប់នៅគុកទួលស្វែងនោះទេ ។ ខ្ញុំនៅតែខឹងគុំគួនទឹងគាត់ដោយសារតែគាត់ជាមនុស្សឃោរឃៅ ហើយអត្មានិយមគិតតែពីចង់រស់ខ្លួនឯង មិនគិតដល់អាយុជីវិតរបស់អ្នកដទៃនោះទេ ។ ឌុច និយាយថាខ្លួនគ្រាន់តែអនុវត្តតាមតែបញ្ជាតែប៉ុណ្ណោះ ដើម្បីឲ្យខ្លួនឯងរួចខ្លួនប៉ុន្តែ ឌុច មិនបានពិចារណាពីជីវិតរបស់អ្នកដទៃដែលខ្លួនពាំនាំយកមកសម្លាប់នៅក្នុងវរណ្ដៅនោះទេ ។

ដូចនេះ ខ្ញុំនៅតែមិនអាចលើកលែងទោសឲ្យ ឌុច បានទេទោះបីជាឥឡូវ ខ្ញុំមានអារម្មណ៍ថាទទួលបានយុត្តិធម៌មួយចំណែកយ៉ាងណាក៏ដោយ ។ ទាក់ទិននឹងសំណងវិញ ខ្ញុំមិនពេញចិត្តសោះ ។ ខ្ញុំតែងតែមានគំនិតចង់ធ្វើអ្វីមួយជូនដល់បងប្រុសរបស់ខ្ញុំដែលបានស្លាប់ទៅដោយជួយលាងជាបង្ហូតាត់នោះគឺបំណងចង់ធ្វើដំណើរទៅកាន់ប្រទេសស្រីលង្កាដើម្បីធ្វើឲ្យយើងទាំងអស់គ្នាអាចមានអារម្មណ៍ធូរស្បើយក្នុងចិត្ត ។

ពាក្យចុងក្រោយរបស់ខ្ញុំគឺសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះតុលាការក្នុងការនាំយកជនល្មើសមកកាត់ទោស ។

◆ លី ឃៀក ភេទប្រុស មកពីខេត្តកណ្តាល

លី ឃៀក

សាលដីកានេះគឺជាសេចក្តីសម្រេចដ៏ត្រឹមត្រូវមួយដែល

ឆ្ពោះទៅមុខដោយអត្តជំនុំជម្រះតុលាការកំពូល ។ ខ្ញុំពេញចិត្តយ៉ាងខ្លាំងចំពោះសេចក្តីសម្រេចនេះ ។

អ្វីដែលខ្ញុំចង់បានបំផុតនៅពេលដែលខ្ញុំដាក់ពាក្យបណ្តឹងនោះ គឺការស្វែងរកយុត្តិធម៌ ហើយឥឡូវនេះខ្ញុំអាចទទួលបានហើយ ។ ខ្ញុំលែងមានកង្វល់គុំកួនទៀត ហើយដោយសារតែខុច ត្រូវបានកាត់ទោសឲ្យជាប់គុកអស់មួយជីវិត ។

◆ នង គីមលៀង ភេទស្រី មកពីរាជធានីភ្នំពេញ

នៅពេលដែលបានទទួលដំណឹងថាខុចត្រូវបានកាត់ទោសឲ្យជាប់គុកអស់មួយជីវិត ខ្ញុំមានអារម្មណ៍សប្បាយរីករាយណាស់ ។ អ្វីដែលខ្ញុំចង់បានបំផុតនោះគឺយុត្តិធម៌ ជាពិសេស គឺនាំយកនូវអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតទៅធ្វើការកាត់ទោសនៅចំពោះមុខតុលាការ ។

ខ្ញុំមានការពេញចិត្តទៅនឹងការចូលរួមរបស់ខ្ញុំក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ ដោយសារតែខ្ញុំបានមើលឃើញដោយផ្ទាល់ភ្នែកនូវការនាំយកជនល្មើសមកកាត់ទោស ។ ចំពោះ ខុច នោះបើជាគាត់ត្រូវបានកាត់ទោសឲ្យជាប់គុកអស់មួយជីវិតយ៉ាងណាក៏ដោយ ក៏ខ្ញុំនៅតែមានអារម្មណ៍ខឹងនឹងគាត់ដដែល ។

◆ សួន សៀង ភេទប្រុស មកពីខេត្តកំពង់ឆ្នាំង

សួន សៀង

នៅពេលដែលបានទទួលដំណឹងថា ខុច ត្រូវបានកាត់ទោសឲ្យជាប់គុកអស់មួយជីវិត ខ្ញុំមានការសប្បាយរីករាយណាស់បើទោះបីជាការសុំគាំទ្ធខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្ញុំត្រូវបានបដិសេធនៅចំពោះមុខតុលាការយ៉ាងណាក៏ដោយ ។ ខ្ញុំមានអារម្មណ៍អស់ចិត្តហើយនៅពេលដែលតុលាការធ្វើការកាត់ទោស ខុច ឲ្យជាប់គុកអស់មួយជីវិតនោះ ។ ខ្ញុំមានការពេញចិត្តទៅនឹងការចូលរួមជាច្រើនឆ្នាំរបស់ខ្ញុំនៅក្នុងដំណើរការនេះ ។ ខ្ញុំគិតថាខ្ញុំទទួលបានយុត្តិធម៌ហើយ ។ សាលដីកានេះគឺមានសារសំខាន់និងផ្តល់ជាប្រយោជន៍យ៉ាងខ្លាំងដល់ខ្ញុំក៏ដូចជាប្រជាជនកម្ពុជាទាំងមូលផងដែរ ។ តុលាការផ្តល់នូវទំនុកចិត្តមួយដល់ខ្ញុំ គឺទំនុកចិត្តនៃការស្វែងរកយុត្តិធម៌ ។ នេះក៏អាចជួយឲ្យក្មេងៗជំនាន់ក្រោយបានរៀនសូត្រយល់ដឹងអំពីប្រវត្តិសាស្ត្រខ្លួនឯង ដើម្បីចូលរួមទប់ស្កាត់កុំឲ្យខ្មែក្រហមឬដដែលនេះកើតឡើងជាថ្មីម្តងទៀតបានឡើយនៅថ្ងៃអនាគត ។ ចំពោះសំណងវិញនោះ ដោយសារតែខ្ញុំមិនត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំមិនដឹងថាត្រូវស្នើសុំអ្វីនោះទេក្រៅពីស្របតាមសេចក្តីសម្រេចរបស់តុលាការតែប៉ុណ្ណោះ ។ ចំពោះខ្ញុំ ខុច គឺជាជនដៃដល់ម្នាក់ដែលសាហាវឃោរឃៅណាស់ ។ បើទោះបីជាខ្លួនគាត់ធ្វើតាមបញ្ជាឬអត់យ៉ាងណាក្តី ខ្ញុំនៅតែខឹងនឹងគាត់ដដែល ។ ដោយសារតែនេះគឺជាថ្ងៃចុងក្រោយហើយ ខ្ញុំអាចមានអារម្មណ៍ធូរស្បើយលែងគិតខ្វល់ខ្វាយពីដំណើរការនេះទៀតហើយ ។ ពាក្យចុងក្រោយរបស់ខ្ញុំគឺសេចក្តីថ្លែងអំណរគុណចំពោះតុលាការនិងមជ្ឈមណ្ឌលឯកសារកម្ពុជាសម្រាប់អ្វីៗទាំងអស់ដែលបានផ្តល់ឲ្យខ្ញុំ ។ ខ្ញុំគ្មានអ្វីផ្តល់ជូនវិញទេក្រៅពីការថ្លែងអំណរគុណដ៏ស្មោះស្ម័ត្រពីខ្ញុំ ។ ខ្ញុំពិតជាពេញចិត្តខ្លាំងណាស់ ។

◆ ពូល ពន្ធឹក ភេទប្រុស មកពីរាជធានីភ្នំពេញ

ទោះបីជាខ្ញុំមិនបានទៅតាមដានដោយផ្ទាល់នូវការប្រកាសសាលដីកាចុងក្រោយរបស់ ខុច នៅតុលាការក៏ដោយ ក៏ខ្ញុំបានតាមដានយ៉ាងដិតដល់នៅផ្ទះដែរ ហើយខ្ញុំមានការពេញចិត្តយ៉ាងខ្លាំងទៅនឹងការកាត់ទោសនេះ ។ សេចក្តីសម្រេចនេះបានជួយឲ្យខ្ញុំកាត់បន្ថយនូវការឈឺចាប់ជាពិសេសជួយឲ្យខ្ញុំមានអារម្មណ៍ធូរស្បើយបន្តិចដែរ ។ សាលដីកានេះគឺមានសារសំខាន់ណាស់ចំពោះខ្ញុំក៏ដូចជាប្រជាជនកម្ពុជាទាំងអស់ផងដែរ ។ វាបម្រើជាតិយើងទាំងមូល ។ តុលាការធ្វើការកាត់ទោសខ្មែក្រហមធ្ងន់ធ្ងរនៅក្នុងប្រវត្តិសាស្ត្ររបស់មនុស្សជាតិ ដែលនេះបានចូលរួមចំណែកនៅក្នុងការកសាងនីតិរដ្ឋដ៏រឹងមាំមួយនៅក្នុងប្រទេសកម្ពុជា ។ តុលាការបានជួយស្វែងរកយុត្តិធម៌ដល់យើងដែលជាជនរងគ្រោះ

ហើយបានជួយបង្កើតនូវមេរៀនប្រវត្តិសាស្ត្រដ៏ពេញលេញមួយ របស់ប្រទេសកម្ពុជាសម្រាប់បន្តដល់ក្មេងៗជំនាន់ក្រោយបាន សិក្សារៀនសូត្រ ក៏ដូចជាអ្នកដឹកនាំបន្តបន្ទាប់ទៀតឲ្យដៀសវាង ខ្ចក្រឡៃកម្មប្រល័យពូជសាសន៍ដដែលនេះ ។ ហេតុដូចនេះ សេចក្តី សម្រេចនេះគឺមានសារសំខាន់ណាស់ ។ នៅពេលដែលខ្ញុំដាក់ពាក្យ បណ្តឹង អ្វីដែលខ្ញុំចង់បានបំផុតនោះគឺយុត្តិធម៌ ។ ខ្ញុំយល់យ៉ាងច្បាស់ ថា តុលាការពុំមានលទ្ធភាពក្នុងការផ្តល់សំណងដល់ជនរងគ្រោះរាប់ លាននាក់នោះទេ ។ អ្វីដែលសំខាន់គឺថាអ្នកជាទីស្រឡាញ់របស់យើង ក៏បានស្លាប់ជាត់បង់ជីវិតទៅហើយ ។ ដូចនេះ ពុំមានសំណងណាអាច ប៉ះប៉ូវឲ្យស្មើនឹងទំហំនៃការឈឺចាប់នេះបានឡើយ ។ យ៉ាងណាមិញ ការកាត់ទោស ឌុច នេះគឺបានក្លាយជាផ្នែកមួយនៃសំណងដែល ពួកយើងចង់បានគ្រប់គ្នា ដោយសារតែការកាត់ទោសនេះអាច ជួយសម្រួលនិងកាត់បន្ថយនូវការឈឺចាប់ដែលចេះតែរំខានដល់ សតិអារម្មណ៍របស់យើងទាំងអស់ជាច្រើនឆ្នាំមកហើយនោះ ។ បើទោះបីជាដំណើរការស្វែងរកយុត្តិធម៌នេះបានជួយកាត់បន្ថយ នូវការឈឺចាប់និងទទួលបាននូវយុត្តិធម៌មួយកម្រិតយ៉ាងណាក្តី ក៏ខ្ញុំនៅតែមិនអាចមានអារម្មណ៍អស់ចិត្តទាំងស្រុងទេ ។ ខ្ញុំចង់ មើលឃើញនូវការរៀបចំពិធីបុណ្យតាមបែបសាសនាឬតាម ប្រពៃណីធ្វើឡើងដើម្បីឧទ្ទិសជូនដល់អ្នកទាំងឡាយដែលបានស្លាប់ ជាត់បង់ជីវិតនៅជំនាន់នោះដើម្បីធ្វើការព្យាបាលរបួសផ្លូវចិត្ត កាលពីអតីតកាល ។ សូមឧទ្ទិសដល់អ្នកដែលចែកឋានទាំងអស់ ឲ្យបានទៅកាន់សុគតិភព ។

ពូល ពត្តីក

ខ្ញុំមានការពេញចិត្តទៅនឹងការចូលរួមរបស់ខ្ញុំនៅក្នុង ដំណើរការនីតិវិធីតុលាការជាច្រើនឆ្នាំកន្លងមកនេះ ។ ជាពិសេស ដំណើរការនេះបានបញ្ចប់ទៅដូចអ្វីដែលយើងទាំងអស់គ្នាដែលជា ជនរងគ្រោះបានរំពឹងទុកអ៊ីចឹង ។ ការចូលរួមរបស់ជនរងគ្រោះនេះ ពិតជាមានអត្ថន័យណាស់ចំពោះខ្ញុំ ។ ប្រសិនបើខ្ញុំមិនបានចូលរួមក្នុង ដំណើរនេះ ខ្ញុំច្បាស់ជាមានការសោកស្តាយយ៉ាងខ្លាំង ។ ដោយសារ តែខ្ញុំបានចូលរួមក្នុងដំណើរការនេះ ខ្ញុំអាចទទួលបានអារម្មណ៍ធូរ ស្បើយបន្តិច ។ ចំពោះខ្ញុំ ឌុច គឺគ្រាន់បើជាងមេដឹកនាំខ្មែរក្រហមដ៏ កំសាកទាំងនោះដែលមិនព្រមនិយាយអ្វីទាំងអស់ ។ ឌុច បាន ព្យាយាមលាតត្រដាងនូវរឿងរ៉ាវជាច្រើនដែលនៅពីក្រោយរបប ខ្មែរក្រហម ។ ឌុចបានសារភាពនូវទោសកំហុសរបស់ខ្លួនឯង ។ ឌុច បានចូលរួមចំណែកបំភ្លឺប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម ដែល ពោរពេញដោយភាពស្មុគស្មាញនេះ ។ ដូចនេះ ខ្ញុំគិតថា ខ្ញុំលែង មានកំហឹងគុំគួននឹង ឌុច ទៀតហើយ ។ វាបានមកដល់ទីបញ្ចប់ ហើយ ។ តុលាការបានកាត់ទោសឲ្យឌុចជាប់គុកអស់មួយជីវិត ។ ការបញ្ចប់ប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតតាមរយៈនីតិវិធីតុលាការនេះ គឺជាចំណុចមួយទៀតដែលជួយឲ្យខ្ញុំមានអារម្មណ៍ធូរស្បើយចិត្ត ដោយសារតែតុលាការនឹងមិនអនុញ្ញាតឲ្យជនល្មើសមានសេរីភាព ដើរហើរបានឡើយ ។ ពាក្យចុងក្រោយរបស់ខ្ញុំ គឺសូមថ្លែងអំណរគុណ ដល់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានជួយឲ្យខ្ញុំបានចូលរួមនៅក្នុង ដំណើរការស្វែងរកយុត្តិធម៌នេះ ក៏ដូចជា សូមអរគុណយ៉ាងជ្រាល ជ្រៅដងដែរចំពោះតុលាការដែលបានផ្តល់នូវយុត្តិធម៌សម្រាប់ខ្ញុំក៏ ដូចជាជនរងគ្រោះទាំងអស់ ។

◆ ទ្រី ងុិចលាង ភេទស្រី មកពីខេត្តកណ្តាល

មុនដំបូង ខ្ញុំគ្រាន់តែដឹងថាបងប្រុសរបស់ខ្ញុំស្លាប់ជាត់ទៅ ហើយ ដោយមិនមាននរណាម្នាក់ទទួលខុសត្រូវនោះទេ ។ រហូត ដល់ថ្ងៃមួយនៅពេលដែលមានឯកសារមួយបានផ្តល់ឲ្យខ្ញុំ ទើបខ្ញុំ ដឹងថាបងប្រុសរបស់ខ្ញុំត្រូវបានយកទៅសម្លាប់នៅគុកទួលស្វែង ។ បងប្រុសរបស់ខ្ញុំចាកចេញពីផ្ទះនៅក្នុងឆ្នាំ១៩៧៥ ។ បន្ទាប់ពី គាត់បានមកលេងផ្ទះម្តងក្រោយជ័យជម្នះ១៩៧៥ ពួកយើង លែងបានទទួលដំណឹងពីគាត់ទៀតហើយ ។ គ្រួសាររបស់ខ្ញុំទាំង អស់គ្នាមានការសោកស្តាយយ៉ាងខ្លាំងចំពោះការបាត់បង់ជីវិត

ទ្រី ដុិចលាត

ហ៊ឹម មុំ

របស់បងប្រុស ។

ប៉ុន្មានឆ្នាំបន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម ម្តាយរបស់ខ្ញុំបានទៅរកគ្រូទាយដើម្បីសាកសួរពីដំណឹងរបស់បងប្រុស ។ ទោះបីជាម្តាយខ្ញុំមានអារម្មណ៍ធូរស្បើយបន្តិចក្រោយពេលដែលគ្រូទាយប្រាប់គាត់ថាបងប្រុសនៅរស់រានមានជីវិតនោះ គាត់ក្រោយមកត្រូវប្រឈមនឹងការពិតដែលថាកូនប្រុសរបស់គាត់ត្រូវបានយកទៅសម្លាប់នៅគុកទួលស្លែង ។ ទាក់ទិនទៅនឹងសំណងវិញ ខ្ញុំទទួលយកនូវអ្វីដែលតុលាការផ្តល់ឲ្យ ។ ខ្ញុំពេញចិត្តទៅនឹងការកាត់ទោស ឌុច ឲ្យជាប់គុកអស់មួយជីវិត ។ ការកាត់ទោសនិងសំណងគឺមានសារសំខាន់ដូចគ្នា ។ ខ្ញុំសប្បាយចិត្តយ៉ាងខ្លាំងដែលបានចូលរួមនៅក្នុងសវនាការសំណុំរឿង០០១ ។ ខ្ញុំលែងមានអារម្មណ៍ខឹងគុំគួននឹង ឌុច ទៀតហើយ ដោយសារតែរឿងនេះបានកើតឡើងយូរណាស់មកហើយ ។ យុត្តិធម៌ក៏បានផ្តល់ឲ្យប្រជាជនផងដែរដោយសារតែ ឌុច ត្រូវបានកាត់ទោសឲ្យជាប់គុកអស់មួយជីវិត ។ សាលដីកានេះគឺអាចទទួលយកបាន ។ ខ្ញុំជឿថាសាលដីការបស់ ឌុច នេះ ធ្វើឲ្យប្រជាជនទូទៅមានការពេញចិត្តយ៉ាងខ្លាំង ។ ខ្ញុំសង្ឃឹមថាសំណុំរឿង០០២ ក៏នឹងដំណើរការទៅដូចគ្នាអីចឹងដែរ ។

◆ ហ៊ឹម មុំ ភេទស្រី មកពីខេត្តតាកែវ

ខ្ញុំយល់ឃើញថាការចូលរួមរបស់ខ្ញុំនៅក្នុងសំណុំរឿង០០១នេះ គឺពិតជាមានអត្ថន័យខ្លាំងណាស់ ដោយសារតែតុលាការបានទទួលស្គាល់ខ្ញុំជាដើមបណ្តឹងរដ្ឋប្បវេណី ហើយខ្ញុំមានការយល់ដឹងកាន់តែច្បាស់ថែមទៀតពីនីតិវិធីរបស់តុលាការ ហើយអ្វីដែលសំខាន់បំផុតនោះ គឺខ្ញុំទទួលបានយុត្តិធម៌ ។ ខ្ញុំពេញចិត្តណាស់ចំពោះការកាត់ទោស ឌុច ឲ្យជាប់ពន្ធនាគារអស់មួយជីវិត ។ ប៉ុន្តែ ខ្ញុំនៅតែមិនអាចអត់ទោសឲ្យគាត់បានទេ ពីព្រោះគាត់បានសម្លាប់មនុស្សអស់រាប់ពាន់នាក់ ដែលក្នុងនោះរួមទាំងបងប្រុសរបស់ខ្ញុំម្នាក់ដែរ ។ នៅពេលដែលខ្ញុំមើលឃើញរូបថតបងប្រុសរបស់ខ្ញុំ រឿងរ៉ាវហាក់ដូចជានៅស្រស់ៗអីចឹង ។ ឥឡូវនេះ ឌុច សមនឹងទទួលនូវអ្វីគាត់បានប្រព្រឹត្តហើយ ។ ខ្ញុំមានអារម្មណ៍ធូរស្បើយមួយកម្រិតធំ ហើយយល់ថា ខ្លួនឯងអស់ចិត្តហើយចំពោះការឈឺចាប់ដែលកើតចេញពីកេរដំណែលរបស់ខ្មែរក្រហមរាប់សិបឆ្នាំកន្លងមកនេះ ។ សាលដីកាឌុចនេះអាចធ្វើឲ្យប្រជាជនទទួលបាននូវអារម្មណ៍អស់ចិត្ត ហើយក៏បម្រើជាមេរៀនប្រវត្តិសាស្ត្រមួយសម្រាប់ប្រជាជាតិរបស់យើងផងដែរ ។ ខ្ញុំអាចទទួលយកបាននូវសំណងជាសមូហភាពដែលតុលាការផ្តល់ឲ្យ ។

◆ យុន ឈឺន ភេទប្រុស មកពីខេត្តកណ្តាល

ខ្ញុំគិតថា ខ្ញុំពិតជាមានសំណាងណាស់ដែលមានឱកាសបានចូលរួមក្នុងដំណើរការកាត់សេចក្តីនៅក្នុងសំណុំរឿង០០១នេះ ដោយសារតែ ឌុច ត្រូវបានតុលាការកាត់ទោសឲ្យជាប់គុកអស់មួយជីវិតចំពោះការសម្លាប់ប្រជាជនរាប់ម៉ឺននាក់នៅគុកទួលស្លែង ។ ខ្ញុំពេញចិត្តទៅនឹងការកាត់ទោស ឌុច ឲ្យជាប់គុកអស់មួយជីវិត ។ ឌុចប្រព្រឹត្តបទល្មើស ដូចនេះគាត់សមនឹងទទួលទោសជាប់គុកអស់មួយជីវិតនេះ ។ ខ្ញុំមានអារម្មណ៍ធូរស្បើយបន្តិចនៅពេលដែលដឹង

យុន ឈឺន

ថាយុត្តិធម៌ត្រូវបានផ្តល់ឲ្យដល់ក្មួយប្រុសរបស់ខ្ញុំ និងប្រជាជនដែលស្លាប់បង់ជីវិតក៏ដូចជាអ្នកដែលរួចរស់មានជីវិតពីគុកទួលស្លែង។ ខ្ញុំគោរពទៅតាមសេចក្តីសម្រេចចុងក្រោយនេះដែលធ្វើឡើងដោយតុលាការ។ ខ្ញុំមិនដែលគិតថាចង់សងសឹកនឹងឪុច ទេ ប៉ុន្តែខ្ញុំគ្រាន់តែមិនអាចបំភ្លេចនូវអ្វីដែលកើតឡើងកាលពីជំនាន់នោះបានតែប៉ុណ្ណោះ។ ខ្ញុំនឹងជ្រាបដល់ក្មេងៗជំនាន់ក្រោយអំពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយខ្មែរក្រហម ដោយសារតែនេះគឺជាប្រវត្តិសាស្ត្រមួយរបស់ប្រទេសយើង ហើយការដែលលើកយករឿងរ៉ាវនេះមកនិយាយគឺអាចជួយជួរជួរសង្គមរបស់យើងបាន។ តុលាការនេះពិតជាបានផ្តល់នូវយុត្តិធម៌ជូនប្រជាជនពិតមែន។ ការចូលរួមពីសំណាក់ជនរងគ្រោះនៅក្នុងដំណើរការរបស់តុលាការនេះ គឺពិតជាមានសារសំខាន់ណាស់។ តុលាការបានធ្វើការងារជាប្រើនជូនដល់ប្រជាពលរដ្ឋ ជាពិសេសគឺការផ្តល់នូវយុត្តិធម៌ជូនប្រជាជន។ ដូចនេះ ខ្ញុំពេញចិត្តចំពោះសំណង់ដែលតុលាការផ្តល់ឲ្យនេះ។

◆ យឹម ឡេង ភេទប្រុស មកពីខេត្តកំពង់ធំ

សុបិន្តរបស់ខ្ញុំបានក្លាយទៅជាការពិតនៅពេលដែលខ្ញុំបានទទួលដំណឹងថា ឪុច ត្រូវបានកាត់ទោសឲ្យជាប់គុកអស់មួយជីវិត។ ឪុច បានសម្លាប់ឪពុករបស់ខ្ញុំ ដូចនេះ ខ្ញុំមានការពេញចិត្តណាស់នៅពេលដែលឮថា ឪុច ត្រូវចំណាយពេលចុងក្រោយរបស់ខ្លួននៅក្នុងពន្ធនាគារ។ ខ្ញុំមិនអាចលើកលែងទោសឲ្យ ឪុច បានទេ។ ឪុច ត្រូវតែជាប់គុក។ ទោះបីជាមានអារម្មណ៍ធូរស្បើយបន្តិចទៅនឹងសាលដីការបស់ ឪុច យ៉ាងណាក្តី ខ្ញុំនៅតែរង់ចាំមើលការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ទាំងបីនាក់នោះទៀត ដោយសារតែអ្នកទាំងនោះគឺជាស្តាបនិកនៃរបបកាប់សម្លាប់យ៉ាងរន្ធត់កាលពីជំនាន់នោះ។ សាលដីកា ឪុច នេះ គឺជាមេរៀនមួយសម្រាប់ជនរាល់គ្នាកុំឲ្យធ្វើតម្រាប់តាមឧក្រិដ្ឋកម្មដ៏ឃោរឃៅនេះទៀត។ សាលដីកានេះបង្រៀនខ្មែរកុំឲ្យសម្លាប់ខ្មែរ ពីព្រោះថាបើខ្មែរគិតតែពីសម្លាប់គ្នានោះច្បាស់ជាគ្មានខ្មែរសល់នៅលើលោកនេះទៀតទេ។ ចំពោះខ្ញុំ សំណង់ដែលតុលាការផ្តល់ឲ្យនេះគឺអាចទទួលយកបាន។ រីឯដំណើរការលើសំណុំរឿង ០ ០ ១ នេះប្រព្រឹត្តទៅបានល្អណាស់។ ចំពោះខ្ញុំ យុត្តិធម៌គឺមានអត្ថន័យប្រើនជាងការផ្តល់សំណង។

◆ ស្មាន ណុប ភេទស្រី មកពីខេត្តកណ្តាល

ខ្ញុំដាក់ពាក្យបណ្តឹងនេះគឺដើម្បីធ្វើការស្វែងរកយុត្តិធម៌និងធ្វើឲ្យខ្លួនមានអារម្មណ៍អស់ចិត្ត។ តាមពិតខ្ញុំមិនចង់លើករឿងអតីតកាលមកនិយាយទេ ដោយសារតែក្រុមគ្រួសាររបស់ខ្ញុំភាគច្រើនត្រូវបានខ្មែរក្រហមយកទៅសម្លាប់។ ខ្ញុំត្រេកអរណាស់នៅពេលដែលដឹងថា ឪុច ត្រូវបានកាត់ទោសឲ្យជាប់គុកអស់មួយជីវិត។ ខ្ញុំមិនអាចលើកលែងទោសឲ្យ ឪុច បានទេ ដោយសារតែ ឪុច នេះបានសម្លាប់មនុស្សជាច្រើន។ ខ្ញុំយល់ថា ឪុច សមនឹងទទួលទោសនេះណាស់។ កាលពីសាលក្រមដំបូង ខ្ញុំមិនពេញចិត្តទេ តែចុងក្រោយនេះ ខ្ញុំរីករាយណាស់នៅពេលដែលដឹងថា ឪុច ត្រូវបានកាត់ទោសឲ្យជាប់គុកអស់មួយជីវិត។

◆ ចាន់ ក្រូច ភេទប្រុស មកពីខេត្តកំពង់ធំ

ខ្ញុំមានអារម្មណ៍ធូរស្បើយបន្តិចនៅពេលដែលស្តាប់ឮនូវសេចក្តីសម្រេចលើសាលដីការបស់ ខុច ។ ការកាត់ទោសឲ្យ ខុច ជាប់គុកអស់មួយជីវិតនេះគឺជាសេចក្តីសម្រេចដ៏ត្រឹមត្រូវបំផុត ។ ខ្ញុំសប្បាយរីករាយណាស់ទៅនឹងការសម្រេចសេចក្តីនេះដោយសារតែវាដូចជាអ្វីដែលយើងទាំងអស់គ្នាចង់បាន ។ ខ្ញុំបានទន្ទឹងរង់ចាំថ្ងៃនេះអស់រយៈពេលជាយូរមកហើយ ឥឡូវនេះការទន្ទឹងរង់ចាំនេះបានក្លាយទៅជាការពិត ។ ខ្ញុំសូមសំដែងនូវសេចក្តីថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះតុលាការក៏ដូចជាមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានជួយខ្ញុំស្វែងរកយុត្តិធម៌ ។ ខ្ញុំលែងមានកំហឹងគុំគួននឹង ខុច ទៀតហើយ ដោយសារតែ ខុច ឥឡូវនេះត្រូវបានកាត់ទោសឲ្យជាប់គុកអស់មួយជីវិតទៅហើយ ។ ជាពិសេស ខុច គឺជាមនុស្សជាម្នាក់មិនអាចទៅធ្វើអ្វីទៀតបានទេក្រៅពីដេកគុក ។ ទាក់ទិននឹងការមិនផ្តល់សំណងវិញ ខ្ញុំមិនពេញចិត្តទេ តែមិនដឹងជាត្រូវធ្វើយ៉ាងដូចម្តេចដោយសារតែនេះគឺជាសេចក្តីសម្រេចរបស់តុលាការកំពូល ។ ការកាត់ទោសជនល្មើសពិតជាមានសារសំខាន់ណាស់ដោយសារតែជនល្មើសត្រូវតែទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលខ្លួនបានប្រព្រឹត្ត ។ នេះគឺដើម្បីបង្ហាញពីនីតិរដ្ឋដ៏រឹងមាំនៅក្នុងប្រទេស ។ ទោះបីជាយ៉ាងណាក្តី ខ្ញុំពេញចិត្តទៅនឹងការចូលរួមរបស់ខ្ញុំនៅក្នុងដំណើរការនីតិវិធីអស់រយៈពេលជាច្រើនឆ្នាំកន្លងមកនេះ ។ នៅពេលមើលឃើញតុលាការបានផ្តល់នូវយុត្តិធម៌ដល់រូបខ្ញុំក៏ដូចជាបានមើលឃើញដោយផ្ទាល់ភ្នែកនូវការកាត់ទោសមេដឹកនាំទាំងនោះ ធ្វើឲ្យខ្ញុំពិតជាមានអារម្មណ៍ធូរស្បើយ ។ ខ្ញុំគិតថាខ្ញុំអាចធ្វើការដេ្ឋរដ្ឋាបាន ។

◆ ស្មាន ស ភេទស្រី មកពីខេត្តកណ្តាល

ការជាប់ចង់កួនប្រុសរបស់ខ្ញុំគឺជាការជាប់ចង់ដ៏ធំធេងសម្រាប់ខ្ញុំ ។ ខ្ញុំមិនចង់និយាយអ្វីទាំងអស់ ។ អ្វីដែលខ្ញុំអាចធ្វើបានគឺមានតែនៅស្ងាត់ស្ងៀម ។ ខ្ញុំយល់ស្របទៅនឹងអ្វីៗទាំងអស់ដែលតុលាការសម្រេច ។ ខ្ញុំលែងមានកំហឹងគុំគួននឹងនរណាម្នាក់ទៀតហើយ ពីព្រោះថាទោះបីជានិយាយរឿងចេញមកក្រៅក៏មិនអាចហៅឲ្យអ្វីដែលបានជាប់ចង់ទៅឲ្យត្រឡប់មកវិញបានដែរ ។ ខ្ញុំមិនចង់ដឹងចង់ឮអ្វីដែលទាក់ទិននឹងអ្នកទាំងនោះទេ ហើយខ្ញុំក៏មិនចង់រំឭករឿងអតីតកាលដងដែរ ។ ទុកឲ្យ ខុច ហ្នឹងស្ងាប់ទៅចុះ ។ ឥឡូវខ្ញុំអត់គិតពីរឿងនេះទៀតទេ ធ្វើបែបនេះគឺអាចឲ្យខ្ញុំមានអារម្មណ៍ធូរស្បើយបានខ្លះ ។ ខ្ញុំចង់ចំណាយពេលវេលាសេសសល់របស់ខ្ញុំទៅធ្វើបុណ្យវិញ ។ ខ្ញុំចាស់ជរាណាស់ទៅហើយ មិនអាចគិតរឿងហ្នឹងទៀតទេ ។

◆ ម៉ែន ថ្លាយ ភេទស្រី មកពីខេត្តកណ្តាល

ខ្ញុំពេញចិត្តទៅនឹងសេចក្តីសម្រេចរបស់តុលាការក្នុងការកាត់ទោស ខុច ឲ្យជាប់គុកអស់មួយជីវិត ។ កាលពីដំបូងខ្ញុំមានអារម្មណ៍ខឹងសម្បារយ៉ាងខ្លាំងដោយសារតែកូនរបស់ខ្ញុំត្រូវបានយកទៅសម្លាប់នៅគុកទួលស្លែង ។ ខ្ញុំខិតខំចិញ្ចឹមកូន ថ្នាក់ថ្នមកូន តែបែរជាកូនត្រូវបានយកមកសម្លាប់នៅគុកទួលស្លែងទៅវិញ ។ កូនរបស់ខ្ញុំជាអតីតយោធាខ្មែរក្រហមម្នាក់ ហើយនៅពេលដែលវា

ត្រូវបានដាស់ទៅកន្លែងមួយទៀតនៅឆ្នាំ១៩៧៦ ពួកយើងលែងទទួលដំណឹងពីគ្នាហួត ។ យើងមិនទឹកស្មានថាកូននេះត្រូវបានបញ្ជូនទៅសម្លាប់ដូច្នេះសោះ ។ យើងតែងតែគិតថាកូននេះជ្រាកដជាបានសុខហើយក្នុងនាមជាយោធាខ្មែរក្រហមម្នាក់ ។ ប៉ុន្តែ ក្រោយឆ្នាំ១៩៧៩ ខ្ញុំបានទទួលដំណឹងថា កូនខ្ញុំត្រូវបានយកទៅសម្លាប់ទៅគុកទួលស្លែង តែខ្ញុំមិនមានឱកាសទៅទីនោះដើម្បីរកមើលរូបថតកូនរបស់ខ្ញុំសោះ ។ ការស្លាប់របស់កូនខ្ញុំពិតជាផ្តល់ផលប៉ះពាល់យ៉ាងខ្លាំងដល់រូបខ្ញុំ ។ ខ្ញុំតែងតែនឹកគិតដល់កូនរបស់ខ្ញុំជានិច្ច ។ ខ្ញុំក៏មានកូនស្រីម្នាក់ឈ្មោះ មិន សុខន ជាប់ខ្លួននៅក្នុងជំនាន់ខ្មែរក្រហមដែរ ។ កូនស្រីរបស់ខ្ញុំធ្វើការនៅទីក្រុងភ្នំពេញមុនឆ្នាំ ១៩៧៥ ។ ចាប់តាំងពីពេលនោះមក ខ្ញុំមិនបានទទួលដំណឹងពីកូនស្រីខ្ញុំទៀតទេ ។ ដោយសារតែខ្ញុំជាប់បង់កូន ទើបខ្ញុំសម្រេចចិត្តដាក់ពាក្យបណ្តឹងទៅតុលាការខ្មែរក្រហមដោយមិនមានបំណងចង់ទាមទារសំណងអ្វីទាំងអស់ ។ ខ្ញុំនឹងទទួលយកអ្វីៗទាំងអស់ដែលតុលាការផ្តល់ឲ្យ ។ ខ្ញុំមានអារម្មណ៍ធូរស្បើយនៅពេលឮថាតុលាការកាត់ទោស ឌុច ឲ្យជាប់គុកអស់មួយជីវិត ។ ប៉ុន្តែចំពោះខ្ញុំវិញ ខ្ញុំលែងបានឃើញមុខកូនខ្ញុំទៀតហើយ ។ ខ្ញុំអាណិតកូនខ្ញុំណាស់ ។

ម៉ែន ម្ភាយ

ខ្ញុំពេញចិត្តនឹងការចូលរួមរបស់ខ្ញុំកន្លងមកនៅក្នុងដំណើរការនេះ ។ ចំពោះ ឌុច ខ្ញុំនៅតែគិតថា គាត់គឺជាឃាតករ ។ ទោះបីជាខ្ញុំមានអារម្មណ៍ធូរស្បើយនៅពេលដែលឃើញតុលាការកាត់ទោស ឌុច ឲ្យជាប់គុកអស់មួយជីវិតយ៉ាងណាក្តី ខ្ញុំនៅតែមិនអាចលើកលែងទោសឲ្យគាត់ដោយសារតែទំហំនៃការឈឺចាប់និងការបាត់បង់មានសភាពធំធេងដែលមិនអាចបំភ្លេចបានឡើយ ។ ខ្ញុំដេកមិនលក់ដោយសារតែខ្ញុំតែងតែនឹកឃើញនូវការឈឺចាប់និងទុក្ខលំបាករបស់កូនខ្ញុំជានិច្ចនៅក្នុងរបបនោះ ។ សាលដីកានេះពិតជាមានសារសំខាន់ណាស់ទុកសម្រាប់ឲ្យក្មេងៗជំនាន់ក្រោយបានសិក្សារៀនសូត្រអំពីអតីតកាលបន្ទាប់ពីយើងចាស់ៗស្លាប់ជាប់បង់ជីវិតទៅ ។ ទាក់ទិនទៅនឹងសំណងវិញ ខ្ញុំពេញចិត្តក្នុងការចារឈ្មោះរបស់ខ្ញុំជាផ្លូវការក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសាលដីកាស្តាពរក្នុងករណី០០១ និងឈ្មោះរបស់កូនខ្ញុំដែលបានស្លាប់នៅគុកទួលស្លែង ។ ចំពោះខ្ញុំ ទោះជាយ៉ាងណាក៏ដោយ ការកាត់ទោសគឺមានសារសំខាន់ជាងសំណង ។ អ្វីដែលខ្ញុំខ្វល់ខ្វាយបំផុតនោះគឺការកាត់ទោសឌុច ។ ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណចំពោះតុលាការ ។

មជ្ឈមណ្ឌលឯកសារកម្ពុជា

ដំណឹងសួររកពូ

នាងខ្ញុំឈ្មោះ លឹម ភានុវណ្ណធ្យីសីហៈ រស់នៅសង្កាត់សន្សំកុសល ខណ្ឌមានជ័យ ក្រុងភ្នំពេញ សូមប្រកាសរកពូឈ្មោះ ហាក់ អុល មកដល់បច្ចុប្បន្នមានអាយុ៧២ឆ្នាំ ។ កាលពីសម័យ លន់ នល់ ពូរបស់នាងខ្ញុំមានផ្ទះនៅទួលគោក ហើយគាត់ធ្វើជាប៉េអឹម ។ គាត់បានបែកពីគ្រួសារនៅម្តុំវត្តលង្កា ពេលដែលខ្មែរក្រហមជម្លៀសប្រជាជនចេញពីក្រុងឆ្នាំ១៩៧៥ ។ ចាប់តាំងពីពេលនោះមក គ្រួសារនាងខ្ញុំបាត់ដំណឹងគាត់រហូត ។

ប្រសិនបើ បងប្អូនណាបានដឹង ឬស្គាល់ឈ្មោះពូរបស់នាងខ្ញុំ សូមមេត្តាទាក់ទងមកនាងខ្ញុំតាមរយៈទូរស័ព្ទលេខ ៖ ០១៥ ៥៥៥ ០០៧ ឬ ០១២ ៩៩៦ ៧៥០ ឬ មជ្ឈមណ្ឌលឯកសារកម្ពុជា តាមរយៈអាសយដ្ឋាន ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ខណ្ឌចំការមន ក្រុងភ្នំពេញ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។

សូមអរគុណ ។

ជំណើរជីវិតគ្រួសារខ្ញុំក្រោមរបប ប៉ុល ពត

នៅព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ យោធាអាវខ្មៅ ប៉ុល ពត បានចូលមកដល់និងកាន់កាប់ទីក្រុងភ្នំពេញ។ កាលនោះខ្ញុំមានអាយុជ្រាំបីឆ្នាំ ប៉ុន្តែរាល់ព្រឹត្តិការណ៍ទាំងឡាយដែលបានកើតឡើងនៅពេលនោះនៅតែដក់ជាប់ក្នុងអារម្មណ៍របស់ខ្ញុំជានិច្ចរហូតដល់ពេលបច្ចុប្បន្ន។ ជ្រាកដណាស់សម្រាប់រូបខ្ញុំ ទោះបីជាជាតិនេះ ឬជាតិក្រោយ ក៏ខ្ញុំនៅចងចាំជានិច្ចនូវអំពើខ្រង់ដ្ឋដ៏ព្រៃផ្សៃនៃរបបខ្មែរក្រហមដែលបានធ្វើមកលើគ្រួសារខ្ញុំដោយអង្គការចាត់ទុកថា គ្រួសារខ្ញុំជាប្រជាជន១៧ មេសា ជាវណ្ណៈមូលធនជាវណ្ណៈជិះជាន់ ជាទិសដៅចម្បងរបស់អង្គការដែលត្រូវតែកម្ទេចឲ្យអស់ក្រោមពាក្យស្លោកថា «ជីកស្មៅត្រូវជីកឫសទាំងឫស»។ ក្រោយពេលកាន់កាប់ក្រុងភ្នំពេញបានហើយ ខ្មែរក្រហមបានជម្លៀសគ្រួសារខ្ញុំទៅនៅភូមិជ្រោយអំពិល។ ពេលទៅដល់ទីនោះដំបូងអង្គការបានស្នើសុំឪ្ពានរបស់ជីតារបស់ខ្ញុំ ហើយគ្រួសារខ្ញុំស្នាក់នៅទីនោះបានពីរយប់ ខ្មែរក្រហមក៏បានជម្លៀសបន្តតាមកប៉ាល់ឲ្យទៅរស់នៅភូមិត្រពាំងស្នោ ឃុំសួង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាមវិញ។ ការរស់នៅទីនោះរបស់គ្រួសារខ្ញុំគឺបានជួយឧបត្ថម្ភពីអ្នកមូលដ្ឋានចាស់ដោយអ្នកទាំងនោះយកបាយឲ្យហូបទាំងពេលព្រឹកនិងពេលល្ងាច។ ប្រហែលបីខែក្រោយមក ខ្មែរក្រហមបានជម្លៀសបន្តឲ្យទៅរស់នៅភូមិស្វាយទាបខាងលិច ឃុំស្វាយទាប ស្រុកចម្ការលើ ខេត្តកំពង់ចាម។

ក្រោយពីទៅដល់ទីនោះបានប្រហែលមួយខែ ខ្ញុំមានជំងឺរាគមួល អង្គការក៏អនុញ្ញាតឲ្យទៅដេកពេទ្យក្នុងឃុំស្តី។ ពេលនោះឪពុករបស់ខ្ញុំបានសុំអង្គការទៅតាមមើលថែខ្ញុំតែត្រូវអង្គការប្រាប់ថា «មិនបាច់ទេ មានពេទ្យថែទាំហើយ»។ ខ្ញុំសម្រាកនៅពេទ្យស្តីតែម្នាក់ឯងបានប្រហែលមួយខែកន្លះជំងឺកាន់តែធ្ងន់ទៅៗ អង្គការបានបញ្ជូនឲ្យទៅដេកពេទ្យនៅវត្តជ្រោយថ្ម (ខេត្តកំពង់ចាម) វិញ។ សម្រាកនៅពេទ្យនោះបានប្រហែលបីខែ ជំងឺក៏ជាសះស្បើយ អង្គការក៏បានបញ្ជូនខ្ញុំឲ្យវិលត្រឡប់មកភូមិស្វាយទាបខាងលិចវិញ។ ពេលដែលខ្ញុំទៅដល់ទីនោះគឺនៅសល់តែគ្រួសារមីង ម៉ាច មួយគ្រួសារតែប៉ុណ្ណោះ ហើយគាត់ប្រាប់ខ្ញុំថា ជីតាជីដូន មីងមា និងឪពុកម្តាយ បងប្អូនៗរបស់ខ្ញុំត្រូវអង្គការឲ្យទៅ «នៅភូមិថ្មី» ហើយនិយាយថា ឪពុកម្តាយខ្ញុំផ្តាំថា កុំឲ្យពិបាកចិត្តចាំគាត់មកយកពេលក្រោយ។ ខ្ញុំក៏រស់នៅជាមួយគ្រួសារមីង ម៉ាច តាំងពីពេលនោះមក។

លី មុនីសភ្ជុំ កំពុងឈរពីមុខរូបភាពដែលយោធាខ្មែរក្រហមចូលទីក្រុងភ្នំពេញ

ថ្ងៃមួយអ៊ំស្រីអ្នកមូលដ្ឋានចាស់ម្នាក់ដែលជាអ្នកធ្លាប់រាប់អានម្តាយខ្ញុំពីមុនមកបានលួចខ្សឹបប្រាប់ខ្ញុំថា ពេលដែលអង្គការចាត់ឲ្យគ្រួសារខ្ញុំទៅនៅភូមិថ្មី ម្តាយរបស់ខ្ញុំបានយំសោកជោកខ្លួនពុំព្រមឡើងឡានទេ ដោយបានប្រាប់ថា លុះត្រាតែឃើញខ្ញុំមកដល់ទើបគាត់ព្រមទៅ ប៉ុន្តែដោយមានការអង្វរពីឪពុកខ្ញុំទើបគាត់យល់ព្រម។ អ៊ំស្រីនោះបន្តប្រាប់ខ្ញុំថា «អង្គការបានយកទៅសម្លាប់ទាំងអស់ហើយ ដូច្នេះក្មួយឯងធំឡើងត្រូវតែសងសឹកវិញ»។ ខ្ញុំនៅជាមួយគ្រួសារមីង ម៉ាច បានប្រហែលមួយខែក៏កើតជំងឺហើម អង្គការក៏បានបញ្ជូនខ្ញុំឲ្យទៅ

ដេកពេទ្យស្ពឹមខ្លួនទៀត ។ ពេលនោះអ៊ីស្រី ដន អ្នកមូលដ្ឋានដែលមកមើលថែកូនគាត់ដេកពេទ្យនៅទីនោះដែរ បានសុំខ្ញុំធ្វើជាកូនចិញ្ចឹម ហើយខ្ញុំក៏ពុំបានបដិសេធនូវសំណើរបស់គាត់ដែរ ។ ដេកពេទ្យស្ពឹបានប្រហែលបួនខែ ជំងឺក៏ជាសះស្បើយ អ៊ីស្រី ដន បានយកខ្ញុំទៅនៅភូមិថ្មីជាមួយគាត់ដែលស្ថិតនៅក្រោយភូមិសាយឣាបខាងលិចក្នុងឃុំតាក្រង ។ ថ្ងៃមួយពេលខ្ញុំមកពីឃ្វាលគោវិញ អ៊ីស្រី ដន បានជ្រាបខ្ញុំថា អង្គការបានសម្ចាប់ម្តាយមីងរបស់ខ្ញុំ ហើយចាប់ពីពេលនេះទៅ បើមាននរណាសួរពីខ្ញុំត្រូវជ្រាបគេថា ខ្ញុំត្រូវជាកូនបង្កើតរបស់គាត់ ហើយហៅគាត់ថាម៉ែៗរហូត ។ ពេលទៅហូបបបរនៅសហករណ៍ម្តងៗ ប្រធានរោងបាយចេះតែមើលមុខខ្ញុំគ្រប់ពេលហាក់ដូចជាមានការសង្ស័យអ៊ីម៉្លេង ។

រហូតមកដល់ចុងឆ្នាំ១៩៧៨ នៅល្ងាចថ្ងៃមួយប្រហែលម៉ោងជ្រាំល្ងាចពេលដែលខ្ញុំត្រឡប់ពីឃ្វាលគោ ម្តាយចិញ្ចឹមរបស់ខ្ញុំបានវេចបង្វិចឲ្យខ្ញុំ ហើយគាត់យំខ្សឹកខ្សួលជ្រាបខ្ញុំថា «អង្គការមិនឲ្យកូនឯងនៅជាមួយម៉ែទៀតទេ ដូច្នេះស្រេចនៅលើដួលបុណ្យកូនឯងទៅចុះ» ។ ពេលនោះអារម្មណ៍របស់ខ្ញុំឥតដឹងអ៊ីទេ គឺដឹងតែនឹកខ្ញុំពុកម្តាយបង្កើតបួនៗ ដីដួនដីតា មីងមាខ្ញុំតែប៉ុណ្ណោះ ។

ក្រោយថ្ងៃ៧ ខែមករាឆ្នាំ១៩៧៩ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិបានយកខ្ញុំមករស់នៅក្នុងមណ្ឌលក្រូងកំពង់ចាម ។ ខ្ញុំរស់នៅនិងបានរៀនសូត្ររហូតដល់អាយុ១៧ឆ្នាំ ដោយមានភាពឈឺចាប់នូវអ្វីដែលខ្ញុំបានទទួលរង ជាពិសេសការបាត់បង់នូវសមាជិកគ្រួសារទាំងក្មេងទាំងចាស់ទាំងប្រុសទាំងស្រីចំនួន២១នាក់ ដែលខ្មែរក្រហមបានសម្ចាប់ខ្ញុំក៏សម្រេចចិត្តចូលធ្វើឣាជីវកាល ។

ព្រោះតែរបបខ្មែរក្រហមបានធ្វើឲ្យរូបខ្ញុំក្លាយជាជនឣនាថាគ្មានទីជម្រកធ្លាក់ខ្លួនកំព្រាតាំងពីឣាយុ៩ឆ្នាំមក ហើយបច្ចុប្បន្ននេះ ខ្ញុំមានឣាយុ៤៥ឆ្នាំហើយ គ្មានផ្ទះសម្បែងរស់នៅ គ្មានប្រពន្ធកូនគឺរស់នៅតែម្នាក់ឯងដោយយកមន្ទីរពេទ្យរបស់រដ្ឋស្នាក់ឣាស្រ័យបណ្តោះឣាសន្នប៉ុណ្ណោះ ។ **ឈី មុនីសភ្ជិ**

ប្រកាសរកកូនស្រី

ឣ៊ុន សៃហ៊ុន

នាងខ្ញុំឈ្មោះ ឣ៊ុន សៃហ៊ុន សព្វថ្ងៃឣាយុ៧៣ឆ្នាំ រស់នៅឃុំព្រៃប្រសប់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល សូមប្រកាសរកកូនស្រីឈ្មោះ មាស ម៉ារឌី ដែលបានបែកគ្នាតាំងពីឆ្នាំ១៩៧៥ ។ នាងខ្ញុំមានស្វាមីឈ្មោះ មាស ហ៊ិន ទើបស្លាប់កាលពីពេលថ្មីៗនេះ ។ យើងមានកូនទាំងអស់ជប់នាក់ ។ កាលពីសម័យ លន់ នល់ នាងខ្ញុំមានផ្ទះនៅភ្នំពេញ ។ នៅចុងខែមីនា ឆ្នាំ១៩៧៥ បងស្រីថ្លៃរបស់ខ្ញុំបានមកលេងផ្ទះខ្ញុំ និងបានសុំកូនស្រីទីបីរបស់ខ្ញុំឈ្មោះ ម៉ារឌី ដែលពេលនោះមានឣាយុត្រឹម៧-៨ឆ្នាំ ទៅលេងនៅខេត្តកំពង់ចាមជាមួយគាត់រយៈពេលបួនប្រាំថ្ងៃ ។ ខណៈពេលនោះ យោធាខ្មែរក្រហមបានឣាយសម្រុកចូលមកដល់ទីក្រុងភ្នំពេញ និងបានជម្លៀសគ្រួសារខ្ញុំចេញទាំងអស់ ។ ចាប់តាំងពីពេលនោះមក គ្រួសារខ្ញុំក៏បានបែកពីកូនស្រីរហូត ។ ទើបមកដល់ប្រទេសទទួលបានសន្តិភាពក្រោយឆ្នាំ១៩៧៩ ខ្ញុំបានស្តាប់ព្តីការប្រកាសផ្សាយតាមវិទ្យុនៅភ្នំពេញថា មានក្រុមសិល្បៈកុមារកំព្រាពីរក្រុមដែលក្រុមមួយនៅស្រុកខ្មែរ និងក្រុមមួយទៀតបានទៅសម្តែងនៅក្រៅប្រទេស ហើយក្នុងចំណោមកុមារដែលបានចេញទៅសម្តែងនោះ ក៏មានឈ្មោះដូចកូនស្រីខ្ញុំដែរ ។ ពេលនោះដើម្បីឲ្យដឹងច្បាស់លាស់ ខ្ញុំបានព្យាយាមចាំស្តាប់ការផ្សាយនេះម្តងទៀត ប៉ុន្តែដំណឹងនេះពុំបានចាក់ផ្សាយឡើងវិញទេ ។ ដូច្នេះ ប្រសិនបើបងប្អូនណាស្គាល់ ឬឮឈ្មោះ មាស ម៉ារឌី ថារស់នៅទីណា សូមទំនាក់ទំនងមកនាងខ្ញុំ ឣ៊ុន សៃហ៊ុន តាមឣាសយដ្ឋានដូចខាងលើ ឬតាមរយៈលេខទូរស័ព្ទ ០៨៩ ៨៦៣ ២៣៨ ឬតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ឣាសយដ្ឋាន : ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ឬតាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬ ០ ១៦ ៨៧៦ ៦៩២ ។ ***សូមឣរគុណ!***

រឿងបដិវត្តន៍របបកម្ពុជាប្រជាធិបតេយ្យ : ពលីកម្មរបស់យុទ្ធមិត្តយើង

ដកស្រង់ចេញពីស្បៃតកៅ យុវជន និងយុវនារីបដិវត្តន៍ លេខ២ កុម្ភៈ ១៩៧៦



កងចល័តនារីកំពុងរៀបចំសាច្បាធ នៅខែសីហា ឆ្នាំ១៩៧៨

មហាជ័យជម្នះ ១៧ មេសា ឆ្នាំ១៩៧៥ នេះជាមហាជ័យជម្នះដ៏ធំធេងសម្បើមអស្ចារ្យ មានអត្ថន័យជាប្រវត្តិសាស្ត្រ និងល្បីខ្ទរខ្ទារ ទាំងនៅក្នុងប្រទេស ទាំងនៅលើឆាកអន្តរជាតិ។ មហាជ័យជម្នះជាប្រវត្តិសាស្ត្រនេះ ពិតជាពុំមែនបានមកដោយចៃដន្យ ឬដោយចក្រពត្តិអាមេរិក និងបរិវារ វាមេត្តា ករុណាដាក់ទានឲ្យនោះឡើយ។ តែមហាជ័យជម្នះដ៏ល្បីល្បាញអស្ចារ្យនេះ ពិតជាបានមកដោយសារមានបក្សកុម្មុយនីស្តកម្ពុជាដឹកនាំតាមមាគ៌ាត្រឹមត្រូវ និងភ្លឺស្វាងមហាអស្ចារ្យ ដោយសារការខិបតួម្ភ គាំទ្រ និងពលីកម្មប្រើនឥតគណនារបស់ប្រជាជន កម្មករ កសិករ ក្រីក្រយើង និងដោយសារការប្រយុទ្ធយ៉ាងតឹងតែង សុិតសុាញ លំបាកវេទនា តែប្រកបដោយវីរភាពបដិវត្តន៍ខ្ពង់ខ្ពស់បំផុត និងពលីកម្មដ៏ធំធេងអស្ចារ្យរបស់យុទ្ធមិត្តយើងក្នុងរយៈ២៨ឆ្នាំកន្លងទៅនេះ។ ក្នុងរយៈកាល២៨ឆ្នាំនៃការតស៊ូបដិវត្តន៍ដ៏សន្ធោសន្ធៅកន្លងទៅនេះ ប្រជាជនយើង ពិសេសកម្មករ កសិករក្រីក្រ យុទ្ធមិត្តយើង និងបង។ យើងជំនាន់មុន បានបង្ហូរឈាមស្រស់ ចោលសាច់ចោលឆ្អឹងពាសពេញដែនដីកម្ពុជា មាតុភូមិជាទីស្នេហាច្រើនរាប់មិនអស់បានទ្រាំទ្រការលំបាកវេទនាសព្វបែបយ៉ាង អត់ឃ្លានឈឺថ្កាត់ ហាលភ្លៀងហាលខ្យល់ ។ល។

តទៅនេះ យើងខ្ញុំសូមលើករឿងរ៉ាវតូចមួយនៃចលនាតស៊ូបដិវត្តន៍ដ៏តឹងតែងលំបាកវេទនាក្នុងបណ្តារឿងរ៉ាវនៃចលនាតស៊ូបដិវត្តន៍ច្រើនរាប់មិនអស់ផ្សេងទៀត។

ភូមិតាឡាត់ ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៨ ចម្ងាយ៣០០ម៉ែត្រពីបន្ទាយ «កាប់កង់» របស់ខ្មាំង។ ប្រជាជនភូមិតាឡាត់ មានប្រពៃណីតស៊ូបដិវត្តន៍ជាប់រហូត តាំងពីជំនាន់វាយអាណានិគមនិយមបារាំងមកម៉្លេះ។ ភូមិមុំនេះ មានឈ្មោះដូចតទៅៈ ភូមិតាឡាត់ ស្រុកចេក ត្រាំសែង បង្គ័ង រកា តាយ៉ូវ ។ល។ កាលពីក្នុងសម័យតស៊ូនយោបាយសម្ងាត់ ប្រជាជន កសិករក្រីក្រយើងមុំនេះធ្លាប់បានជួយលាក់បំពួនកម្មាភិបាលសម្ងាត់យើងជួយចិញ្ចឹមបាយទឹក និងជួយខិបត្តម្ភស្រូវអង្ករដល់ប់រហូត ទោះបីខ្មាំងហាមប្រាម បង្ក្រាបរាតត្បាត កាប់សម្លាប់ រះពោះកាត់ក្បាលបូចឆព្យរដើងឡើងលើ ខ្ទេះគ្រាប់ក្អែក កាត់ដៃ កាត់ដើង និងផ្ទើទារុណកម្មយ៉ាងព្រៃផ្សៃរហ៊ាសុីសយ៉ាងណាក៏ដោយ។

នៅក្នុងសម័យសង្គ្រាមបដិវត្តន៍ជាង៥ឆ្នាំកន្លងទៅនេះ ស្រុកភូមិមុំនេះបានត្រូវឆេះបាក់បែកខ្ទេចខ្ទី ហិនហោចអស់គ្មានសល់ ដោយសារគ្រាប់បែក និងគ្រាប់ផ្លោងរបស់ចក្រពត្តិអាមេរិក និងពួកក្បត់លន់ នល់។

មិត្ត រ៉ែត ជាកូនកសិករក្រ នៅភូមិតាឡាត់នេះ។ ក្រោយមក ដោយត្រូវខ្មាំងបង្ក្រាបរាតត្បាត និងរករឿងរកហេតុធ្វើទុក្ខ

បុកម្នេញខ្លាំងពេក គ្រួសារមិត្ត រ៉ែត និងប្រជាជនយើងឯទៀតទាំងអស់នៅក្នុងភូមិតាឡាត់នេះ បានចាកចេញចោលភូមិកំណើត មកនៅខាងលិចវត្តព្រៃរមៀតវិញ។ នៅក្នុងគ្រួសារនេះ មានកូនប្រុសតែមួយគត់គឺមិត្ត រ៉ែត នេះឯង។

ដោយទ្រាំទ្រនឹងការដេះជាន់ ឆក់ប្លន់ និងការបង្ក្រាបរាតត្បាតយ៉ាងសាហាវព្រៃផ្សៃរបស់ខ្លាំងមិនបាន នៅថ្ងៃ២៥ ខែកុម្ភៈ ឆ្នាំ១៩៦៨ ប្រជាជនកសិករយើងនៅមុំនេះបានរួបរួមសាមគ្គីគ្នា ក្រោកឡើងធ្វើកុប្បកម្ម វាយលុកចូលប៉ុស្តិ៍ប័ររបស់ខ្លាំងនៅមុំនោះ ដណ្តើមអាវុធពីដៃខ្លាំងមកបំពាក់ឲ្យខ្លួន ហើយនាំគ្នារត់ចូលព្រៃបន្តការតស៊ូបដិវត្តន៍វាយកម្ទេចខ្លាំងទៀត។

ក្រោយពេលកុប្បកម្មភ្លាម អឹ ស៊ីម បានប្រគល់មិត្ត រ៉ែត ដែលជាកូនប្រុសបណ្តូលចិត្តតែមួយគត់នៅក្នុងគ្រួសារជូនបក្ស ដោយទឹកចិត្តសោមនស្សរីករាយជ្រះថ្លាបំផុត។ ពេលយកមិត្ត រ៉ែត ទៅប្រគល់ជូនអង្គការ អឹស៊ីម ដែលជាកសិករក្រម្នាក់ នៅឃុំតាឡាត់ បានមានប្រសាសន៍ថា «ខ្ញុំចាស់ហើយ រត់លូននឹងគេមិនរួចទេ សូមប្រគល់ជូនបក្សនូវកូនប្រុសសម្លាញ់មួយនេះដើម្បីបន្តវេនបដិវត្តន៍»។ សូមបញ្ជាក់ថា អឹស៊ីម ធ្លាប់ធ្វើជាយុទ្ធជនបដិវត្តន៍យ៉ាងអង់អាចក្លៀវក្លា កាលពីជំនាន់តស៊ូអាវុធវាយអាណានិគមនិយមបារាំង។ ចាប់តាំងពីខែកុម្ភៈ ឆ្នាំ១៩៦៨មក មិត្ត រ៉ែត ក៏បានចូលជាយុទ្ធជនឈ្លប ទៅបម្រើការងារបដិវត្តន៍នៅឯមូលដ្ឋានក្នុងព្រៃជារៀងរហូតមក។

ខែវិច្ឆិកា ឆ្នាំ១៩៦៩ ក្នុងពេលដែលខ្លាំងកំពុងបើករាតត្បាត ដោយទ្រង់ទ្រាយធំទៅលើប្រជាជន និងអ្នកតស៊ូបដិវត្តន៍នៅក្នុងភូមិភាគនិរតី បក្សបានបើកវគ្គអប់រំមួយនៅជំរុំភ្នំឱរ៉ាល់ ដើម្បីអប់រំ កសាងពង្រឹងគោលជំហរនយោបាយ សតិអារម្មណ៍ ចាត់តាំងឲ្យកម្មាភិបាល យុទ្ធជន យុទ្ធនារីបដិវត្តន៍ យើងទាំងអស់និងដើម្បីដាក់វិធានការត្រៀមទប់ទល់ និងវាយសំរុកបកទៅលើខ្លាំងវិញ ការពារមូលដ្ឋានបង្កែកបដិវត្តន៍ ការពារកម្លាំងបដិវត្តន៍ពង្រឹងពង្រីកកម្លាំងបដិវត្តន៍ឲ្យបានដាច់ខាត។

ពេលនោះ ខ្ញុំត្រូវបានអង្គការហៅឲ្យមកភ្នំឱរ៉ាល់នេះដែរ។ ខ្ញុំនឹកអរព្រួចថា ប្រហែលបានចូលរៀនសូត្រក្នុងវគ្គនេះដែរហើយ។ តែពេលខ្ញុំទៅដល់អង្គការបានហុចកូនសំបុត្រតូចមួយឲ្យខ្ញុំហើយទាញដៃខ្ញុំឲ្យអង្គុយចុះ។ អង្គការបានយកកូនឈើតូចមួយគួសរាសនៅលើដី។ ព្រមជាមួយនោះ អង្គការបាននិយាយមកកាន់ខ្ញុំថា «សមមិត្តត្រូវទៅរកសមមិត្ត សេន នៅឯភ្នំច្រមុះស្នា។ បើរកមិនឃើញ សមមិត្តត្រូវចាប់រកគាត់ពីបឹងឃ្លោងទៅដល់ភ្នំដាច់ដោ។ បើមិនឃើញទៀត ទៅរកគាត់នៅភ្នំកំពូលបី» អង្គការនិយាយបន្តទៀតថា «សមមិត្តមិនជាប់រៀនទេ ព្រោះបក្សត្រូវការសមមិត្តទៅបំពេញភារកិច្ចជាបន្ទាន់ និងចាំជាប់។ ពោលគឺសមមិត្ត

និងមិត្តសេន ត្រូវទៅកាប់ចម្ការនៅលើកំពូលភ្នំជាំស្ងា រៀបចំមូលដ្ឋានបដិវត្តន៍ថ្មីមួយទៀតនៅទីនោះសម្រាប់ធ្វើជាដំណាក់និវសារ គក្លាប់ពីកោះកុង មកភ្នំឱរ៉ាល់ដង (មូលដ្ឋានបដិវត្តន៍នៅកោះកុង ត្រូវដាច់ខ្សែទាក់ទងជាមួយភូមិភាគនិរតីជាយូរខែហើយ ដោយខ្លាំងរាតត្បាតខ្លាំងពេក)។ សមមិត្តយកក្រមមិត្ត រ៉ែត ទៅជាមួយចុះ ព្រមទាំងយកពេទ្យម្នាក់ទៅជាមួយដង»។ អង្គការនិយាយចប់ ក៏ហុចថ្នាំគ្រុនចាញ់ ១៥គ្រាប់ និងថ្នាំចាក់ ៥ ទៅ៦អំពូលមកខ្ញុំ ហើយនិយាយថា «នេះជាថ្នាំពេទ្យសម្រាប់

កសាងមូលដ្ឋានបដិវត្តន៍ថ្មី! បើសមមិត្តត្រូវការ ឬខ្វះខាតថ្នាំសង្កូវ ព្យាបាលបងប្អូន សមមិត្តត្រូវណែនាំមិត្តពេទ្យឲ្យដោះស្រាយជាមួយព្រៃភ្នំ» ។ សូមជម្រាបថា ថ្នាំពេទ្យនៅពេលនោះក្រណាស់ ។ ថ្នាំគ្រុនចាញ់មួយគ្រាប់ៗ មានតម្លៃជាងមាសទៅទៀត ។ ការដែលអង្គការប្រគល់ថ្នាំពេទ្យប៉ុណ្ណឹងមកឲ្យខ្ញុំ សម្រាប់អង្គភាពទាំងមូលដែលត្រូវទៅកសាងមូលដ្ឋានបដិវត្តន៍ថ្មីនេះ គឺជាគោលនយោបាយខ្ពស់បំផុតរបស់បក្សគឺបក្សយកចិត្តទុកដាក់ធំធង់អង្គភាពយើងខ្ញុំ

ការសម្តែងសិល្បៈយុវជនយុវនារីបដិវត្ត ខែសីហា ឆ្នាំ១៩៧៨

ជាទីបំផុតហើយ ។ យើងខ្ញុំទទួលយកថ្នាំពេទ្យនេះអំពីដៃអង្គការដោយទឹកចិត្តរំភើបញាប់ញ័រឥតខ្ចប់មា និងដោយស្ងាក់ស្ទើរក្នុងចិត្ត ពុំចង់ទទួលយកឡើយ ព្រោះថ្នាំពេទ្យក្រណាស់ អង្គការក៏មានតិចតួចស្ទើរណាស់ ។ អង្គការបានបេះពីមាត់ពីកដល់ឲ្យយើងខ្ញុំ ។ យើងខ្ញុំមិនចង់ទទួលយក ព្រោះខ្លាចអង្គការឈឺថ្កាត់ទៅគ្មានថ្នាំអ៊ីព្យាបាល ។ ឃើញអាកប្បកិរិយាខ្ញុំស្ងាក់ស្ទើរយ៉ាងនេះ អង្គការមានប្រសាសន៍មកកាន់យើងខ្ញុំទាំងញញឹមពព្រាយថា «សមមិត្តយកថ្នាំនេះទៅចុះ ព្រោះនៅខាងឯណោះ ស្ងាយស្រុកភូមិប្រជាជនណាស់ ។ ឯយើងខ្ញុំនៅខាងនេះ ចាំដោះស្រាយរកទៀត» ។ យើងខ្ញុំទទួលយកថ្នាំនេះដាក់ក្នុងហោប៉ៅអាវ រួចឈានចេញដើរបាន៨-១០ជំហាន ។ អង្គការក៏បក់ដៃហៅយើងខ្ញុំត្រឡប់ទៅវិញហើយសួរយើងខ្ញុំថាសមមិត្តមានអង្ករទេ? យើងខ្ញុំឆ្លើយជម្រាបអង្គការវិញថា ស្រូវយើងធ្វើនៅភូមិបុសគាជកឡើងពណ៌ស្វាបសេកហើយ ។ យើងខ្ញុំមិនហ៊ានឆ្លើយជម្រាបអង្គការថា អត់អង្ករទេ ព្រោះយើងខ្ញុំមិនចង់ឲ្យអង្គការខ្វល់ខ្វាយរឿងហ្នឹងពេក ព្រោះពេលនោះយើងគ្មានអង្ករទេ យើងហូបតែកួចប៉ុន្មានខែមកហើយ ។ ឯអង្ករមានបន្តិចបន្តួច គឺទុកសម្រាប់តែមិត្តយើងដែលឈឺខ្លាំង ។

អង្គការយល់ដល់ដម្រៅទឹកចិត្តយើងខ្ញុំ ហើយនិយាយដោយទឹកមុខញញឹមថា ស្បៀងរបស់យើងគឺត្រូវយកកួចធ្វើជាមូលដ្ឋានសំខាន់ ។ យើងត្រូវដាច់ខាត ការពារកម្លាំងបដិវត្តន៍ឲ្យបាន ។ ប៉ុន្មានថ្ងៃនេះ សមមិត្តយើងពលីកម្មអស់ជាច្រើនហើយព្រោះតែរឿងចូលយកអង្ករក្នុងភូមិ ហើយធ្លាក់ក្នុងរន្ធង់ត្រៀមរបស់ខ្លាំង ។ សព្វថ្ងៃ ខ្លាំងវាធ្វើរបងជាន់គៀបសុទ្ធតែបន្លារឿងបន្លាអន្ត្រូងព័ន្ធជុំវិញភូមិប្រជាជនទាំងអស់ដែលធ្លាប់ខបត្តមអង្ករយើង ហើយវាហាមប្រាមមិនឲ្យប្រជាជនចេញពីភូមិដាច់ខាត ។ បើអ្នកណាហ៊ានប្រព្រឹត្តល្មើសនឹងបទបញ្ជាវានេះ វានឹងចាប់សម្លាប់អស់មួយពូជ ។ ពេលល្ងាចឡើង វាអួសសម្រាស់ លុបដានដើងទាំងអស់ ។ បើព្រឹកស្អែកឡើង វាឃើញមានដានដើង ហើយបើវាត្រៀមចាប់សម្លាប់យើងមិនបាន វានឹងចាប់ប្រជាជនក្នុងភូមិសម្លាប់ទាំងអស់ ។ ខ្លាំងវាយោរឃោរណាស់ ។ វាធ្វើយ៉ាងនេះប៉ុនប៉ង បង្ខិតបាយ បង្ខិតស្រូវអង្ករ ឲ្យយើងដាច់ពោះស្លាប់ទាំងអស់ ។ តែយើងដាច់ខាតមិនស្លាប់ ។ យើងត្រូវតែប្រយុទ្ធដោះស្រាយស្បៀង ចិញ្ចឹមកងទ័ពយើងឲ្យបានដង ហើយការពារអាយុជីវិតប្រជាជនយើងឲ្យបានទៀត ។ ដូច្នេះអង្គភាពសមមិត្តត្រូវប្រយុទ្ធបង្កបង្កើនដលឲ្យបានដាច់ខាត ដើម្បីមានស្បៀងខបត្តមកងទ័ពយើងវាយកម្ទេចខ្លាំងបានជាបន្តបន្ទាប់ ។

ពុពាក្យសម្តីដ៏មោះមុតនេះរបស់អង្គការ យើងខ្ញុំទាំងអស់គ្នាមានការរំជួលចិត្តដង និងមានកំហឹងពុះពោរចំពោះខ្លាំងសត្រូវដង ។ យើងខ្ញុំទាំងអស់គ្នាបញ្ជាក្នុងចិត្តថា នឹងសម្រេចការកិច្ចនេះជូនបក្ស

ឲ្យបានដាច់ខាត ទោះបីជួបឧបសគ្គ ឬត្រូវឆ្លងកាត់ការលំបាកវេទនាយ៉ាងណាក៏ដោយ ។ ពេលយើងខ្ញុំចាប់រលាក់ដៃជម្រាបលាអង្គការ ដោយមនោសញ្ចេតនាបដិវត្តន៍ជ្រាលជ្រៅបំផុត អង្គការមានប្រសាសន៍មកកាន់យើងខ្ញុំថា ដើម្បីការពារកម្លាំងបដិវត្តន៍ ការពារសុខភាពមិត្តយើងឲ្យសម្រេចការកិច្ចបក្សបានជោគជ័យ សមមិត្តមិនអាចទៅដៃទទេយ៉ាងនេះបានទេ សមមិត្តត្រូវរកអង្ករខ្លះយកទៅដង ។ សមមិត្តត្រូវទៅជួបក្រុម តាខ្ចូ ដែលជាក្រុមការពារនៅខាងមុខ ព្រោះឥឡូវនេះ គាត់កំពុងនាំមិត្តយើងច្រូតស្រូវមួរនៅភូមិស្រែកិន និងភូមិតាអុយ (ភូមិស្រែកិន និងភូមិតាអុយនេះ គ្មានប្រជាជនទៅទេ ព្រោះត្រូវខ្មាំងកៀរយកទៅដាក់នៅភូមិយុទ្ធសាស្ត្រ ឯត្រពាំងដោរ អនុខេត្តថ្មគែរ អស់ហើយ) ។

ខ្ញុំ និងក្រុមមិត្ត រ៉ែត ក៏បាននាំគ្នាចេញដំណើរទៅដោយអនុវត្តតាមការណែនាំរបស់អង្គការគ្រប់ម៉ាត់ទាំងអស់ ។

ភ្នំឱ្រាល់ ក្នុងខែវិច្ឆិកា មានអាកាសធាតុត្រជាក់ស្រឹត មុតដល់ក្នុងឆ្អឹង ។ ទឹកសន្សើមធ្លាក់ជោគជាំ ព្រៃព្រឹក្សា បីដូចជាទឹកភ្លៀងរលឹម ។ មិត្តយើងមានខោអាវតែមួយបន្ទាស់ម្នាក់ប៉ុណ្ណោះ ។ មិត្តខ្លះអត់ទាំងក្រមារុំទៀតផង ។ ក្នុងគ្នាយើងដប់នាក់ មានក្រណាត់ភ្លៀងតែបីទេ ដូច្នេះមិនចាច់និយាយឡើយដល់មុង ភួយ និងអង្រឹង ។ យើងខ្ញុំទាំងអស់គ្នា ពុំដែលស្គាល់ស្រមោលឡើយ ។ យើងខ្ញុំនាំគ្នាដើរទាំងរងារញាក់ញ័រ រណ្តំថ្ពាម ឆ្លងកាត់ព្រៃភ្នំ ជ្រោះជ្រលងស្ងាត់ជ្រងំ ដុតកំដៅដោយភ្លើងកំហឹងវណ្ណៈ ឆ្ពោះតម្រង់ទៅរកទិសដៅបដិវត្តន៍ជានិច្ច ។ ដើរមួយព្រឹកធំ យើងខ្ញុំក៏បានទៅជួបនឹងក្រុម តាខ្ចូ ដែលកំពុងច្រូតស្រូវមួរនៅភូមិតាអុយ ។ យើងខ្ញុំពិភាក្សាជាមួយតា សុំស្រូវគាត់យកទៅបុកអង្ករបានពីរថែ ។ ក្រៅពីនេះ មិត្តយើងគ្រប់គ្នាសុទ្ធតែមានក្លួចស្លូតមួយថែៗម្នាក់ហើយ ។ យើងក៏លាក្រុមតាខ្ចូ ចាកចេញពីភ្នំឱ្រាល់ ធ្វើដំណើរកាត់ព្រៃចូលវាល ឆ្ពោះទៅរកសមមិត្តសនទៀត ។

ព្រះអាទិត្យអស្តង្គតទៅ នៅសល់តែពន្លឺក្រហមច្រាលនៅឯដើងមេឃទិសខាងលិច ។ ព្រះច័ន្ទក៏ចាប់ផ្តើមរះឡើងជាបន្តបន្ទាប់ចោលពន្លឺរស្មីភ្លឺព្រាលៗ តាមចន្លោះមែកឈើ ស្លឹកឈើដ៏ស៊ុបទ្រុបនៃព្រៃដើងភ្នំឱ្រាល់ ។ ខ្យល់រដូវរំហើយ ខែវិច្ឆិកា ត្រជាក់ស្រិបមុតដល់ឆ្អឹងខ្នង បក់ត្រសៀកៗចូលតាមប្រឡោះដើមឈើព្រៃ ។ ទឹកសន្សើមក៏ចាប់ផ្តើមធ្លាក់ប្រសំៗលើស្លឹកឈើព្រៃដងទាំងឡាយ ។ យើងខ្ញុំនាំគ្នាធ្វើដំណើរដោយស្ងាត់ស្ងៀមនៅក្នុងព្រៃងងឹតព្រៀងៗនេះ និងដោយស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ជានិច្ច ។ យើងប្រុងប្រយ័ត្នម្យ៉ាង រក្សាការសម្ងាត់កុំឲ្យបែកដួរ កុំឲ្យខ្មាំងតាមរាតត្បាតបំផ្លិចបំផ្លាញយើងបាន តែប្រុងប្រយ័ត្នម្យ៉ាងទៀតគឺកុំឲ្យវង្វេងទិសដែរ ព្រោះយប់កាន់តែងងឹតចាក់ភ្នែកមិនយល់ហើយ ។ ទៅដល់កន្លែងព្រៃជ្រៅមួយ ដែលមានការធានាសន្តិសុខគ្រប់គ្រាន់ យើងនាំគ្នាឈប់សម្រាកនៅទីនោះ ។ យើងគ្មានអង្រឹង គ្មានមុង គ្មានភួយអ្វីទាំងអស់ ។ យើងនាំគ្នាដើរជ្រើសរកកន្លែងដីទំលុះខ្ពស់បន្តិច ជោសសំអាតទីកន្លែងឲ្យស្អាតជាតហើយ រួចទើបនាំគ្នាកាប់ស្លឹកឈើ មែកឈើ យកមកក្រាលលើដី ធ្វើជាត្រែ ធ្វើជាកន្ទេល ហើយសម្រាកផ្ទាល់នៅលើដីនេះតែម្តង ។ មិត្តណាខ្សោយ ទើបត្រូវបានក្រណាត់កៅស៊ូភ្លៀងគ្របដណ្តប់ពីលើ ។ តែចំពោះមិត្តយើងទូទៅ គឺនាំគ្នាដេកឱបដៃក្រវៀនៗទាំងអស់គ្នា ។ ដើម្បីការពារនឹងសត្វព្រៃកាចសាហាវ មានខ្លា ដំរី ជាដើម យើងរើសមែកឈើធាប់ៗ យកមកដុតភ្លើងភ្នក់មួយនៅចំកណ្តាល រួចហើយយើងផ្ងារវែនគ្នាអង្គុយយាមភ្លើង និងការពារសន្តិសុខមួយម៉ោងម្នាក់រហូតដល់ភ្លឺ ។

នៅពេលព្រលឹមស្រាងៗព្រឹកស្អែកឡើង យើងនាំគ្នាក្រោកពីដំណេក ប្រញាប់ប្រញាល់ពន្លត់ភ្នក់ភ្លើង កើបស្លឹកឈើ និងមែកឈើស្រស់ ដែលយើងកាប់ក្រាលដេកពីយប់យកទៅពង្រាយចោលពាសពេញព្រៃរួចហើយ យើងកើបស្លឹកឈើធាប់ៗមកដាក់ពង្រាយលុបដានរបស់យើងវិញទាំងអស់ ។ យើងនាំគ្នាធ្វើដំណើរស្រូតកាត់យ៉ាងលឿនឆ្ពោះទៅមុខទៀត ទៅដល់ដួរលំតូចមួយដែលឆ្ពោះទៅច្រកវាំជ្រុំ មិត្ត រ៉ែត បានជ្រាបយើងទាំងអស់គ្នាឲ្យដើរថយក្រោយ ដើម្បីបង្វែងដានខ្មាំង ។ រួចមិត្ត រ៉ែត បាននិយាយតិចៗ ខ្សឹបជ្រាបខ្ញុំថា «ប៉ុន្មានថ្ងៃមុននេះ ខ្មាំងទើបបានព័ទ្ធបាញ់សម្លាប់សមមិត្តយើង មានសមមិត្ត កែវ ដេង និងសមមិត្ត ដួ ជាដើម ដែលចូលទៅជាក់ទងប្រជាជននៅភូមិឆ្ងិននេះ ។ ដូច្នេះយើងត្រូវតែប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ថែមទៀត ហើយជម្រុលដំណើរយើងឲ្យលឿន ឆ្លងកាត់តំបន់ក្រោះថ្នាក់នេះឲ្យបានផុតឆាប់កាលណា លួកាលណោះ» ។

យើងនាំគ្នាដើរអស់រយៈពីរយប់ពីរថ្ងៃ ទើបទៅដល់ចឹងឃ្លោង តែយើងគ្មានជួបនឹងមិត្តណាម្នាក់ឡើយ យើងឃើញតែគំនរសំបកគ្លួច ឃើញតែអន្ទង់ត្រាំគ្លួច និងឃើញតែស្នាមជ្រុះជំរំចាស់ដែលមិត្តយើងរុះរើចោល និងលុបបំបាត់ដានអស់ទៅហើយ។ សមមិត្ត រ៉ែត ដើរពិនិត្យគ្រប់ទីកន្លែង រួចមកពិនិត្យមើលសំបកគ្លួចទៀត។ ក្រោយការពិគ្រោះពិភាក្សាជាមួយសមមិត្តយើងទាំងអស់គ្នាហើយ មិត្ត រ៉ែត មានមតិថា៖«កន្លែងនេះជ្រាកដជាកន្លែងរបស់បង សន ហើយ ហើយជ្រាកដជាពុំមែនជំរំចាស់របស់ខ្មាំងទេ។ បើតាមការពិនិត្យសំបកគ្លួច បងសនអាចចេញពីទីនេះប្រហែលបួនដប់ថ្ងៃមុននេះប៉ុណ្ណោះ។ ប្រហែលជាគាត់ចេញទៅរកគ្លួចនៅកន្លែងផ្សេងទៀតហើយ។ យើងទាំងអស់គ្នាក៏យល់ស្របតាមមតិរបស់ មិត្ត រ៉ែត ដែរ។ យើងក៏នាំគ្នាបន្តដំណើរទៅមុខទៀត សំដៅឆ្ពោះទៅភ្នំច្រមុះស្នា។ យើងនាំគ្នាដើរតាមផ្លូវទន្លាក់ៗ ដែលមានសំបកគ្លួចក្រៀម នៅរាត់រាយដោយដុបដោយជុំតាមបណ្តោយផ្លូវនោះរហូត។ ប្រហែលរសៀលម៉ោងបីនៅថ្ងៃដដែលនោះ យើងបានដើរទៅជួបនឹងប្រជាជនមួយក្រុមចំនួន១៥គ្រួសារ គឺជាប្រជាជនក្រោំងឈឹម ព្រៃអាពូក និងភូមិពាមល្មា ក្នុងឃុំចំបក់ អនុខេត្តគីរីរម្យ ដែលត្រូវខ្មាំងរាតត្បាតកាប់សម្លាប់យោរយៅព្រៃផ្សៃខ្លាំងពេក ទ្រាំទ្រពុំបាននាំគ្នារត់ចោលភូមិករ ដូរសម្បែង មកតាមបដិវត្តន៍ យើងសុខចិត្តមករស់នៅក្នុងព្រៃហូបក្លួច ដំឡូងព្រៃ និងស្លឹកឈើវិញ។ ពេលឃើញក្រុមយើងដើរទៅដល់ បងប្អូនប្រជាជនទាំងស្រី ប្រុស ចាស់ ក្មេង នាំគ្នារត់មកចោមរោម ឱបរឹតយើងខ្ញុំដោយក្តីនឹករឭកនិងដោយមនោសញ្ចេតនាវណ្ណៈជ្រាលជ្រៅបំផុត។ បងប្អូនរស់នៅខ្វះខាត អត់ឃ្លានណាស់ គ្មានស្រូវអង្គរ គ្មានអំបិល ប្រហុកអ៊ីមកជាប់ជាមួយខ្លួនបន្តិចទេ ព្រោះត្រូវខ្មាំងដុតបំផ្លាញចោលអស់នៅឯភូមិ។ តែទោះបីជាបងប្អូនខ្វះខាត អត់ឃ្លានយ៉ាងនេះហើយក្តី ក៏បងប្អូនគ្មានតួញតែស្រូវឬគ្មានថ្លូរជ្រាប់យើងមួយអឺនឡើយ។ បងប្អូននៅតែសុទិដ្ឋិនិយមបដិវត្តន៍ នៅតែប្រយុទ្ធជាមួយធម្មជាតិ ប្រយុទ្ធជាមួយខ្មាំងយ៉ាងអង់អាចក្លាហានជាប់ជានិច្ច ហើយឈរដាច់ខាតនៅខាងបដិវត្តន៍ ទោះបីខ្មាំងធ្វើការយោសនាបោកប្រាសលួងលោមអូសទាញតាមសម្ភារផ្សេងៗឲ្យបងប្អូនវិលត្រឡប់ទៅភូមិវិញយ៉ាងណាក៏ដោយ។ បងប្អូនឃាត់យើងឲ្យនៅហូបបាយជាមួយបងប្អូនសិន រួចហើយសឹមធ្វើដំណើរទៅមុខទៀត។ ម្ហូបអាហារដែលបងប្អូនរៀបចំជប់លៀងពួកយើងខ្ញុំនេះ គ្មានអ្វីក្រៅពីបបរក្លួចសាប លាយនឹងស្លឹកឈើព្រៃនោះឡើយ។ យើងខ្ញុំសាកសួរបងប្អូនទៅទើបដឹងថាបងប្អូនហូបសាបឥតអំបិលរយៈពេលបួនប្រាំខែមកហើយ។ យើងខ្ញុំរំជួលចិត្តជាខ្លាំង។ យើងខ្ញុំនាំគ្នាប្រមូលរបបអំបិលរបស់ខ្លួនដែលមានបន្តិចបន្តួចរំលែកចែកជូនប្រជាជនស៊ើរទាំងអស់ហើយទុកតែបន្តិចបន្តួចសម្រាប់មិត្តយើងប៉ុណ្ណោះ។ យើងគិតថាយើងនៅក្មេង យើងហូបសាបក៏បាន។ ចាំទៅដល់ទីកន្លែងសឹមនាំគ្នាដុតបុសរ៊ីធ្វើទឹកក្បុងហូប និងដើរកដីប្រាបខ្លះដែលមានជាតិប្រឡមៗយកមករួមដូរំ ទំរាំយើងទាក់ទងទៅខាងកោះកុងបាននោះយើងនឹងបានអំបិលហូបហើយ។

នៅពេលឃើញយើងខ្ញុំប្រមែប្រមូលអំបិលយកទៅប្រគល់ជូនបងប្អូនយើងមានការរំភើប និងរំជួលចិត្តរហូតដល់ស្រក់ទឹកភ្នែក។ បងប្អូនប្រកែក ពុំព្រមទទួលយកអំបិលនេះដាច់ខាត។ បងប្អូននិយាយមកកាន់យើងខ្ញុំថា «កូនៗទុកអំបិលបន្តិចបន្តួចនេះហូបខ្លួនឯងចុះ កុំឲ្យជាក់កម្លាំង ព្រោះកូនៗត្រូវធ្វើដំណើរឆ្ងាយដង ហើយត្រូវប្រយុទ្ធជាមួយខ្មាំងដង។ ចំណែកឯពុកម៉ែនៅមួយកន្លែងចាំដោះស្រាយទៀត។ ពុកម៉ែបានមករស់នៅក្នុងព្រៃជាមួយបដិវត្តន៍ ទោះបីហូបក្លួចសាប ក៏ពុកម៉ែសប្បាយរីករាយក្នុងចិត្តជាជាងរស់នៅជាមួយខ្មាំង ហូបត្រីសាច់ ក្រោមការដិះជាន់មើលងាយមើលថោករបស់ខ្មាំងដែរ»។

តែយើងខ្ញុំក៏ព្រមយកអំបិលនេះមកដាក់ក្នុងស្បោងវិញដែរ យើងខ្ញុំជម្រាបទៅពុកម៉ែវិញថា «សូមពុកម៉ែទទួលយកអំបិលបន្តិចបន្តួចនេះទុកពិសារចុះ ក្នុងដំណើរតមុខទៀត យើងខ្ញុំអាចដោះស្រាយបានមិនអីទេ»។

ថ្ងៃរសៀលកាន់តែជ្រៅបមាត់ព្រៃទៅហើយ។ យើងខ្ញុំនាំគ្នាជម្រាបលាពុកម៉ែ និងបងប្អូនប្រជាជនទាំងអស់ដោយមនោសញ្ចេតនានឹករឭក អាឡោះអាល័យ ហាក់បីដូចជាយើងខ្ញុំឃ្លាតចាកអំពីម៉ែឪគ្រួសារដូច្នេះដែរ។ យើងបោះជំហានទៅមុខទៀត ពោរពេញដោយកំហឹងឆាបឆួលចំពោះខ្មាំង និងដោយសេចក្តីប្តេជ្ញាចិត្តធ្វើបដិវត្តន៍រាយកម្ទេចខ្មាំង រំដោះប្រជាជនឲ្យ

ជានទាំងស្រុង និងជាស្ពាពរ ទៅទីអវសានដាច់ខាត ។

នៅវេលារសៀលស្អែកឡើង ទើបក្រុមយើងខ្ញុំបានទៅជួបនឹងសមមិត្ត សន នៅខាងកើតភ្នំដាច់ដោដូចបំណង ។ ខ្ញុំបានហុចកូនសំបុត្ររបស់អង្គការទៅជូនសមមិត្ត សន ។ សមមិត្តជានបែកសំបុត្រនោះអាន ដោយយកចិត្តទុកដាក់បំផុត ។ យប់នោះ សមមិត្ត សន ដែលជាស្នងការនយោបាយ កងអនុសេនាតូចនៃកងទ័ពបដិវត្តន៍យើង ដំបូងបំផុត ជានប្រមែប្រមូលប្រជុំប្រធានក្រុមទាំងអស់ ដើម្បីដាក់ផែនការធ្វើដំណើរទៅភ្នំជាំស្លាទៀតតាមការណែនាំរបស់អង្គការខាងលើ ។ លុះព្រឹកស្អែកឡើង យើងនាំគ្នាធ្វើកូចហាលឲ្យស្ងួតឲ្យជានម្នាក់ៗមួយស្បោង ដើម្បីធ្វើជាស្បៀងត្រៀមបម្រុងទុកក្នុងពេលដែលយើងចាប់ដំណើរការកាប់រានចំការថ្មីនៅឯភ្នំជាំស្លា ។

នៅដើមខែធ្នូ ឆ្នាំ១៩៦៩ ក្រុមយើងខ្ញុំនិងអង្គភាពសមមិត្ត សន ជានាំគ្នាចេញដំណើរឆ្ពោះតម្រង់ទៅភ្នំជាំស្លា ។ យើងចេញដំណើរពីភ្នំក្រាស់តម្រង់ទៅរកផ្លូវលំមួយនៅខាងលិចភូមិកំលត ដោយត្រូវដើរកាត់ព្រៃធំ ហើយក្រាស់ងងឹតឈឹងរកមើលទិសតំបន់អ៊ូមិនឃើញ មិត្តនិសារនាំផ្លូវក៏វង្វេងរកវីអស់រយៈបួនទៅប្រាំម៉ោង យើងចេះតែនាំគ្នារុកក្នុងព្រៃ រហូតដល់ម៉ោង៨ល្ងាច ទើបធ្លាយចេញវាល ។ គ្រាន់តែឈានដើងចេញដល់វាលភ្លាម ខ្លាំងជាញ់យើងប្រាវភ្លាមដែរ ។ មិត្ត សន បញ្ជាឲ្យមិត្តយើងអែបដំបូក ឬតល់ឈើធំៗ ហើយជាញ់សម្រុកទៅខ្លាំងវិញយ៉ាងខ្លាំង ។ អាខ្លាំងជាត់ម្ចាស់ការ ព្រោះវាត្រៀមស្វាក់យូរពេក តាំងពីយប់មកម្ល៉េះ ។ វាអត់ងងុយ រង់ចាំស្វាក់ផ្លូវយើងយប់មិញទើសភ្លឺមកដល់រសៀលនេះ វាក៏ដេកលង់លក់អស់នៅក្នុងអូរ ពេលឮសូរកាំភ្លើងផ្ទុះភ្លាម វាសុទ្ធក្រោកឡើងទាំងមមីមមើ ហើយទាញកាំភ្លើង ជាញ់តែពីសតែពាស ឥតដឹងទិសតំបន់អ៊ូឡើយ ។ អាខ្លះស្ងន់ពេក គិតតែពីក្រាបជាញ់ឡើងលើ ។ ឆ្លងតាមការប្រយុទ្ធអស់១៥នាទីខ្លាំងក៏ជាក់ទ័ពត់ខ្លាត់ខ្លាយអស់ ។ យើងរឹបយកអង្ករមួយចំនួន គ្រាប់កាំភ្លើងមួយចំនួន និងសម្ភារផ្សេងៗទៀតមួយចំនួន ធ្វើជាទុនសម្រាប់ដំណើរទៅមុខទៀត ឈានទៅសម្រេចការកិច្ចបដិវត្តន៍របស់យើងដោយជោគជ័យ ។

ក្រោយមក យើងក៏បន្តដំណើរទៅដល់ស្ទឹងដា ។ សមមិត្តណាដែលពូកែហែលទឹក ត្រូវហែលឆ្លងស្ទឹងដានេះទៅត្រើយម្ខាងមុន ព្រោះស្ទឹងត្រង់នេះធំ ជ្រៅ ហើយទឹកក៏ហូរខ្លាំង រួចហើយមិត្តយើងនាំគ្នាកាប់វល្លិ៍ធំមួយចងសន្ធឹងកាត់ស្ទឹងនេះដើម្បីឲ្យមិត្តដទៃទៀតហែលសួតាមវល្លិ៍នេះ ឆ្លងទៅត្រើយម្ខាងទៀតទាំងអស់គ្នា ។ រួចហើយមិត្តយើងកាត់ដាច់វល្លិ៍នេះចោល ។ ក្រោយឆ្លងស្ទឹងដាហើយ យើងក៏បានធ្វើដំណើរទៅដល់ភ្នំជាំស្លាដូចបំណង ។ អង្គភាពយើងទាំងមូលមកដល់ឥឡូវមានគ្នាដល់៨០ជ្លាយនាក់ហើយ គិតទាំងនិរសារម្នាក់ និងពេទ្យម្នាក់ផង ។ ទៅដល់ភ្នំជាំស្លា ក្រោយដើរជ្រើសរើសទីកន្លែងស្រួលបួលហើយ យើងនាំគ្នាចាប់ផ្តើមវាយសម្រុកបោះទីតាំងនៅលើកំពូលភ្នំនេះ ។ យើងចែកកម្លាំងគ្នាធ្វើការងារតាមក្រុម។ មិត្តខ្លះមានការៈទៅរកកូច សម្រាប់ធ្វើស្បៀងអាហារ ក្រុមមិត្តខ្លះកាប់ចម្ការ ក្រុមមិត្តខ្លះកាប់ចម្រូងខ្លារសម្រាប់ធ្វើរបងការពារមូលដ្ឋានបដិវត្តន៍ថ្មីយើង ។ ក្រុមមិត្តខ្លះទៀតវាយសម្រុកធ្វើជម្រកសម្រាប់រស់នៅ ចំណែកឯមិត្តនិសារជានាំមិត្តពេទ្យរុកចូលព្រៃជ្រៅៗស្វែងរកឫសឈើ និងវល្លិ៍ព្រៃផ្សេងៗ យកមកដុំថ្នាំសម្រាប់ព្យាបាលមិត្តយើង ។ យើងនាំគ្នាធ្វើការយ៉ាងដុសដល់រីករាយ ក្នុងសន្ទុះវាយសម្រុកបដិវត្តន៍ជាប់ជានិច្ច ។ ក្រុមនីមួយៗប្រឡងប្រណាំងគ្នាធ្វើការងារមិនចាយប់ឬថ្ងៃឡើយ ។ គ្រាន់តែក្រុមបិតចម្រូងនិងធ្វើខ្លារក្នុងមួយថ្ងៃ ម្នាក់ៗអាចធ្វើចម្រូងជានពី៧,០០០ទៅ១០,០០០ដែ ។ ក្នុងរយៈតែមួយអាទិត្យប៉ុណ្ណោះ យើងកាប់ចម្ការជាន៤ហិកតា យើងធ្វើជម្រកនៅហើយស្រេច ព្រមទាំងបោះទីតាំងការពារដោយចម្រូងខ្លារ ព័ទ្ធជុំវិញយ៉ាងក្រាស់ ។ យើងមានគ្រាប់ពោត២២កំប៉ុងមានស្រូវពូជមួយចំនួន និងគ្រាប់ត្រឡាច ល្ពៅ មួយកូនថង់ ។ យើងនាំគ្នាប្រយុទ្ធដាំដុះលើផ្ទៃដី៤ហិកតានេះ ជានាសពេញទាំងអស់ រួចទើបពង្រីកចម្ការ យើងជាបន្តទៅទៀត ។ យើងទាំងអស់គ្នាប្តេជ្ញាថានឹងវាយសម្រុកបង្កបង្កើនដល់ឲ្យជានច្រើនជាអតិបរមា ដើម្បីមានស្បៀងបញ្ជូនទៅអង្គការត្រៀមរៀបចំវាយសម្រុកទៅខ្លាំងវិញដោយជោគជ័យនៅរដូវប្រាំង ។

មិនយូរប៉ុន្មាន ដំណាំដាំដុះផ្សេងៗរបស់យើងក៏ដុះទ្រុលទ្រុបពេញចម្ការ ។ យើងទាំងអស់គ្នារីករាយឥតខ្ចប់មា ។ តែមុននឹងទទួលផលយើងក៏នាំគ្នាសម្រុកធ្វើកូច ហាលថ្ងៃឲ្យស្ងួត

បញ្ជូនទៅអង្គការនៅភ្នំឱរ៉ាល់ បានជាប់ជានិច្ច។ ក្នុងគ្រប់ការកិច្ច ប្រចាំថ្ងៃនេះ សមមិត្ត វ៉ែត បានធ្វើដំណើរជាគំរូឈានមុខគេ គ្រប់ពេលវេលាទាំងអស់ គំរូទាំងខាងសីលធម៌ប្រយុទ្ធទ្រាំទ្រការលំបាកវេទនាសព្វបែបយ៉ាង គំរូក្នុងការឆ្នៃប្រឌិតធ្វើការងារពលកម្ម បង្កបង្កើនដល គំរូខាងគោរពអង្គការវិន័យ គំរូទាំងខាងគោលជំហរ សាមគ្គីទូលាយ យល់អធ្យាស្រ័យ និងជួយដោះទុក្ខធុរៈដល់សមមិត្តឯទៀតទាំងអស់។ អង្គភាពយើងបានរៀនសូត្រតាមគំរូបដិវត្តន៍រស់រវើកនេះជាប់ជានិច្ច។ យប់ណាក៏យើងខ្ញុំឃើញមិត្ត វ៉ែត អង្គុយបិតចម្រូង បិតខ្លារយ៉ាងដិត ដួងវិហគរំលងអាធ្រាត្រជានិច្ច។ យប់ណាក៏ឃើញមិត្ត វ៉ែត ឡើងជ្រាវភ្លើង និងជាន់បន្សាបភ្លើងក្នុងមួយយប់ៗ ពីរ-បីដង ដោយចុះត្រាំក្នុងទឹកជ្រោះត្រជាក់ស្រិបដូចទឹកកក។ បំពោះយុទ្ធមិត្តណាដែលមានជំងឺគ្រុនចាញ់ធំពោះ ធ្លាក់អណ្តើក សមមិត្ត វ៉ែត តែងឡើងដុតថ្ម ហើយរុំក្រណាត់កន្ទបរយ៉ីរយៃយ៉ាកមកឲ្យសង្កត់ពោះជារៀងរាល់យប់។ ពេលខោអាវរបែក យើងខ្ញុំតែងបានស្មើសុំខ្ចីម្ជុល ចេស សមមិត្ត វ៉ែត មកដេរប៉ះខោអាវ។ ក្នុងកូនថង់តូចមួយរបស់មិត្ត យើងឃើញមានដុំក្រណាត់ចាស់ៗ ប៉ុន្តែបាតដៃជារច្រើនបន្ទះ ដែលសមមិត្តហែកយកត្រង់សាច់ជាពីខោអាវដុយរលួយរបស់មិត្តយើងដែលចោល ព្រមទាំង ឡេវគួច ធំគ្រប់ពណ៌ ប្រហែលមួយទូកដៃ ដែលសមមិត្តបានកាត់យកពីអាវចាស់ៗ ដែលគេចោលដូច្នោះ មិត្តណាត្រូវការរបស់កំប៉ិកំប៉ុកអ្វី ក៏តែងនាំគ្នាទៅស្មើសុំសមមិត្ត វ៉ែតជានិច្ច ហើយមិត្ត វ៉ែត ក៏ច្រើន តែមានផ្តល់ជូនមិត្តយើងតាមសំណូមពរជានិច្ចដែរ។ មិត្តយើងក្នុងអង្គភាពទាំងមូលស្រឡាញ់គោរពនិងរៀនសូត្រតាមគំរូដាក់ស្តែងរបស់មិត្ត វ៉ែតជាប់ជានិច្ច។

អង្គភាពយើងខ្ញុំ ហូបក្តួចសាប អត់អំបិលជាងពីរខែមកហើយ។ យើងបានបញ្ជូនមិត្តយើងក្រុមមួយនាក់ឲ្យទៅទាក់ទងខាងកោះកុង។ យើងនៅរង់ចាំដំណឹងពីខាងកោះកុងនេះ ដិតបីខែហើយតែមិនឃើញមិត្តនិសារត្រឡប់មកវិញសោះ មិនដឹងជាមិត្តយើងត្រូវខ្មាំងស្ទាក់ចាប់តាមផ្លូវ ឬក៏មានគ្រោះកាចចង្រៃអ្វីតាមផ្លូវឡើយ។

ឱមាតុភូមិកម្ពុជា ជាទីស្នេហាស្មើជីវិត ទីណាក៏ដូចជាទីណាដែរ អ្នកសំបូរសព្វសត្វម្រឹគីម្រឹគា ត្រីសាច់ ក្តួចដំឡូងបន្លែឈើព្រៃនិងផ្លែឈើសព្វបែបយ៉ាង។ យើងមិនដែលខ្វះម្ហូបអាហារទេ យើងខ្វះតែអំបិលមួយមុខគត់។ អន្ទង់ត្រាំក្តួចមួយៗ ត្រាំតែបួនជ្រាំថ្ងៃមានត្រីពុលអណ្តែតព្រោងព្រាតហើយ។ នៅតាមមាត់ព្រៃក្បែរចម្ការ យើងធ្វើអន្ទាក់ ធ្វើជង់ ដាក់ខ្នារ បានសត្វព្រៃហូបជារៀងរាល់ថ្ងៃ។ បន្ថែ បង្ការព្រៃក៏មានបន្ថែបង្ការដែលយើងដាំក៏ដុះទ្រុបទ្រុប លូតលាស់លូណាស់។ យើងនឹងគិតដល់ជីវភាពប្រជាជនយើង ដែលរស់នៅក្នុងតំបន់ខ្ចាំង ត្រូវខ្ចាំងជិះជាន់ កាប់សម្លាប់បង្ហូរឈាមជារៀងរាល់ថ្ងៃ តែនៅតែប្រយុទ្ធអង់អាចក្លាហានជាមួយខ្មាំង មិនព្រមចុះញ៊ែមសារភាពខ្មាំងឡើយ ហើយទោះបីខ្លួនឯងខ្វះខាតអត់ឃ្លានយ៉ាងណា ក៏នៅតែបេះពីមាត់ពីក យកមកខបត្តូមួបដិវត្តន៍ដោយទឹកចិត្តសោមនស្សជ្រះថ្លាជាទីបំផុត។ យើងនឹកឃើញដល់យុទ្ធមិត្តយើងទាំងអស់ ដែលប្រយុទ្ធនៅក្នុងតំបន់ខ្ចាំង ត្រូវខ្ចាំងចាប់ចងជាក់គុក ច្រងាក់ ធ្វើទារុណកម្មលើរូបរាងកាយសព្វបែបយ៉ាង តែមិត្តយើងនៅតែប្រយុទ្ធជាមួយខ្មាំងជាប់មិនសារភាពខ្មាំង មិនឆ្លើយឲ្យការណ៍ខ្មាំងដាច់ខាត។ មិត្តយើងប្រយុទ្ធរហូតដល់ដង្ហើមចុងក្រោយបំផុត នៅក្នុងកន្លែងទារុណកម្ម។ យើងនឹកឃើញដល់អង្គការ ដល់យុទ្ធមិត្តយើងឯទៀតទាំងអស់ ដែលកំពុងដឹកនាំចលនាតស៊ូបដិវត្តន៍ បំផុសចលនាបដិវត្តន៍និងកំពុងប្រយុទ្ធស្ទាប់រស់ជាមួយខ្មាំងយ៉ាងអង់អាចក្លៀវក្លាបំផុត នៅពាសពេញដែនដីកម្ពុជាទាំងយប់ទាំងថ្ងៃ ដោយគ្មាននឹកនាដល់ការនឿយហត់អត់ឃ្លាន គ្មាននឹកនាដល់គ្រោះថ្នាក់អាយុជីវិតដាល់ខ្លួនបន្តិចសោះឡើយ។ បើយកវីរភាព និងការលះបង់របស់ប្រជាជនយើង យុទ្ធមិត្តយើង និងបក្សយើងមកប្រៀបធៀបនឹងការលំបាកវេទនារបស់យើងដាល់ ឃើញថាតិចតួចស្តួចស្តើងណាស់ គ្រាន់តែខ្វះអំបិលហូបប៉ុណ្ណឹង គ្រាន់តែទ្រាំទ្រនឹងអាកាសធាតុត្រជាក់ គ្រុនចាញ់ប៉ុណ្ណឹងៗ យើងប្តេជ្ញាសម្រេចភារកិច្ចដែលបក្សប្រគល់ឲ្យនេះឲ្យបានជោគជ័យទាំងស្រុង ទោះបីត្រូវឆ្លងកាត់ការលំបាកវេទនា ឬត្រូវធ្វើពលីកម្មខ្ពស់ជាងនេះទៀតក៏ដោយ។ ជារៀងរាល់ថ្ងៃ យើងខំដាំដុះ យើងខំរកក្តួច មកហាលប្រមែប្រមូល និងសន្សំស្បៀងផ្សេងៗទុកសម្រាប់បញ្ជូនទៅខបត្តូមអង្គការឲ្យបានអតិបរមា។

(នៅមានត)

សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម

មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ជ្រាបថាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០ ១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល : truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

សូមផ្តល់ព័ត៌មានដូចខាងក្រោម:

១) ឈ្មោះអ្នកប្រកាសជ្រាប់, ២) តើមានបងប្អូនបង្កើតរួមឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍: ឪពុក ម្តាយ បងប្រុសបួនប្រុស បងស្រី ឬបួនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍: ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍: រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍: លេខទូរស័ព្ទ អាស័យដ្ឋាន) ។

ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោម:

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍: រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ខបត្តម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉ៃ សុីតដេន និងសហរដ្ឋអាមេរិក

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃ២ ខែសីហា ឆ្នាំ១៩៩៩

មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ:

ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 148, April 2012 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.